■ វត្ថុបុរាណខ្មែរជិត៣០ដុំ បញ្ជូនមកកម្ពុជាវិញ <ទំព័រ ៣



■ ព្រះសហគមន៍នឹងបង្កើតគណៈកម្មារ សម្រាប់ទឹកដីអន្តរភូមិភាគ <ទំព័រ ២២-២៣




កាសែតចេញផ្សាយ ប្រចាំខែ ឆ្នាំទី១២

# អ្នកនាំសារ the messenger

ខែ មិថុនា | ឆ្នាំ ២០២២ | លេខទី ១៥២

www.catholiccambodia.org/km/ www.facebook.com/RVAKHMER/ https://khmer.rvasia.org/

JUNE, 2022 | #152


## អបអរសាទរពិធីឆ្លងព្រះវិហារសន្តអូគូស្តាំង

ពិធីឆ្លងព្រះវិហារសន្តអូគូស្តាំង កំពត នាថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០២២ ក្រោមអធិបតីភាពរបស់ លោកអភិបាល អូលីវីយេ ផ្មិតហាស្លេ អភិបាលព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ ដែលមាន គ្រីស្តបរិស័ទមកពីព្រះសហគមន៍នានាយ៉ាងច្រើនកុះករ។



# គម្រោងការរបស់ព្រះជាម្ចាស់

នៅឆ្នាំ ១៩៩៩ ផុន ជាយុវជនម្នាក់អាយុ ២០ឆ្នាំ បានប្រាប់ទៅកាន់ លោកឪពុករបស់គាត់ ដែលមានដើមកំណើតនៅព្រះសហគមន៍កាតូលិកប៊ូស្រា ក្នុងខេត្តមណ្ឌលគិរីថា «ពុក ខ្ញុំចង់រៀនដើម្បីក្លាយទៅជាបូជាចារ្យ ដើម្បីជួយបម្រើព្រះសហគមន៍កាតូលិកក្នុងភូមិភាគកំពង់ចាម?»

លោក ទ្រី ជាឪពុកបានឆ្លើយថា «កូនអើយ! បើឯងពិតជាចង់បួសមែន ពុកពិតជាមិនរស់ទេ»

ដោយការជំទាស់នេះ សព្វថ្ងៃនេះលោក ផុន បានរៀបការបង្កើតគ្រួសារមួយដ៏កក់ក្ដៅ ជាស្វាមីល្អ និងគួរឱ្យគោរពសម្រាប់ភរិយារបស់គាត់ និងជាទីពឹងដ៏រឹងមាំរបស់កូនៗទាំង២នាក់របស់គាត់ផងដែរ។

នៅឆ្នាំ ២០០០ យុវជនម្នាក់ទៀតឈ្មោះ ប្រាក់ ណែត បានសុំការអនុញ្ញាតពីឪពុករបស់គាត់ ទៅរៀនបួសទៅជាលោកបូជាចារ្យនាពេលអនាគត។

ឪពុកឆ្លើយថា «ទេ ពុកមិនយល់ព្រមទេ។ បើកូនប្រុសនៅតែចង់ក្លាយជាបូជាចារ្យទៀត ពុកនឹងស្លាប់ភ្លាម។»

បន្ទាប់មកកូនឆ្លើយថា៖ «ឪពុក! ពុកមានសេរីភាព ក្នុងការជ្រើសស្លាប់ ឬរស់ ជាការសម្រេចចិត្តរបស់ពុក ព្រោះជាជីវិតរបស់ពុក។ រីឯ កូនវិញ ក៏មានសេរីភាពជ្រើសរើសជីវិតផ្ទាល់ខ្លួន និងចង់ក្លាយជាមនុស្សម្នាក់ដែលខ្ញុំចូលចិត្តនាពេលអនាគតរបស់ខ្ញុំដូចគ្នាដែរ»។

ប៉ុន្មានឆ្នាំក្រោយមក កូនប្រុសនោះបានជួបនារីម្នាក់ដែលខ្លួនស្រលាញ់ និងបានរៀបការជាមួយនាង ហើយ សព្វថ្ងៃនេះ ពួកគេមានកូនមួយជាចំណងដៃ រស់នៅដោយសប្បាយរីករាយ និងមានសុភមង្គល ។

នៅឆ្នាំ ២០១៣ យុវនារីម្នាក់ឈ្មោះ ពេន ហ៊ីល បានសួរឪពុកម្ដាយរបស់នាងថា តើពួកគាត់នឹងអនុញ្ញាតឱ្យនាងក្លាយជា ដូនជីកាតូលិកដែរឬទេ។ ឪពុកមិននិយាយអ្វីទាំងអស់ ហើយដើរចេញទៅ។ ឯម្ដាយបានប្រាប់ទៅកូនស្រីថា «ស្រីហ៊ីលអើយ! កូន ក្លាយជាបងស្រីកាតូលិក មិនមែនជាជម្រើសសម្រាប់ជួយមនុស្សទូទៅទេ ហើយមិនអាចជួយប្រជាជនយើងបានដែរ។ កូនគួរតែជ្រើសរើសសិក្សាផ្នែកឱសថ ឬគលានុបដ្ឋាយិការនឹងក្លាយជាបុគ្គលិកម្នាក់អាចថែទាំសុខភាព គឺល្អជាងសម្រាប់អនាគតរបស់កូន។»



### ហេតុផលឪពុកម្ដាយ៖

ករណីទាំងបីខាងលើបង្ហាញពីភាពស្ទាក់ស្ទើររបស់ឪពុកម្ដាយនៅក្នុងព្រះសហគមន៍កាតូលិកប៊ូស្រា ក្នុងការលើកទឹកចិត្តកូនៗរបស់ពួកគេឱ្យស្ដាប់ការត្រាស់ហៅរបស់ព្រះជាម្ចាស់ អោយទៅជាដូនជី ឬបូជាចារ្យ។ នេះមិនមែនជាកង្វះក្ដីស្រឡាញ់របស់ម្ដាយឪពុកចំពោះការត្រាស់ហៅរបស់កូនៗឬមិនមានការយកចិត្តទុកដាក់ពីព្រះសហគមន៍នោះទេ គឺដោយសារតែការភ័យខ្លាចថា កូនៗរបស់ពួកគាត់ជាជនជាតិព្នងរងការលំបាកក្នុងការសិក្សាយូរឆ្នាំ។ ពួកគាត់គិតថា ប្រសិនបើកូនរបស់ពួកគាត់បន្តការសិក្សាដ៏យូរបែបនេះ មិនយូរមិនឆាប់ ពួកគេនឹងបោះបង់ ហើយក្លាយជាមនុស្សម្នាក់ធ្លាក់ទឹកចិត្ត ពោរពេញដោយទុក្ខ

ដ៏ក្រៀមក្រំក្នុងជីវិតរបស់ពួកគេ។ ដូច្នេះ ការជំទាស់ជាជម្រើសប្រសើរចំពោះសំណើរសុំចង់ទៅបួសរបស់ពួកកូនៗនាពេលដំបូង។

### ព្រះជាម្ចាស់សម្ដែងការអស្ចារ្យ ចំពោះការភ័យខ្លាចរបស់ឪពុកម្ដាយ

ទោះបីជាឪពុកម្ដាយជនជាតិដើមភាគតិចទាំងនោះ បដិសេធចំពោះកូនៗរបស់ពួកគាត់យ៉ាងណា តែព្រះហឫទ័យប្រណីសណ្ដោសរបស់ព្រះជាម្ចាស់បានជម្រុញឱ្យយុវជន និងយុវនារីក្លាហានឆ្លើយតបតាមការត្រាស់ហៅជាអ្នកបួស ដើម្បីបម្រើព្រះសហគមន៍របស់ព្រះអង្គ។

ក្លារ៉ា ពេន ហ៊ីល បានក្លាយជាដូនជីកាតូលិកនៅក្នុងឆ្នាំ២០១៨ ក្នុងក្រុមស្រឡាញ់ឈើឆ្កាងព្រះយេស៊ូក្នុងភូមិភាគកំពង់ចាម។

យើងមកមើលអំពីជីវិតយុវជនម្នាក់ទៀត។ ប៉ុន្មានឆ្នាំមុននេះ លោក ប្រាក់ ប៊ុនហុង ធ្លាប់ជាចុងភៅម្នាក់ល្បីឈ្មោះនៅក្នុងភោជនីយដ្ឋានមួយកន្លែងក្នុងទីក្រុងភ្នំពេញ។ លោកឪពុកហាន់ ស្លូហ្សាន្ទូ ម៉ាទិនណេ យេស៊ូ (Juan) ដែលជាអ្នកទទួលខុសត្រូវព្រះសហគមន៍កាតូលិកប៊ូស្រា បានទៅសួរសុខទុក្ខលោក ប៊ុនហុង ហើយលោកបានប្រាប់ពីគោលបំណងថា គាត់ចង់ឈប់ពីការងារនេះ និងចង់បន្តការសិក្សា ដើម្បីក្លាយជាបូជាចារ្យសម្រាប់ព្រះសហគមន៍កាតូលិក។ លោកឪពុកហាន់ មិនបានគិតថាសម្ដីរបស់លោកប៊ុនហុងជាការលេងសើចនោះទេ ប៉ុន្តែផ្ទុយទៅវិញគាត់បានគាំទ្រយ៉ាងពេញទំហឹងដោយលើកទឹកចិត្ត យកចិត្តទុកដាក់ និងណែនាំ។

ដោយសារការគាំទ្រឥតឈប់ឈរ និងការយកចិត្តទុកដាក់អស់ពីចិត្តរបស់លោកឪពុកហាន់ ដែលជាសមាជិកនៃក្រុមគ្រួសារយ៉ារ៉ូម៉ាល់(Yarumal) មកពីប្រទេសកូឡុំប៊ី នៅថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០២២ លោកឧបដ្ឋាក ប្រាក់ ប៊ុនហុង ត្រូវបានតែងតាំងជាបូជាចារ្យនៅក្នុងព្រះសហគមន៍កាតូលិកសន្ត យ៉ូហានបាទីស្ដ ប៊ូស្រា ក្នុងខេត្តមណ្ឌលគិរី។

លោកឪពុក ប្រាក់ ប៊ុនហុង ជាប្អូនប្រុសរបស់លោក ប្រាក់ ណែត ដែលឪពុកបង្កើតធ្លាប់បានបដិសេធ មិនឱ្យបួសក្លាយជាបូជាចារ្យ។ ឪពុកដដែល នៅថ្ងៃតែងតាំងកូនប្រុសជាបូជាចារ្យមានសេចក្ដីសោមនស្សរីករាយស្វាគមន៍យើងដែលជាបូជាចារ្យ ហើយបាននាំប៊ុនហុង ដែលជាកូនទៅកាន់ព្រះវិហារដែលទើបនឹងសាងសង់ថ្មី ថ្វាយខ្លួនទៅព្រះជាម្ចាស់ ដោយមានសក្ខីកម្មពីគ្រីស្តបរិស័ទចំនួនប្រមាណ ១៣០០នាក់។

នេះគឺជាការផ្លាស់ប្ដូរដ៏អស្ចារ្យសម្រាប់ព្រះសហគមន៍កាតូលិក។ ឥឡូវនេះ ឪពុកម្ដាយមានទំនុកចិត្ត លើកទឹកចិត្តកូនឱ្យសម្រេចសេចក្ដីប្រាថ្នានៃការត្រាស់ហៅដ៏ពិតប្រាកដរបស់ព្រះជាម្ចាស់ចំពោះពួកគេ។

នៅចុងបញ្ចប់នៃពិធីអភិបូជាលោកឪពុកប្រាក់ ប៊ុនហុងជាបូជាចារ្យថ្មីបានឡើងថ្លែងអំណរគុណដល់មនុស្សជាច្រើននៅក្នុងកម្មវិធីតែងតាំងនោះ។ គាត់ក៏បានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះនិស្សិត ទេវវិទ្យាល័យទាំងអស់ជាមិត្តរបស់គាត់ ទាំងខ្មែរ និងវៀតណាម ចំពោះទំនាក់ទំនង ការជួយគ្នា និងការរស់នៅជាសហគមន៍។ ឥឡូវនេះលោកឪពុកប៊ុនហុង មានអំណរសប្បាយដែលព្រះជាម្ចាស់បានប្រទានបេសកកម្មថ្មីសម្រាប់ជីវិតរបស់គាត់។ នេះជាការផ្លាស់ប្ដូរមួយដ៏អស្ចារ្យ និងដោយសេចក្ដីស្រឡាញ់ផងដែរ។

«គ្មានការអ្វីដែលព្រះជាម្ចាស់ធ្វើមិនកើតនោះឡើយ (លក១,៣៧)»។

សូមព្រះជាម្ចាស់ប្រទានពរដល់ការផ្លាស់ប្ដូរដ៏អស្ចារ្យនេះ!

*លោកអភិបាលអន់តូនីសាមី ស៊ូសៃរាជ្យ*
*អតីតលោកអភិបាលព្រះសហគមន៍ភូមិភាគកំពង់ចាម*

Formation, Dailouge, Cooperation
ការិយាល័យផ្សព្វផ្សាយព័ត៌មានកាតូលិក

ចាងហ្វាង : លោក លី សុវណ្ណា
សេចក្ដីប្រកាសលេខ៖ លេខចុះបញ្ជី២០២២៖ ១២៧៩|២២ធត.ប្រ
ផ្ទះលេខ ២៥ ផ្លូវលេខ ២៤២ សង្កាត់ បឹងព្រលិត ខណ្ឌ ៧ មករា រាជធានីភ្នំពេញ
Contact: (855) 17 726 060
Email : csccambodia@gmail.com / Website : www.catholiccambodia.org
Email : catholicphnompenh@gmail.com / Website : www.catholicphnompenh.org
https://www.facebook.com/CatholicCambodia / https://www.facebook.com/CatholicPhnomPenh

# កម្ពុជាសោកស្តាយដែលមីយ៉ាន់ម៉ាប្រហារជីវិតសកម្មជនបក្សប្រឆាំងចំនួន ០៤រូប

*អត្ថបទ៖ អមរិន្ទ ដានុត*

កម្ពុជាដែលជាប្រធានអាស៊ាន មានការក្តីតក់ស្លុត និងសោកសៅយ៉ាងក្រៃលែង ទៅលើការសម្រេចការប្រហារជីវិតសកម្មជនបក្សប្រឆាំងចំនួន ០៤រូបនៅប្រទេសមីយ៉ានម៉ាកាលពីថ្ងៃទី២៥ ខែកក្កដា បើទោះបីជាសម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន ស្នើសុំឱ្យពិចារណាឡើងវិញលើសេចក្តីសម្រេចផ្តន្ទាទោសលើជនទាំងនោះក៏ដោយ។



*លោក មីន អ៊ូង ហ្លាំង (Min Aung Hlaing)។*



*សកម្មជនបក្សប្រឆាំងដែលត្រូវបានគេប្រហារជីវិត។*

យោងតាមសេចក្តីថ្លែងការណ៍របស់ ប្រធានអាស៊ាន ស្តីពីការប្រហារជីវិតសកម្មជនបក្សប្រឆាំងបួននាក់នៅមីយ៉ាន់ម៉ា នាថ្ងៃទី២៥ ខែកក្កដា បានឱ្យដឹងថា សកម្មជនបក្សប្រឆាំងចំនួន៤គ្នាដែលត្រូវធ្វើការប្រហារជីវិតនោះមាន លោក ភ្យូ ហ្សេយ៉ា ថវ, លោក ក្យរ មីនយូ, លោក ឡា មីយូ អោង និងលោក អេង ធូរ៉ា ហ្សេ។

សេចក្តីថ្លែងការណ៍បានបញ្ជាក់ថា ៖ «អាស៊ានពិតជាមានក្តីតក់ស្លុត និងសោកសៅយ៉ាងក្រៃលែងដោយសារការប្រហារជីវិតសកម្មជនបក្សប្រឆាំងចំនួន ០៤រូបនេះ បើទោះបីមានការស្នើសុំឱ្យពិចារណាឡើងវិញលើសេចក្តីសម្រេចផ្តន្ទាទោសលើជនទាំងនោះ ដោយផ្ទាល់ពីសំណាក់សម្តេចតេជោ ហ៊ុន សែន ក្នុងនាមជាប្រធានអាស៊ានក៏ដូចជាសំណូមពរពីសំណាក់រដ្ឋសមាជិកអាស៊ានដទៃទៀត យ៉ាងណាក្តី»។

ប្រធានអាស៊ានក៏បានអំពាវនាវយ៉ាងខ្លាំងក្លា និងជាបន្ទាន់ដល់ភាគីទាំងអស់ឱ្យជៀសវាងនូវសកម្មភាពទាំងឡាយណាដែលធ្វើឱ្យវិបត្តិនៅមីយ៉ាន់ម៉ាកាន់តែធ្លាក់ដុនដាប រារាំងដល់ការសន្ទនាដោយសន្តិវិធីក្នុងចំណោមភាគីពាក់ព័ន្ធទាំងអស់ និងបង្កគ្រោះថ្នាក់ដល់សន្តិភាព សន្តិសុខ និងស្ថិរភាព ទាំងនៅមីយ៉ាន់ម៉ា និងក្នុងតំបន់ទាំងមូល។

នេះជាបញ្ហាដែលអាស៊ានយកចិត្តទុកដាក់យ៉ាងខ្លាំង។ ខណៈដែលមានការទទួលស្គាល់នូវភាពស្មុគស្មាញនៃវិបត្តិ ព្រមទាំងកំដៅទោសៈមោហៈផ្ទុះឡើង គ្រប់ទិសទីក្នុងប្រទេសមីយ៉ាន់ម៉ា អាស៊ានជារួមបានអំពាវនាវឱ្យភាគីពាក់ព័ន្ធទាំងអស់មានការអត់ទ្រាំ និងភាពអត់ធ្មត់ជាអតិបរិមា ហើយខិតខំជៀសវាងមិនធ្វើឲ្យជម្លោះរីករាលដាលកាន់តែខ្លាំង។ នេះបើតាមសេចក្តីថ្លែងការណ៍នេះ។

ប្រភពដដែលបានលើកឡើងទៀតថា ការអនុវត្តទោសប្រហារជីវិត តែមួយសប្តាហ៍មុនកិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសអាស៊ានលើកទី៥៥ គឺជាទង្វើមិនអាចអត់ឱនបានធ្ងន់ធ្ងរណាស់ ព្រោះវាបានទាញថយក្រោយនូវវឌ្ឍនភាព និងថែមទាំងសបញ្ជាក់ច្បាស់ពីកង្វះឆន្ទៈគាំទ្រកិច្ចខិតខំប្រឹងប្រែងជាពិសេសរបស់ប្រធានអាស៊ាន។

សេចក្តីថ្លែងការណ៍បានបន្ថែមថា ៖ «ប្រធានអាស៊ានបានខិតខំប្រឹងប្រែងក្នុងការជួយពន្លឿនវឌ្ឍនភាពនៃការអនុវត្តកិច្ចព្រមព្រៀងជាឯកច្ឆន្ទ៥ចំណុច ពោលគឺការកសាងភាពជឿជាក់ និងទំនុកចិត្ត ដើម្បីឲ្យធ្វើមានកិច្ចសន្ទនាក្នុងចំណោមភាគីពាក់ព័ន្ធទាំងអស់ សំដៅបញ្ចប់អំពើហិង្សា និងសម្រាលទុក្ខវេទនារបស់ប្រជាជនស្លូតត្រង់»។

អាស៊ាននៅតែប្រកាន់ខ្ជាប់គោលការណ៍ដែលមានចែងក្នុងធម្មនុញ្ញអាស៊ាន និងកិច្ចព្រមព្រៀងជា ឯកច្ឆន្ទ៥ចំណុច។ ក្នុងនាមជាប្រធានអាស៊ាន កម្ពុជាសូមលើកបន្ទរនូវសម្លេងដ៏លើសលុបក្នុងមជ្ឈដ្ឋានអាស៊ាន ក៏ដូចជាសហគមន៍អន្តរជាតិ ដែលជំរុញឱ្យអាជ្ញាធរទីក្រុងណៃពិដោ ចាត់វិធាន ការជាក់ស្តែង ដើម្បីអនុវត្តកិច្ចព្រមព្រៀងជាឯកច្ឆន្ទ៥ចំណុចឱ្យបានពេញលេញ និងប្រកបដោយ ប្រសិទ្ធភាព។

គួរបញ្ជាក់ថា នាដើមខែមិថុនាកន្លងទៅនេះ មន្ត្រីអ្នកនាំពាក្យរបស់របបសឹកភូមាបានប្រកាសនឹងកាត់ទោសប្រហារជីវិតមនុស្ស៤នាក់ ដែលនេះគឺជាការប្រហារជីវិតលើកទី១ក្នុងប្រទេសនៅតំបន់អាស៊ីអាគ្នេយ៍នេះក្នុងពេលប៉ុន្មានទសវត្សរ៍មកនេះ៕

# វត្ថុបុរាណខ្មែរជិត៣០ដុំ បញ្ជូនមកកម្ពុជាវិញ

*អត្ថបទ៖ អមរិន្ទ ដានុត*

មន្ត្រីជាន់ខ្ពស់នៃក្រសួងវប្បធម៌ និងវិចិត្រសិល្បៈកម្ពុជា និងមន្ត្រីនៃស្ថានទូតសហរដ្ឋអាមេរិកប្រចាំកម្ពុជា បានស្វាគមន៍នូវការមកដល់នៃវត្ថុបុរាណដែលត្រូវបានលួចចេញពីប្រទេសកម្ពុជាចំនួន ២៧ដុំ ត្រឡប់មកកាន់ស្រុកកំណើតវិញ និងដាក់រក្សាទុកនៅសារមន្ទីរជាតិកម្ពុជា នារសៀលថ្ងៃទី១៣ ខែកក្កដា។





ការស្វាគមន៍នេះ មានការចូលរួមដោយ លោកឧបការីរដ្ឋមន្ត្រីក្រសួងការបរទេសសហរដ្ឋអាមេរិកទទួលបន្ទុកកិច្ចការអាស៊ីបូព៌ា និងប៉ាស៊ីហ្វិក Daniel J. Kritenbrink, លោកឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិកប្រចាំប្រទេសកម្ពុជា W. Patrick Murphy និងលោកស្រីបណ្ឌិតសភាចារ្យ ភឿង សកុណា រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈកម្ពុជា។

លោកឧបការីរដ្ឋមន្ត្រី Kritenbrink បានថ្លែងសង្កត់ធ្ងន់ពីអនុស្សាវរណៈយោគយល់គ្នា រវាងរាជរដ្ឋាភិបាលកម្ពុជា និងសហរដ្ឋអាមេរិក ដែលបានពង្រឹងកិច្ចសហប្រតិបត្តិការផ្នែកវប្បធម៌ រវាងសហរដ្ឋអាមេរិក និងកម្ពុជា ដោយសម្របសម្រួលការបញ្ជូនត្រឡប់មកវិញ នូវវត្ថុបុរាណមិនអាចកាត់ថ្លៃបានចំនួនជាង ១០០ដុំ កសាងសមត្ថភាពរបស់ប្រជាជនកម្ពុជាដែលធ្វើការងារអភិរក្សបេតិកភណ្ឌវប្បធម៌។

លោកក៏បានសរសើរដល់ការខិតខំរួមគ្នារបស់ក្រសួងយុត្តិធម៌សហរដ្ឋអាមេរិក ផ្នែកអនុវត្តច្បាប់មេធាវីប្រចាំតំបន់ Manhattan ក្រសួងវប្បធម៌កម្ពុជា និងស្ថានទូតអាមេរិក ដែលបាននាំដល់ការធ្វើមាតុភូមិនិវត្តន៍នៃវត្ថុបុរាណចំនួន ២៧ ដុំនេះ។

លោក Kritenbrink បានមានប្រសាសន៍ថា៖ «ពិធីនៅថ្ងៃនេះគឺជាការបង្ហាញឲ្យឃើញពីទំនាក់ទំនងរឹងមាំ រវាងសហរដ្ឋអាមេរិក និងក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ។ គម្រោងគំនិតផ្តួចផ្តើមរបស់សហរដ្ឋអាមេរិក ដូចជាមូលនិធិឯកអគ្គរដ្ឋទូតសម្រាប់ការអភិរក្សវប្បធម៌ ស្តែងឲ្យឃើញនូវការគាំទ្រយូរអង្វែងរបស់យើង ចំពោះការជួសជុលទីតាំងប្រវត្តិសាស្ត្រ ដែលមានសារសំខាន់ផ្នែកវប្បធម៌សម្រាប់ប្រទេសកម្ពុជា»។

នៅក្នុងពិធីនោះ លោកឯកអគ្គរដ្ឋទូត Murphy បានប្រកាសពីអំណោយថវិកាថ្មីមួយរបស់រដ្ឋាភិបាលសហរដ្ឋអាមេរិក តាមរយៈមូលនិធិឯកអគ្គរដ្ឋទូតសម្រាប់ការអភិរក្សវប្បធម៌ ដែលមានទឹកប្រាក់ចំនួន ៣៦០ ៨០០ដុល្លារ សម្រាប់ជួសជុលប្រាសាទព្រះវិហារ។

លោកបានបន្តថា នេះជាអំណោយបន្ថែមលើថវិកាចំនួន ៤០៦ ០០០ដុល្លារ ដែលត្រូវបានផ្តល់រួចហើយដោយរដ្ឋាភិបាលសហរដ្ឋអាមេរិកសម្រាប់អភិរក្សប្រាសាទប្រវត្តិសាស្ត្រនេះ ដែលស្ថិតនៅភាគខាងជើងនៃប្រទេសកម្ពុជា។

លោកឯកអគ្គរដ្ឋទូត Murphy បានមានប្រសាសន៍ថា៖ «សហរដ្ឋអាមេរិកមានមោទនភាពចំពោះការរួមចំណែករបស់ខ្លួន ចំពោះការខិតខំក្នុងការអភិរក្សបេតិកភណ្ឌវប្បធម៌របស់ប្រទេសកម្ពុជា និងចំពោះការខិតខំរួមគ្នារបស់យើង ក្នុងការបញ្ជូនត្រឡប់មកប្រទេសកម្ពុជាវិញ នូវវត្ថុបុរាណដែលមិនអាចកាត់ថ្លៃបាន ពីសហរដ្ឋអាមេរិក»។

ជាមួយគ្នានោះដែរ លោកស្រីបណ្ឌិតសភាចារ្យ ភឿង សកុណា ក៏បានថ្លែងអំណរគុណដោយស្មោះចំពោះការរួមចំណែករបស់រដ្ឋាភិបាលសហរដ្ឋអាមេរិក ទាំងពេលវេលា ទាំងធនធាន នៅក្នុងការប្រយុទ្ធប្រឆាំងនឹងការជួញដូរដោយខុសច្បាប់នូវសម្បត្តិវប្បធម៌។ លោកស្រីមានប្រសាសន៍ថា ៖ «យើងរីករាយនឹងបន្តកិច្ចសហប្រតិបត្តិការ នៅក្នុងការស៊ើបអង្កេត និងការខិតខំរបស់យើង ការបណ្តុះបណ្តាល និងការផ្លាស់ប្តូរព័ត៌មានគ្នា ហើយនិងជំនាញ ក្នុងពេលដែលយើងរកឃើញវិញ នូវទ្រព្យសម្បត្តិដ៏មានតម្លៃរបស់ជាតិយើង»។

គួរបញ្ជាក់ថា សហរដ្ឋអាមេរិកបានផ្តល់ថវិកាចំនួនជាង ៥ លានដុល្លារ ដល់រាជរដ្ឋាភិបាលកម្ពុជា គិតចាប់តាំងពីឆ្នាំ ២០០១ មក សម្រាប់ការងារអភិរក្សវប្បធម៌ ដែលក្នុងនោះ រួមមានជាង ៣,៥ លានដុល្លារសម្រាប់អភិរក្សនិងជួសជុលប្រាសាទភ្នំបាក់ខែង នៅខេត្តសៀមរាប និងសម្រាប់ជួយដល់សារមន្ទីរទួលស្លែង៕

# ក្រ.សុខាភិបាលនឹងផ្តល់ថ្នាំមីក្រូសារជាតិចម្រុះដល់ស្ត្រីមានផ្ទៃពោះ

*អត្ថបទ៖ អមរិន្ទ ដានុត*

មន្ត្រីជាន់ខ្ពស់នៃក្រសួងសុខាភិបាលបានលើកឡើងថា អង្គការសុខភាពពិភពលោកបានអនុម័តបញ្ចូលគ្រាប់ថ្នាំមីក្រូសារជាតិចម្រុះទៅក្នុងបញ្ជីឱសថសារវន្តរបស់ខ្លួនរួចទៅហើយ ដែលអនុញ្ញាតឱ្យប្រទេសនីមួយៗរួមទាំងកម្ពុជាផងដែរ បញ្ចូលគ្រាប់ថ្នាំមីក្រូសារជាតិចម្រុះនេះក្នុងបញ្ជីឱសថសារវន្តរបស់ខ្លួនបាន។



លោកស្រី ប្រាក់ សោភ័ណ្ឌនារី រដ្ឋលេខាធិការក្រសួងសុខាភិបាល និងជាប្រធានគណៈកម្មការដឹកនាំសម្របសម្រួលការផ្តល់បន្ថែមគ្រាប់ថ្នាំមីក្រូសារជាតិចម្រុះសម្រាប់ស្ត្រីមានផ្ទៃពោះនៅកម្ពុជា បានថ្លែងថា ៖ «ដូច្នេះហើយកម្ពុជានឹងធ្វើការសិក្សាសាកល្បងការផ្តល់បន្ថែមគ្រាប់ថ្នាំមីក្រូសារជាតិចម្រុះដល់ស្ត្រីមានផ្ទៃពោះនេះដោយសិក្សាមើលការទទួលយក, អាត្រាគ្របដណ្តប់, ក្លិន, រស់ជាតិ, ផលប៉ះពាល់ និងតម្លៃក្នុងការផ្តល់បន្ថែមគ្រាប់ថ្នាំមីក្រូសារជាតិចម្រុះ ជំនួសគ្រាប់ថ្នាំជាតិដែកដល់ស្ត្រីមានផ្ទៃពោះ»។

យោងលើលទ្ធផលការអង្កេតថ្នាក់ជាតិកន្លងមកបានឱ្យដឹងថាស្ត្រីចំនួន ៦២% និងកុមារ ៦៤% មានបញ្ហាកង្វះជាតិស័ង្កសី។ កង្វះជាតិហ្វូលេតក៏នៅតែជាបញ្ហាដែលប៉ះពាល់ដល់ស្ត្រី១៨%។ កង្វះជីវជាតិ D ក៏ជាបញ្ហាសុខភាពសាធារណៈកម្រិតមធ្យមនៅក្នុងប្រទេសផងដែរ ដែលប៉ះពាល់ដល់ស្ត្រីកម្ពុជា ៣១%។

លើសពីនេះទៀតស្ត្រីចំនួន ៧៨% និងកុមារ ៦៦% មានកំហាប់ជាតិអ៊ីយ៉ូតនៅក្នុងទឹកនោមមិនគ្រប់គ្រាន់តាមស្តង់ដារឡើយ។ កង្វះជីវជាតិ B1 ក្នុងចំណោមស្ត្រីក៏ត្រូវបានរកឃើញថាស្ថិតនៅកំរិតដែលមានបញ្ហាផងដែរ។ ម្យ៉ាងវិញទៀតទោះបីជាអត្រានៃភាពស្លេកស្លាំងខ្ពស់ក្នុងចំណោមស្ត្រីកម្ពុជាក៏ដោយ យើងឃើញថាមានស្ត្រីតែ ៣% ប៉ុណ្ណោះមានបញ្ហាខ្វះជាតិដែក ហើយជាង ៦០% ទៀតមានបញ្ហាអេម៉ូក្លូប៊ីនមិនប្រក្រតី ឬបញ្ហា genetic។

លោកស្រី ប្រាក់ សោភ័ណ្ឌនារី បានបញ្ជាក់ថា ៖ «ទាំងអស់នេះសបញ្ជាក់ច្បាស់ថាស្ត្រីកម្ពុជាត្រូវការនូវមីក្រូសារជាតិមួយចំនួនផ្សេងទៀតដូចជាជាតិស័ង្កសី ជាតិហ្វូលេត ជាតិអ៊ីយ៉ូត ជីវជាតិ D ជីវជាតិ B1ជាដើមក្រៅពីជាតិដែក»។

មន្ត្រីសុខាភិបាលរូបនេះ បានបន្ថែមទៀតថា ការសិក្សាសាកល្បងការផ្តល់បន្ថែមគ្រាប់ថ្នាំមីក្រូសារជាតិចម្រុះដល់ស្ត្រីមានផ្ទៃពោះជំនួសគ្រាប់ថ្នាំជាតិដែកនេះគឺជាអាទិភាពខ្ពស់របស់ក្រសួងសុខាភិបាលដូចដែលមានចែងនៅក្នុងឯកសារពង្រាងនៃផែនទីបង្ហាញផ្លូវដើម្បីពន្លឿនការលើកកម្ពស់អាហារូបត្ថម្ភផង និងផែនការជាតិស្តីពីការគ្រប់គ្រងកុមារមានបញ្ហាស្គមស្គាំងផងដែរ។

ជាមួយគ្នានោះដែរ លោក ហ៊ូ ក្រេីននាយករងអង្គការហេលែន ខេល័រអន្តរជាតិ (Helen Keller) បានឱ្យដឹងដែរថា មានការសិក្សាស្រាវជ្រាវតាមបែបវិទ្យាសាស្ត្រចំនួន ២៦ ក្នុងរយៈពេលជាច្រើនឆ្នាំកន្លងទៅនេះ នៅទូទាំងពិភពលោកបានរកឃើញថា ការផ្តល់បន្ថែមគ្រាប់ថ្នាំមីក្រូសារជាតិចម្រុះជំនួសគ្រាប់ថ្នាំជាតិដែកដល់ស្ត្រីមានផ្ទៃពោះនឹងជួយការពារនិងកាត់បន្ថយនូវអានិភ័យជាច្រើនដូចជា: បញ្ហាទារកស្លាប់ក្នុងផ្ទៃ, ទារកកើតមិនគ្រប់គីឡូ, ទារកក្នុងផ្ទៃមិនឡើងទម្ងន់, ទារកកើតមិនគ្រប់ខែជាដើម។

លោកថា ៖ «ការសិក្សាក៏បានរកឃើញថា អត្រាស្លាប់របស់ស្ត្រីមានផ្ទៃពោះត្រូវបានកាត់បន្ថយជាអតិបរមា ហើយជួយកាត់បន្ថយ និងការពារស្ត្រីមានផ្ទៃពោះដែលមាបញ្ហាស្លេកស្លាំងស្រាប់ហើយនោះពីហានិភ័យធ្ងន់ធ្ងរលើការសម្រាលកូនមុនពេលគ្រប់ខែ, សម្រាលកូនមិនគ្រប់គីឡូ និងបញ្ហាមិនឡើងទម្ងន់របស់ម្តាយក្នុងអំឡុងពេលមានផ្ទៃពោះ»។

គម្រោងសាកល្បងនេះ នឹងធ្វើឡើងនៅក្នុងខេត្តកំពង់ធំ សម្រាប់រយៈពេល ២៤ ខែ ដោយចាប់ផ្តើមពីខែកក្កដា ឆ្នាំ ២០២២ ដល់ខែមិថុនា ឆ្នាំ ២០២៤ ដើម្បីវាយតម្លៃកត្តាដែលមានឥទ្ធិពលលើការប្រើប្រាស់ គ្រាប់ថ្នាំមីក្រូសារជាតិក្នុងចំណោមស្ត្រីមានផ្ទៃពោះនៅកម្ពុជា។



ការសិក្សានេះនឹងជ្រើសរើសអ្នកចូលរួមចំនួន ៧៤៥ នាក់ រួមទាំងស្ត្រីមានផ្ទៃពោះនៅក្នុងមណ្ឌលសុខភាពចំនួន ២០ ។ ស្ត្រីមានផ្ទៃពោះក្នុងក្រុមថ្នាំជាតិដែកនឹងទទួលបានគ្រាប់ថ្នាំចំនួន ៩០ គ្រាប់ស្របតាមគោលការណ៍ណែនាំរបស់ប្រទេសកម្ពុជា ខណៈដែលស្ត្រីមានផ្ទៃពោះក្នុងក្រុម គ្រាប់ថ្នាំមីក្រូសារជាតិ នឹងទទួលបានគ្រាប់ថ្នាំ ១៨០ គ្រាប់។

លោកស្រី Selamawit Negash អ្នកឯកទេសសុខភាពនិងអាហារូបត្ថម្ភ នៃអង្គការយូនីសេហ្វ មានប្រសាសន៍ថា ៖ «យូនីសេហ្វ មានការគាំទ្រយ៉ាងខ្លាំងចំពោះគម្រោងសាកល្បង គ្រាប់ថ្នាំមីក្រូសារជាតិ ដោយសារតែគ្រាប់ថ្នាំនេះ ត្រូវបានផ្តល់អាទិភាពនៅក្នុងផែនទីផ្លូវជាតិសម្រាប់ពន្លឿនការលើកកំពស់អាហារូបត្ថម្ភនៅកម្ពុជា»។

លោកស្រីបានលើកឡើងឱ្យដឹងទៀតដែរថា កង្វះអាហារូបត្ថម្ភរបស់មាតា គឺជាកត្តាកំណត់ដ៏សំខាន់នៃលទ្ធផលនៃការមានផ្ទៃពោះមិនល្អ។ កង្វះអាហារូបត្ថម្ភរបស់មាតាមិនត្រឹមតែបង្កើនហានិភ័យនៃជំងឺមាតា និងមរណភាពប៉ុណ្ណោះទេ ថែមទាំងហានិភ័យនៃការផ្តល់កំណើតដល់ទារកដែលមានទំងន់ពីកំណើតទាប ដែលនាំឱ្យទារកស្ថិតក្នុងគន្លងនៃផលវិបាកអវិជ្ជមានរយៈពេលវែង រាប់ចាប់ពីការចុះខ្សោយនៃការលូតលាស់ និងការអភិវឌ្ឍន៍ក្នុងវ័យកុមារភាពរហូតដល់ពុំរ៉ៃ៕

# ៦ខែ រដ្ឋផាករថយន្តដឹកលើសទម្ងន់កម្រិតកំណត់១៦៤៣គ្រឿង

*អត្ថបទ៖ អមរិន្ទ ដានុត*

របាយការណ៍របស់គណៈកម្មាធិការសម្របសម្រួលអចិន្ត្រៃយ៍នៃគណៈកម្មាធិការដឹកនាំការត្រួតពិនិត្យយានយន្តដឹកជញ្ជូនលើសទម្ងន់កម្រិតកំណត់ បានឱ្យដឹងនៅថ្ងៃទី០៦ ខែកក្កដា នេះថា ក្នុងឆមាសទី១ ឆ្នាំ២០២២ រថយន្តដឹកលើសទម្ងន់កម្រិតកំណត់ដោយច្បាប់ចំនួន ១ ៦៤៣ គ្រឿង ត្រូវបានផាកពិន័យ។



របាយការណ៍ដដែលបានបន្តថា ក្នុងនោះ រថយន្តចំនួន២២០គ្រឿង ដែលដឹកលើសទម្ងន់កម្រិតកំណត់ លើសពី២០% នៃច្បាប់អនុញ្ញាតត្រូវបានពិន័យ និងឃាត់ទុកចំនួនមួយឆ្នាំ។

គណៈកម្មាធិការសម្របសម្រួលអចិន្ត្រៃយ៍នៃគណៈកម្មាធិការដឹកនាំការត្រួតពិនិត្យយានយន្តដឹកជញ្ជូនលើសទម្ងន់កម្រិតកំណត់នៃក្រសួងសាធារណៈការនិងដឹកជញ្ជូនបានបញ្ជាក់ថា ការអនុវត្តការងារលើការទប់ស្កាត់យានយន្តដឹកជញ្ជូនលើសទម្ងន់កម្រិតកំណត់ បានត្រួតពិនិត្យយានយន្តសរុបចំនួន ១ ៨៣១ ៣៧៤ គ្រឿង។

ក្នុងនោះរថយន្តដឹកមិនលើសទម្ងន់មានចំនួន ១ ២៣០ ០១០ គ្រឿងរថយន្តដឹកលើសទម្ងន់ក្នុងកម្រិតអនុគ្រោះ មានចំនួន ៥៩៩ ៧២១គ្រឿង រថយន្តដឹកលើសទម្ងន់កម្រិតកំណត់ដែលត្រូវបានផាកពិន័យមានចំនួន ១ ៦៤៣ គ្រឿង ពិន័យទឹកប្រាក់សរុបប្រមាណ ២,៨ ពាន់លានរៀល។

ក្នុងចំណោមរថយន្ត ១ ៦៤៣ គ្រឿង ដែលបានផាកពិន័យ មានរថយន្តចំនួន ២២០ គ្រឿង ដែលដឹកលើសទម្ងន់កម្រិតកំណត់ លើសពី២០% នៃទម្ងន់អនុញ្ញាតត្រូវផាកពិន័យ និងឃាត់ទុករយៈពេលមួយឆ្នាំ ដោយយោងតាមច្បាប់ផ្លូវថ្នល់មាត្រា ៦០ ។

គណៈកម្មាធិការនេះបានបញ្ជាក់ថា ៖ «ការដឹកលើសទម្ងន់កម្រិតកំណត់ជាកត្តាចម្បងធ្វើឱ្យផ្លូវឆាប់ខូចមុនអាយុកាល និងបង្កគ្រោះថ្នាក់ចរាចរណ៍ដល់អ្នកធ្វើដំណើរ»។

លោកទេសរដ្ឋមន្ត្រី ស៊ុន ចាន់ថុល រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន និងជាប្រធានគណៈកម្មាធិការដឹកនាំការត្រួតពិនិត្យយានយន្តដឹកជញ្ជូនលើសទម្ងន់កម្រិតកំណត់ បានអំពាវនាវដ៏ទទូចសុំឱ្យអ្នកប្រើប្រាស់ផ្លូវ និងក្រុមហ៊ុនដឹកទំនិញគោរពច្បាប់ ចរាចរណ៍ទាំងអស់គ្នា។

លោកថា ត្រូវកាត់បន្ថយគ្រោះថ្នាក់ចរាចរណ៍នៅតាមដងផ្លូវ កុំដឹកជញ្ជូនទំនិញលើសទម្ងន់កម្រិតកំណត់ធ្វើឱ្យផ្លូវឆាប់ខូចឆាប់ រេចរិលមុនអាយុកាល មានជង្ហុកសម្បុកមាន់ បង្កគ្រោះថ្នាក់ចរាចរណ៍ ចំណាយថវិកាច្រើនក្នុងការជួសជុល និងថែទាំផ្លូវ។

គ្រប់ក្រុមការងារពាក់ព័ន្ធ បានធ្វើការផ្សព្វផ្សាយអំពីបទដ្ឋានគតិយុត្តពាក់ព័ន្ធនានាដល់ម្ចាស់ក្រុមហ៊ុនដឹកជញ្ជូន ម្ចាស់រថយន្តធុនធ្ងន់ និងអ្នកបើកបររថយន្តធុនធ្ងន់ទាំងអស់ ជាពិសេសចុះអប់រំដល់ម្ចាស់ដេប៉ូខ្សាច់ថ្មី និងការដ្ឋានដឹកដីឱ្យចូលរួមគោរពតាមបទដ្ឋានបច្ចេកទេសស្តីពីការដឹកជញ្ជូន ដើម្បីបញ្ចៀសឱ្យបាននូវការដឹកលើសទម្ងន់ កម្រិតកំណត់ដែលនាំឱ្យផ្លូវឆាប់ខូច កាត់បន្ថយគ្រោះថ្នាក់ចរាចរណ៍។

ក្នុងទិសដៅបន្ទាប់គណៈកម្មាធិការសម្របសម្រួលអចិន្ត្រៃយ៍នឹងសិក្សាលទ្ធភាពសាងសង់ស្ថានីយជញ្ជីងបន្ថែមទៀតនៅតាមបណ្តារាជធានី-ខេត្ត និងផ្លូវជាតិសំខាន់ៗមួយចំនួន ព្រមទាំងបន្តការអប់រំផ្សព្វផ្សាយបទដ្ឋានគតិយុត្តនានាពាក់ព័ន្ធនឹងការដឹកលើសទម្ងន់កម្រិតកំណត់ដោយច្បាប់ ព្រមទាំងប្រើប្រាស់បច្ចេកវិទ្យា ដើម្បីភ្ជាប់ទិន្នន័យពីគ្រប់ស្ថានីយជញ្ជីងមកទីស្តីការក្រសួង៕

# តើជំងឺអុតស្វាមានរោគសញ្ញា និងការឆ្លងដោយរបៀបណាដែរ?

*អត្ថបទ៖ ,,,,*

កម្ពុជាត្រូវបានរកឃើញមានករណីជំងឺអុតស្វាលើកទី១ ទៅលើបុរសជនជាតិនីហ្សេរីយ៉ា អាយុ២៧ឆ្នាំ ដែលបានរត់គេចខ្លួនពីប្រទេសថៃចូលមកដល់កម្ពុជា និងត្រូវបានរកឃើញនិងបញ្ជូនទៅព្យាបាលនៅមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀតនាយប់ថ្ងៃទី២៣ ខែកក្កដាកន្លងទៅនេះ។






លោកស្រី ឱ វណ្ណឌីន រដ្ឋលេខាធិការក្រសួងសុខាភិបាល បានឱ្យដឹងថា ស្ថានភាពអ្នកជំងឺអុតស្វាជនជាតិនីហ្សេរីយ៉ារូបនេះធម្មតាមិនមានអ្វីធ្ងន់ធ្ងរនោះទេ ហើយគាត់ត្រូវបានមើលថែទាំ និងព្យាបាលយ៉ាងយកចិត្តទុកដាក់លើអ្នកជំងឺនេះផងដែរ។

លោកស្រីមានប្រសាសន៍ថា ៖ «ចំណែកអ្នកពាក់ព័ន្ធចំនួន៥នាក់ មិនទាន់មានរោគសញ្ញាណាមួយបង្ហាញថាពួកគាត់ឆ្លងជំងឺនេះនៅឡើយទេ ប៉ុន្តែពួកគាត់ត្រូវបានបន្តតាមដានសុខភាពជាបន្តទៀត»។

### តើជំងឺនេះមានរោគសញ្ញាយ៉ាងដែរ?

យោងតាមក្រសួងសុខាភិបាលបានឱ្យដឹងថា រោគសញ្ញាមួយចំនួននៃជំងឺអុតស្វាមានដូចជា ចេញកន្ទួលរមាស់បែបពងទឹកនៅលើដងខ្លួន បាតដៃ បាតជើង និងផ្ទៃមុខ អមដោយរោគសញ្ញាក្តៅខ្លួនលើសពី ៣៨,៥ អង្សាសេ និងមានឈឺក្បាល ហើមកូនកណ្តុរ ឈឺសាច់ដុំ និងខ្លួនប្រាណ ឈឺចង្កេះ អស់កម្លាំងខ្លាំង រួមជាមួយនឹងប្រវត្តិធ្វើដំណើរទៅកន្លែង ដែលមានកើតជំងឺអុតស្វា។

ការធ្វើតេស្តរកមេរោគអុតស្វានេះ មន្ត្រីសុខាភិបាលត្រូវធ្វើតេស្តវិភាគនៅមន្ទីរពិសោធន៍ដោយយកវត្ថុសំណាកដំបៅនៅលើដងខ្លួនអ្នកសង្ស័យ ឬអ្នកឈឺតាមលក្ខណៈបច្ចេកទេសត្រឹមត្រូវ ហើយបញ្ជូនទៅធ្វើវិភាគនៅមន្ទីពិសោធន៍នៃវិទ្យាស្ថានសុខភាពសាធារណៈ ឬវិទ្យាស្ថានប៉ាស្ទ័រកម្ពុជា។

ក្រសួងបានបន្តថា អ្នកដែលមានការសង្ស័យឬអ្នកដែលកើតជំងឺអុតស្វា ត្រូវដាក់ឱ្យនៅដាច់ដោយឡែក ដែលត្រូវធ្វើរហូតដល់អ្នកជំងឺបានព្យាបាលជាសះស្បើយ ឬមានការបញ្ជាក់ពីមន្ទីរពិសោធន៍នូវលទ្ធផលអវិជ្ជមានវីរុសអុតស្វានេះ។

ប្រភពដដែលបានបន្តឱ្យដឹងទៀតថា ត្រូវសាកសួរដល់អ្នកដែលនៅជុំវិញជាពិសេសក្រុមគ្រួសារ ឬសាច់ញាតិ ឬអ្នកប៉ះពាល់ផ្សេងៗ ដើម្បីតាមដានរកអ្នកឆ្លងបន្តគ្នា។

### ការការពារការឆ្លងពីជំងឺអុតស្វា

តាមកែណែនាំរបស់ក្រសួងសុខាភិបាលបានលើកឡើងថា ប្រជាពលរដ្ឋទាំងអស់ត្រូវអនុវត្តអនាម័យខ្លួនប្រាណ និងរស់នៅស្អាត ដោយធ្វើអនាម័យដៃស្អាតដោយសម្អាតជាមួយសាប៊ូឬជែល អាល់កុល និងអនុវត្តការការពារការចម្លងតាមផ្លូវដង្ហើម។

ត្រូវជៀសវាងការប៉ះពាល់ដោយផ្ទាល់ជាមួយអ្នកដែលមានជំងឺនេះ ឬបុគ្គលដែលសង្ស័យ រួមទាំងការរួមភេទ ជាពិសេសការប៉ះពាល់ស្បែកផ្ទាល់របស់អ្នកជំងឺ, កន្លែងដែលមានចេញពងទឹកបែក, វត្ថុរាវរបស់អ្នកជំងឺ។

ក្រសួងសុខាភិបាលបានបន្តថា ត្រូវចៀសវាងប៉ះពាល់សម្ភារៈប្រើប្រាស់របស់អ្នកជំងឺ ឬបុគ្គលដែលសង្ស័យ ដូចជាសម្លៀកបំពាក់ ពូក ខ្នើយ ចាន ស្លាបព្រា កែវទឹក ជាដើម ហើយត្រូវបោកគក់ ឬលាងសម្អាតឱ្យបានត្រឹមត្រូវនូវសម្ភារៈប្រើប្រាស់របស់បុគ្គលនេះ ដោយឡែក។

បុគ្គលសង្ស័យដែលមិនមានរោគសញ្ញា មិនត្រូវដាក់ធ្វើចត្តាឡីស័កទេ ហើយអាចធ្វើការងារជាធម្មតា គ្រាន់តែមានការប្រុងប្រយ័ត្ន ដោយមិនត្រូវមានការប៉ះពាល់អ្នកដទៃក្នុងអំឡុងពេលធ្វើការតាមដានសុខភាពរយៈពេល ២១ថ្ងៃបន្ទាប់ពីបានប៉ះពាល់ជាមួយអ្នកឈឺជំងឺអុតស្វានេះ។

ក្រសួងបានបញ្ជាក់ទៀតថា ៖ «ត្រូវបរិភោគចំណីអាហារដែលឆ្អិនល្អ និងរក្សាអនាម័យចំណីអាហារទាំងការចម្អិនអាហារឱ្យបានល្អ»។

## រោគសញ្ញានិងអាការៈជំងឺអុតស្វា

ចំពោះមនុស្ស រោគសញ្ញានៃជំងឺអុតស្វាគឺស្រដៀងនឹងជំងឺអុតស្វាយ ប៉ុន្តែស្រាលជាងរោគសញ្ញានៃជំងឺអុតស្វាយ។ ជំងឺអុតស្វា ចាប់ផ្តើមដោយមានអាការៈគ្រុនក្តៅ ឈឺក្បាល ឈឺសាច់ដុំ និងអស់កម្លាំង។ ភាពខុសគ្នាចម្បងរវាងរោគសញ្ញានៃជំងឺអុតស្វា និងជំងឺអុតស្វាយគឺថា ជំងឺអុតស្វាធ្វើឱ្យមានហើមកូនកណ្តុរ ចំណែកឯជំងឺអុតស្វាយមិនមានរោគសញ្ញានេះនោះឡើយ។ រយៈពេលបង្ករោគ (ពេលវេលាចន្លោះពីការឆ្លងមេរោគដល់ការចេញរោគសញ្ញា) សម្រាប់ជំងឺអុតស្វាជាធម្មតាមានចន្លោះពី ៧ ទៅ ១៤ ថ្ងៃ ប៉ុន្តែក៏អាចមានចាប់ពី ៥ ទៅ ២១ ថ្ងៃផងដែរ។




រោគសញ្ញាដំបូងរួមមាន៖

- គ្រុនក្តៅ
- ឈឺក្បាល
- ឈឺសាច់ដុំ
- ឈឺខ្នង
- ហើមកូនកណ្តុរ
- រងារញាក់
- ហត់នឿយ
- ស្បែកឡើងកន្ទួល

កន្ទួលដែលមានខ្ទុះអាចបង្ករជាដំបៅ អាចកើតឡើងតាមដំណាក់កាលដូចខាងក្រោម៖

- ស្នាមអុច
- កន្ទួលរឹង
- ពងមានទឹក
- ពងខ្ទុះ
- ពងបែក

**១១៥**

(+៨៥៥) ១២ ៨២៥ ៤២៤
(+៨៥៥) ១២ ៤៨៨ ៩៨១
(+៨៥៥) ១២ ៨៣៦ ៨៦៨

# ថវិកា ៧៤៤ លានដុល្លារ ជួយដល់គ្រួសារក្រីក្រ និងងាយរងគ្រោះដោយជំងឺកូវីដ-១៩ ក្នុងរយៈពេល២៥ខែ

*អត្ថបទ៖ អមរិន្ទ ដានុត*

កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារក្រីក្រ និងងាយរងគ្រោះ ក្នុងអំឡុងពេលប្រយុទ្ធនឹងជំងឺកូវីដ-១៩ បានអនុវត្តបានរយៈពេលចំនួន ២៥ខែកន្លងមក ដោយបានចំណាយថវិកាសរុបប្រមាណ ៧៤៤ លានដុល្លារ ទៅដល់គ្រួសារក្រីក្រ និងងាយរងគ្រោះដែលមានបណ្ណសមធម៌ប្រមាណជាង ៦៨ ម៉ឺនគ្រួសារ ដោយទទួលបានការសាទរពីអ្នកទទួលផល ដៃគូអភិវឌ្ឍន៍, អង្គការសង្គមស៊ីវិលជាតិ-អន្តរជាតិ និងប្រជាពលរដ្ឋទូទៅ។

យោងតាមសេចក្តីប្រកាសព័ត៌មានរួមគ្នាស្តីពីពិធីសម្ពោធ និងផ្សព្វផ្សាយរបាយការណ៍វាយតម្លៃការអនុវត្ត «កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារក្រីក្រ និងងាយរងគ្រោះក្នុងអំឡុងពេលប្រយុទ្ធនឹងជំងឺកូវីដ-១៩» នាថ្ងៃទី២៧ ខែកក្កដា បានឱ្យដឹងថា កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារក្រីក្រ និងងាយរងគ្រោះ ក្នុងអំឡុងពេលប្រយុទ្ធនឹងជំងឺកូវីដ-១៩ ត្រូវបានដាក់ឱ្យដំណើរការកាលពីថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០២០ ។

ក្រុមប្រឹក្សាជាតិគាំពារសង្គម និងកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ (UNDP) ប្រចាំកម្ពុជា បានសហការរៀបចំការវាយតម្លៃបច្ច័យសង្គម-សេដ្ឋកិច្ចនៃការអនុវត្តកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារក្រីក្រ និងងាយរងគ្រោះ ក្នុងអំឡុងពេលប្រយុទ្ធនឹងជំងឺកូវីដ-១៩ នៅឆ្នាំ២០២០ និង២០២១ ដោយមានការគាំទ្រពីរដ្ឋាភិបាលអូស្ត្រាលី ក្នុងគោលបំណងស្វែងយល់ពីប្រសិទ្ធភាព និងបច្ច័យដែលកើតចេញពីការអនុវត្តកម្មវិធី ទាំងនៅកម្រិតមីក្រូ (ក្នុងកម្រិតគ្រួសារ) និងកម្រិតម៉ាក្រូ (បច្ច័យលើសេដ្ឋកិច្ច) ដែលជាធាតុចូលដ៏សំខាន់ក្នុងការរៀបចំជម្រើសគោលនយោបាយសម្រាប់ការគិតគូរកសាងប្រព័ន្ធគាំពារសង្គមកម្ពុជា។

លទ្ធផលនៃការវាយតម្លៃនេះ បង្ហាញថា ៖ «កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារក្រីក្រ និងងាយរងគ្រោះ ក្នុងអំឡុងពេលប្រយុទ្ធនឹងជំងឺកូវីដ-១៩ បានផ្តល់ផលវិជ្ជមានជាច្រើន។ កម្មវិធីនេះ បានចូលរួមចំណែកសម្រួ លជីវភាពរបស់គ្រួសារក្រីក្រឱ្យរួចផុតពីការធ្លាក់ចូលទៅក្នុងបញ្ហាអសន្តិសុខស្បៀង បំណុល, ការលក់ទ្រព្យសកម្មរបស់គ្រួសារ និងបានសម្រួលបន្ទុកចំណាយរបស់គ្រួសារ ពិសេសចំណាយលើម្ហូបអាហារ, ថ្នាំសង្កូវ និងការអប់រំកូនចៅ»។

ចំពោះបច្ច័យលើផ្នែកម៉ាក្រូសេដ្ឋកិច្ច, កម្មវិធីនេះបានចូលរួមដល់កំណើនសេដ្ឋកិច្ចប្រមាណ ០,៥៥% ក្នុងឆ្នាំ២០២០ និង ០,៥ % ក្នុងឆ្នាំ២០២១។ មិនតែប៉ុណ្ណោះ កម្មវិធីនេះ ក៏បានរួមចំណែកក្នុងការកាត់បន្ថយអត្រានិកម្មភាពចំនួន ០.៥៧% ក្នុងឆ្នាំ ២០២០ និង ០.៦២% ក្នុងឆ្នាំ២០២១ និងកាត់បន្ថយអត្រាភាពក្រីក្របានប្រមាណ ២,៧% ក្នុងឆ្នាំ២០២០ និង ៣,៤ % ក្នុងឆ្នាំ២០២១ ។

លោក ផាន់ ផល្លា រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានថ្លែងឱ្យដឹងថា ៖ «កម្មវិធីឧបត្ថម្ភសាច់ប្រាក់នេះ ជាផ្នែកមួយដ៏សំខាន់នៃអន្តរាគមន៍ ដែលបានដាក់ចេញដោយរាជរដ្ឋាភិបាលកម្ពុជា ក្រោមស្មារតីបុរេសកម្ម ជាក់ស្តែងនិយម និងការឆ្លើយតបខ្ពស់ ក្នុងការផ្តល់កិច្ចគាំពារ ដល់គ្រួសារក្រីក្រ និងងាយរងគ្រោះ ពីផលប៉ះពាល់នៃជំងឺរាតត្បាតជាសាកលមួយនេះ»។







> កម្មវិធីឧបត្ថម្ភសាច់ប្រាក់នេះ ជាផ្នែកមួយដ៏សំខាន់នៃអន្តរាគមន៍ ដែលបានដាក់ចេញដោយរាជរដ្ឋាភិបាលកម្ពុជា ក្រោមស្មារតីបុរេសកម្ម ជាក់ស្តែងនិយម និងការឆ្លើយតបខ្ពស់ ក្នុងការផ្តល់កិច្ចគាំពារ ដល់គ្រួសារក្រីក្រ និងងាយរងគ្រោះ ពីផលប៉ះពាល់នៃជំងឺរាតត្បាតជាសាកលមួយនេះ

លោកថា លទ្ធផលនៃការវាយតម្លៃនេះ មិនត្រឹមតែបានបង្ហាញពីប្រសិទ្ធភាព និងតម្លាភាពនៃការអនុវត្តកម្មវិធីប៉ុណ្ណោះទេ ថែមទាំងបានបង្ហាញឱ្យឃើញកាន់តែច្បាស់ពីតួនាទីនៃអន្តរាគមន៍ផ្នែកជំនួយសង្គម ដែលបានជួយសម្រួលជីវភាពរបស់ប្រជាពលរដ្ឋ និងជំរុញកំណើនសេដ្ឋកិច្ចផងដែរ។

ចំណែក នាយិការង UNDP លោកស្រី Sonali Dayaratne បានលើកឡើងថា របាយការណ៍វាយតម្លៃនេះ បានបង្ហាញអំពីភស្តុតាងដែលមានលក្ខណៈវិទ្យាសាស្ត្រ ដែលជាមូលដ្ឋានរឹងមាំ ក្នុងការគិតគូរវិនិយោគបន្ថែមលើប្រព័ន្ធគាំពារសង្គម ដែលនឹងអាចផ្តល់ការគាំទ្រយ៉ាងមានប្រសិទ្ធភាពសម្រាប់គ្រួសារក្រីក្រ និងងាយរងគ្រោះ ដែលទទួលរងនូវផលប៉ះពាល់ និងធានាថាគ្មានអ្នកណាម្នាក់ត្រូវបានបោះបង់ចោល នោះឡើយ។

លោកស្រីមានប្រសាសន៍ថា ៖ «ការវាយតម្លៃនេះ អនុញ្ញាតឱ្យយើងយល់ និងមើលឃើញកាន់តែច្បាស់អំពីប្រសិទ្ធភាព និងបច្ច័យរបស់កម្មវិធីលើជីវភាពរបស់គ្រួសារក្រីក្រ និងងាយរងគ្រោះក៏ដូចជាម៉ាក្រូសេដ្ឋកិច្ច»។

ជាមួយគ្នានោះដែរ លោកស្រី Benita Chudleigh លេខាទីមួយនៃស្ថានទូតអូស្ត្រាលីប្រចាំកម្ពុជា មានប្រសាសន៍ដែរថា ក្នុងនាមជាមិត្តរបស់កម្ពុជា ប្រទេសអូស្ត្រាលីប្តេជ្ញាសហការជាមួយដៃគូនានា ដើម្បីរិះរកវិធីលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋកម្ពុជា។

លោកស្រីបញ្ជាក់ថា ៖ «យើងសូមអបអរសាទរដល់រាជរដ្ឋាភិបាលកម្ពុជា ដែលបានប្រើប្រាស់ប្រព័ន្ធទិន្នន័យអត្តសញ្ញាណកម្មគ្រួសារក្រីក្រ (IDPoor) ដែលរដ្ឋាភិបាលអូស្ត្រាលីបានផ្តល់ការគាំទ្រក្នុងទសវត្សរ៍កន្លងមកនេះ ដើម្បីកំណត់អត្តសញ្ញាណប្រជាជនដែលជួបការខ្វះខាតបំផុត ធ្វើជាក្រុមគោលដៅនៃកម្មវិធីឧបត្ថម្ភសាច់ប្រាក់នេះ»៕

# យុទ្ធនាការអន្ទាក់សូន្យត្រូវបានប្រកាសចាប់ផ្តើម បន្តក្នុងទឹកដីខេត្តមណ្ឌលគិរី ដែលជាខេត្តទី៤









*អត្ថបទ៖ អមរិន្ទ ដានុត*

យុទ្ធនាការជាតិសំដៅលើកកម្ពស់ការយល់ដឹងស្តីពីផលប៉ះពាល់នៃការប្រើប្រាស់អន្ទាក់សត្វខុស ច្បាប់ ត្រូវបានប្រកាសចាប់ផ្តើមនាថ្ងៃទី២៩ ខែកក្កដា នេះនៅក្នុងទឹកដីខេត្តមណ្ឌលគិរី ដែលជាខេត្តទី៤ នៃតំបន់ភាគខាងកើតទន្លេមេគង្គដែលបានចូលរួមរៀបចំយុទ្ធនាការអន្ទាក់សូន្យក្នុងតំបន់ការ ពារធម្មជាតិនេះ។

ខេត្តមណ្ឌលគីរីគឺជាខេត្តទី៤ នៃតំបន់ភាគខាងកើតទន្លេមេគង្គដែលបានចូលរួមរៀបចំយុទ្ធនាការអន្ទាក់សូន្យក្នុងតំបន់ការ ពារធម្មជាតិដើម្បីបញ្ឈប់ការដាក់អន្ទាក់ និងការបរបាញ់សត្វព្រៃដោយខុសច្បាប់ និងធ្វើឱ្យតំបន់ការពារធម្មជាតិកាន់តែមានសុវត្ថិភាពសម្រាប់ជីវៈ ចម្រុះគ្រប់ប្រភេទ និងសម្រាប់មនុស្ស។

លោក នេត្រ ភក្ត្រា រដ្ឋលេខាធិការក្រសួងបរិស្ថានបានឱ្យដឹងថា ស្ថានភាពដ៏អាក្រក់នៃការធ្លាក់ចុះជីវៈចម្រុះមិនបាន កើតឡើង តែក្នុងប្រទេសកម្ពុជានោះទេ គឺចំនួនសត្វព្រៃនៅលើសកលលោកទាំងសត្វរស់នៅលើដីនិងក្នុងទឹក ក៏បានធ្លាក់ចុះខ្លាំងបំផុតរហូតដល់ ៦៨% ជាមធ្យម ក្នុងរយៈពេល ៥០ ឆ្នាំចុងក្រោយនេះ បើគិតចាប់តាំងពីឆ្នាំ១៩៧០ មក។

លោកបានបន្តថា ការបរបាញ់ខុសច្បាប់ចាប់តាំងពីអតីតកាលមកដល់ពេល បច្ចុប្បន្នរួមផ្សំនឹងបរិមាណអន្ទាក់បានដាក់ជាច្រើនក្នុងព្រៃធម្មជាតិ ជាកត្តាជំរុញ ដោយការជួញដូរសត្វព្រៃខុសច្បាប់ សុទ្ធសឹងជាមូលហេតុចម្បងៗ ដែលបណ្តាលឱ្យសត្វព្រៃនៅកម្ពុជាប្រឈមមុខនឹងការបាត់បង់។ អន្ទាក់ជាឃាតកលាក់មុខ និងជាកត្តាគំរាមកំហែងដ៏ចម្បងមួយចំពោះសត្វព្រៃ។

លោក នេត្រ ភក្ត្រា បានបញ្ជាក់ថា៖ «នេះជាពេលវេលាមួយដែលយើងទាំងអស់គ្នាត្រូវ រួមសហការគ្នាចាត់វិធានល់ ការអភិរក្សបន្ទាន់និងប្រកបដោយភាពច្នៃប្រឌិតដើម្បីចូលរួមទប់ស្កាត់កត្តាគំរាមកំហែងចម្បងៗទាំងនេះជាពិសេសពីកត្តាអន្ទាក់»។

យុទ្ធនាការនេះត្រូវបានប្រកាសចាប់ផ្តើមនៅក្នុងបណ្តាខេត្តជាច្រើន រួមទាំងខេត្តមណ្ឌលគិរីផងដែរ ដែលបានផ្តោតលើការប្រើប្រាស់វិធីសាស្ត្រប្រព័ន្ធ ទីផ្សារមានមេត្រីភាពចំពោះការអភិរក្សដើម្បីដោះស្រាយចំពោះវិបត្តិអន្ទាក់ និងការគំរាមកំហែងផ្សេងៗទៀតដែលប៉ះពាល់ដល់តំបន់ការពារធម្មជាតិ និងជីវចម្រុះរបស់ប្រទេសកម្ពុជា។

នាយកស្តីទីនៃការិយាល័យកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាពនៃទីភ្នាក់ងារ USAID ប្រចាំប្រទេសកម្ពុជា អ្នកនាង Andrea Pavlick បានលើកឡើងដែរថា៖ «សត្វព្រៃគឺជាផ្នែកមួយដ៏សំខាន់នៃបេតិកភណ្ឌជាតិរបស់ប្រទេសកម្ពុជា ហើយក៏ជាផ្នែកដ៏សំខាន់មួយនៃការអភិវឌ្ឍន៍ដែលផ្តល់អត្ថប្រយោជន៍ទាំងសេដ្ឋកិច្ចជាតិ និងជីវភាពរស់នៅរបស់ប្រជាជន»។

អ្នកនាងបានបន្តថា សហគ្រាស និងខ្សែប្រវាក់តម្លៃដែលរួមបញ្ចូលវិស័យអេកូ ទេសចរណ៍ធម្មជាតិការកាត់បន្ថយការបំភាយឧស្ម័នដែលបណ្តាលមកពីការបាត់បង់ និងរេចរឹលព្រៃឈើ (REDD+) និងរបស់ប្រើប្រាស់ដែលមានមេត្រីភាពចំពោះការអភិរក្ស ពិតជាអាចផ្តល់នូវការជំរុញទឹកចិត្តដ៏មានឥទ្ធិពលដើម្បីដោះស្រាយវិបត្តិអន្ទាក់ និងការគំរាមកំហែងផ្សេងៗទៀតដល់ជីវ ចម្រុះរបស់ប្រទេសកម្ពុជា។

ចំណែក លោក ញ៉ែម សុផន ប្រធានគ្រប់គ្រងគម្រោងកែវសីមា នៃអង្គការ WCS Cambodia បានថ្លែងថា៖ «ការគំរាមកំហែងដ៏ធំចំពោះពពួកសត្វព្រៃ នៅក្នុងតំបន់ការពារធម្មជាតិ គឺការបរបាញ់ដោយមិនរើសមុខ ជាពិសេសតាមរយៈការប្រើប្រាស់អន្ទាក់លួស»។

អង្គការ WCS Cambodia ដោយមានកិច្ចសហការជាមួយក្រសួងបរិស្ថាន និងសហគមន៍មូលដ្ឋាន ប្តេជ្ញាពង្រឹងវិធីសាស្ត្រ និងធនធានជាយុទ្ធសាស្ត្រ ដើម្បីប្រយុទ្ធប្រឆាំងនឹងការដាក់អន្ទាក់សត្វខុសច្បាប់នៅក្នុងដែនជម្រកសត្វព្រៃកែវសីមានៃខេត្តមណ្ឌលគិរី។

ជាមួយគ្នានោះដែរ លោក សេង ទៀក ដែលជានាយកអង្គការ WWF បានឱ្យដឹងដែរថា ស្របគ្នានេះ វិធានការរួម និងការពង្រឹងការអនុវត្តច្បាប់ដ៏តឹងរឹង គឺជាការចាំបាច់បំផុត ដើម្បីបញ្ឈប់តម្រូវការសាច់សត្វព្រៃ និងបិទចោលនូវរាល់ទីផ្សារលក់ដូរសត្វព្រៃគ្រប់ប្រភេទ។

លោកបានបន្តថា៖ «មធ្យោបាយសំខាន់ក្នុងការដោះ ស្រាយបញ្ហាឫសគល់នៃការបរបាញ់និងការជួញដូរសត្វព្រៃ គឺដើម្បីធានាថាប្រជាជនរស់នៅក្នុង និងនៅខាងក្រៅតំបន់ការពារធម្មជាតិអាចចូលរួម យ៉ាងជិតស្និទ្ធ ក្នុងការអភិរក្សសត្វព្រៃដំណោះស្រាយផ្អែកលើមូលដ្ឋានធម្មជាតិ និងការអភិវឌ្ឍសេដ្ឋកិច្ចប្រកបដោយចីរភាព»។

> ❝នេះជាពេលវេលាមួយដែលយើងទាំងអស់គ្នាត្រូវ រួមសហការគ្នាចាត់វិធានល់ ការអភិរក្សបន្ទាន់និងប្រកបដោយភាពច្នៃប្រឌិតដើម្បីចូលរួមទប់ស្កាត់កត្តាគំរាមកំហែងចម្បងៗទាំងនេះជាពិសេសពីកត្តាអន្ទាក់❞

ចាប់ពីខែមករា ដល់ខែមិថុនា ឆ្នាំ២០២២ យ៉ាងហោច ណាស់អន្ទាក់ចំនួន ៥០០ ត្រូវបានរឹបអូសនិងប្រមូលដកចេញពីដែនជម្រកសត្វព្រៃលំផាត់ដោយមន្ត្រីឧទ្យានុរក្ស និងប្រជាសហគមន៍ ក្រោមកិច្ចគាំទ្រពីអង្គការ NatureLife Cambodia ខណៈដែលមន្ត្រីឧទ្យានុរក្សបានអន្តរាគមន៍ករណីឧក្រិដ្ឋកម្មសត្វព្រៃចំនួន ១៣ ករណីដាច់ដោយឡែកពីគ្នា។ នេះបើតាម លោក វ៉ូ វរសក្ស នាយកប្រតិបត្តិនៃអង្គការ NatureLife Cambodia។

លោកបានបន្តថា៖ «នេះបង្ហាញថា អន្ទាក់នៅតែជាការគំរាមកំហែងចម្បងដល់សត្វព្រៃរបស់យើង។ យើងសូមទទូចដល់អាជ្ញាធរពាក់ព័ន្ធឲ្យបង្ក្រាបការជួញដូរសាច់ សត្វព្រៃខុសច្បាប់នៅតាមទីផ្សារ និងភោជនីយដ្ឋាននានា។ យើងរួមគ្នាការពារសត្វព្រៃរបស់យើង»។

លោកស្រី ហ៊ូ កល្យាណ នាយិកាអង្គការវីខូហ្វ ប្រចាំប្រទេសកម្ពុជា បានលើកឡើងថា៖ «មនុស្សគឺជាផ្នែកនៃបញ្ហា ហើយក៏ជាផ្នែកនៃដំណោះ ស្រាយចំពោះបញ្ហាដែលយើងឃើញសព្វថ្ងៃនេះទាក់ទងនឹងការជួញដូរសត្វព្រៃខុសច្បាប់»។

ទន្ទឹមនឹងនេះដែរ លោក ទុយ សេរីវឌ្ឍនា នាយកកម្មវិធីនៃអង្គការ Wild Earth Allles Cambodia បានប្រាប់ដែរថា ប្រទេសកម្ពុជាត្រូវបានគេស្គាល់ថា ជាប្រទេសសម្បូរទៅដោយជីវចម្រុះច្រើននៅក្នុងចំណោមប្រទេសនៃតំបន់អាស៊ីអាគ្នេយ៍។ ជីវចម្រុះមួយចំនួននៅក្នុងប្រទេសកម្ពុជា ត្រូវទទួលរង សម្ពាធពីការគំរាមកំហែងផ្សេង។

គួរបញ្ជាក់ថា យុទ្ធនាការអន្ទាក់សូន្យត្រូវបានប្រកាសបើកជាផ្លូវការកាលពីខែមីនា ឆ្នាំ២០២២ កន្លងទៅនេះក្នុងខេត្តស្ទឹងត្រែង ព្រះវិហារ និងក្រចេះ ហើយកំពុងត្រូវបានប្រកាសបើកក្នុងខេត្តមណ្ឌលគិរី រួចនឹងឈានទៅប្រកាសបើកក្នុងខេត្តកំពង់ធំ និងខេត្តរតនគិរីជាបន្តបន្ទាប់ ដោយការបិទបញ្ចប់ត្រូវបានគ្រោងសម្រាប់ខែតុលា ឆ្នាំ២០២២ ខាងមុខ៕

# មន្ត្រីរដ្ឋាភិបាលថា៖ ការធ្លាក់ចុះនៃចំណាត់ថ្នាក់របស់កម្ពុជាលើការជួញដូរមនុស្ស អាមេរិកក៏ជាអ្នករួមចំណែកក្នុងការទទួលខុសត្រូវដែរ

*អត្ថបទ៖ ផល សុផានិត*

មន្ត្រីជាន់ខ្ពស់នៃក្រសួងមហាផ្ទៃ បានលើកឡើងថា ប្រសិនបើប្រទេសកម្ពុជាធ្លាក់ចំណាត់ថ្នាក់នៃការប្រយុទ្ធប្រឆាំងនឹងការជួញដូរមនុស្សនោះ សហរដ្ឋអាមេរិកក៏ជាអ្នករួមចំណែកទទួលខុសត្រូវលើបញ្ហា ដោយសារតែសហរដ្ឋអាមេរិកបានប្ដេជ្ញាចិត្តធ្វើការងារនិងជួយយ៉ាងជិតស្និតជាមួយរាជរដ្ឋាភិបាលកម្ពុជា ជាពិសេសក្រសួងមហាផ្ទៃលើកិច្ចការងារនេះ។





លោកស្រី ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍នៃគណៈកម្មាធិការជាតិប្រយុទ្ធនឹងការជួញដូរមនុស្ស បានថ្លែងដូចនេះនារសៀលថ្ងៃទី ២១ ខែកក្កដានេះ ដោយលោកស្រីបញ្ជាក់ថា កម្ពុជាបានប្ដេជ្ញាចិត្តខ្ពស់ទាក់ទងនឹងការអនុវត្តយុទ្ធសាស្ត្រទាំង៤ពីការប្រយុទ្ធប្រឆាំងការជួញដូរមនុស្សរបស់គណៈកម្មាធិការជាតិ។

លោកស្រីថា ៖ «ក្នុងនោះមានទាំង ការបង្ការទប់ស្កាត់ មានទាំងការអនុវត្តច្បាប់ កិច្ចការយុត្តិធម៌ យើងមានទាំងកិច្ចការពារជនរងគ្រោះ និងកិច្ចសហប្រតិបត្តិការអន្តរជាតិ»។



រដ្ឋលេខាធិការរូបនេះបានបន្តទៀតថា ការបង្ក្រាបបទល្មើសការជួញដូរមនុស្ស កម្ពុជាបានសម្រេចគោលដៅច្រើន ហើយប្រព័ន្ធយុត្តិធម៌មានការកែទម្រង់។ កម្ពុជាមានការពន្លឿនការដោះស្រាយសំណុំរឿងពាក់ព័ន្ធនិងការជួញដូរមនុស្ស បានលឿននិងប្រសើរ។

លោកស្រី ជូ ប៊ុនអេង មានប្រសាសន៍ថា ៖ «យើងតែងតែសង្ឃឹមថាឆ្នាំនេះយើងនឹងទទួលបានចំណាត់ថ្នាក់ល្អ យើងមានកិច្ចសហការពីស្ថានទូតសហរដ្ឋអាមេរិកប្រចាំកម្ពុជា ដែលកន្លងមកយើងនឹងធ្វើការជិតស្និតជាមួយគ្នា រហូតដល់មានដាក់ការិយាល័យ FBI ជាមួយនិងអគ្គស្នងការដ្ឋាននគរបាលជាតិ មានអ្នកធ្វើសេចក្ដីរាយការណ៍មកធ្វើការជាមួយយើង»។



លោកស្រីបន្តថា ៖ «ហើយចុះទៅយកព័ត៌មានខ្លួនឯងដោយផ្ទាល់ នៅថ្នាក់ក្រោមជាតិ រួមបូកសរុបរបាយការណ៍ ដែលម្នាក់ៗតែងតែនិយាយថាវិជ្ជមានខ្លាំងណាស់ ប៉ុន្តែផ្ទុយទៅវិញបែរជាមានចំណាត់ថ្នាក់លេខបី ដែលជាចំណាត់ថ្នាក់ទាបបំផុត វាស្មើរនឹងយើងមិនបានធ្វើអ្វីសោះ»។

សហរដ្ឋអាមេរិកបានដាក់ចំណាត់ថ្នាក់កម្ពុជាអស់រយៈពេលពីរឆ្នាំមកហើយ ខណៈចំណាត់ថ្នាក់លេខពីរនេះ ជាប្រទេសដែលមានការខិតខំប្រឹងប្រែង ឆ្លើយតបភាពចន្លោះប្រហោង ដែលត្រូវបំពេញបន្ថែមនៅក្នុងកិច្ចការប្រយុទ្ធប្រឆាំងការជួញដូរមនុស្សនេះ។ ប៉ុន្តែសម្រាប់ឆ្នាំ២០២២នេះវិញដែលសហរដ្ឋអាមេរិកសម្រេចដាក់ប្រទេសកម្ពុជា ក្នុងចំណាត់ថ្នាក់លេខ៣ បានន័យថាកម្ពុជាមានភាពព្រងើយកន្តើយ គ្មានការយកចិត្តទុកដាក់ គ្មានការខ្វាយខ្វល់ ចំពោះកិច្ចការប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស រហូតអាចសម្រេចដាក់ទណ្ឌកម្មដល់ប្រទេសកម្ពុជា។ នេះបើតាមការបញ្ជាក់បន្ថែមរបស់លោកស្រី ជូ ប៊ុនអេង។

កាលពីថ្ងៃទី១៩ ខែកក្កដាកន្លងទៅថ្មីៗនេះ ក្រសួងការបរទេសអាម៉េរិកទទួលបន្ទុកប្រយុទ្ធប្រឆាំងនឹងការជួញដូរមនុស្ស បានដាក់ប្រទេសវៀតណាម កម្ពុជា ប្រ៊ុយណេ និងម៉ាកាវ ក្នុងបញ្ជីខ្មៅជួញដូរមនុស្ស ដោយរាប់ប្រទេសម៉ាឡេស៊ីផងដែរ ដោយចោទប្រកាន់ថា ប្រទេសទាំងនេះ មិនប្រឹងប្រែងក្នុងការបញ្ឈប់ការងារផ្លូវភេទដោយបង្ខំ ឬជួយពលករចំណាកស្រុក។

លោកស្រី Kari Johnstone មន្ត្រីជាន់ខ្ពស់នៃក្រសួងការបរទេសទទួលបន្ទុកប្រយុទ្ធប្រឆាំងនឹងការជួញដូរមនុស្សបាននិយាយថា រដ្ឋាភិបាលអាស៊ីជាច្រើនត្រូវបានទម្លាក់ដំណែងដោយសារពួកគេធ្លាប់ ស្ថិតនៅក្នុងបញ្ជីឃ្លាំមើលកាលពីមុន ហើយមិនបានបង្ហាញពីសកម្មភាព ដែលបញ្ឈប់ការជួញដូរមនុស្ស នោះឡើយ។

អ្នកស្រី Kari Johnstone បានប្រាប់អ្នកសារព័ត៌មានថា ៖ «ប៉ុន្តែមានប្រទេសមួយចំនួននៅឆ្នាំនេះ នៅក្នុងតំបន់អាស៊ីមិនបានខិតខំប្រឹងប្រែងក្នុងការបញ្ឈប់ការងារផ្លូវភេទដោយបង្ខំ ឬជួយពលករចំណាកស្រុក នោះទេ»។

ការដាក់កម្ពុជាចូលក្នុងបញ្ជីខ្មៅនេះ លោកស្រី ជូ ប៊ុនអេង បានសង្កត់ធ្ងន់ថា ៖ «ការដាក់បញ្ចូលប្រទេសកម្ពុជា ចូលទៅក្នុងបញ្ជីខ្មៅនេះ បានន័យថាសហរដ្ឋអាមេរិកមិនបានធ្វើការជាមួយប្រទេសកម្ពុជានោះទេ គឺសហរដ្ឋអាមេរិកធ្វើការងារតែឯងខណៈសហរដ្ឋអាមេរិកបានផ្ដល់ជំនួយដល់កម្ពុជាកន្លងមកក្នុងការប្រយុទ្ធប្រឆាំងការជួញដូរមនុស្សនេះ តែបែរជាដាក់ប្រទេសកម្ពុជាចូលក្នុងបញ្ជីខ្មៅ»។

គួរបញ្ជាក់ថា ប្រទេសវៀតណាម នៅក្នុងរបាយការណ៍ស្ដីពីការជួញដូរមនុស្សប្រចាំឆ្នាំរបស់ក្រសួងការបរទេសអាមេរិក បានរកឃើញថា ទីក្រុងហាណូយ មិនបានចាត់វិធានការប្រឆាំងនឹងមន្ត្រីការទូត និងបុគ្គលិកស្ថានទូតវៀតណាមម្នាក់ ដែលបានបង្ហោះសារ នៅក្នុងប្រទេសអារ៉ាប៊ីសាអូឌីត ដែលត្រូវបានគេចោទប្រកាន់ពីបទបង្កភាពស្មុគស្មាញក្នុងការជួញដូរពលរដ្ឋខ្លួនជាច្រើននោះឡើយ។

ក្រសួងការបរទេសអាចម៉េរិក បានឲ្យដឹងដែរថា ការរីករាលដាលនៃអំពើពុករលួយ បានរារាំងដល់កិច្ចខិតខំ ប្រឹងប្រែងជួយដល់កុមាររាប់ពាន់នាក់ រួមទាំងកុមារដែលត្រូវបាន ជួញដូរទៅឲ្យកន្លែងកម្សាន្ត និងការបោកបញ្ឆោតតាមប្រព័ន្ធអ៊ីនធឺណិត ជាដើម។

នៅក្នុងទីក្រុងម៉ាកាវ ដែលគេស្គាល់ថាជាទីក្រុងដែលល្បីខាងកាស៊ីណូ និងការជួញដូរផ្លូវភេទ។ របាយការណ៍នេះបានឲ្យដឹងថា អាជ្ញាធរមិនផ្ដល់សេវាដល់ជនរងគ្រោះដោយការជួញដូរតែមួយមុខ ក្នុងរយៈពេល៣ឆ្នាំជាប់ៗគ្នា នោះទេ។

ជាមួយគ្នានេះដែរ ប្រទេសអាល់ហ្សេរី និងប្រជុំកោះមហាសមុទ្រឥណ្ឌា កូម៉ូរ៉ូ ដែលធ្លាប់នៅក្នុងបញ្ជីខ្មៅ ត្រូវបានលុបចេញពីបញ្ជីខ្មៅនៅឆ្នាំនេះបន្ទាប់ពីមានការកែលម្អផងដែរ៕

# កិច្ចសន្ទនាយុវជនអាស៊ានរិះគិតអំពីផលប៉ះពាល់នៃឧស្សាហកម្ម៤.០

*អត្ថបទ៖ អរិយបុត្រ*

«កិច្ចសន្ទនាយុវជនអាស៊ានលើកទី១» ក្រោមមូលបទ «យុវជនក្នុងយុគ្គសម័យបដិវត្តន៍ឧស្សាហកម្ម៤.០ កាលានុវត្តភាព និងការប្រឈមក្នុងការស្តារឡើងវិញក្រោយជំងឺរាតត្បាតជាសកល» បានរៀបចំនៅទឹកដីអង្គរ កាលពីចុងខែកក្កដា។

«កិច្ចសន្ទនាយុវជនអាស៊ានលើកទី១» នេះ បានប្រព្រឹត្តឡើងនៅថ្ងៃទី២៥ ដល់ថ្ងៃទី ២៦ ខែកក្កដា ឆ្នាំ២០២២ ក្នុងគោលបំណងផ្តល់ជាវេទិកាសម្រាប់យុវជនអាស៊ាន និងសាធារណរដ្ឋកូរ៉េ ដើម្បីចូលជួបពិភាក្សា ផ្តល់អនុសាសន៍ និងផ្លាស់ប្តូរយោបល់គ្នា ជាមួយរដ្ឋមន្រ្តីយុវជនអាស៊ាន-សាធារណរដ្ឋកូរ៉េ និងដៃគូសន្ទនាជាន់ខ្ពស់សំខាន់ៗជាច្រើន។

លោក ហង់ជួន ណារ៉ុន រដ្ឋមន្រ្តីក្រសួងអប់រំ យុវជន និងកីឡា នេះគឺជាព្រឹត្តិការណ៍ដែលរៀបចំឡើងដើម្បីអបអរសាទរភាពជាប្រធានប្តូរវេនអាស៊ានរបស់កម្ពុជា ក្នុងឆ្នាំ២០២២ ក្រោមមូលបទ «អាស៊ានរួមគ្នាធ្វើ ដោះស្រាយបញ្ហាប្រឈមទាំងអស់គ្នា» នៅក្នុងក្រមខណ្ឌសសរស្តម្ភសហគមន៍សង្គម-វប្បធម៌អាស៊ាន ក្រោមកិច្ចសហការជាមួយលេខាធិការដ្ឋានអាស៊ាន

> ខ្ញុំរីករាយ ដែលឮថា យើងមានរៀបចំកិច្ចប្រជុំបែបនេះ ពីព្រោះ វាគឺជាវេទិកា ដែល យ៉ាងហោចណាស់ ក៏ តំណាងយុវជនយើង ខ្លះបានចូលរួម ដែរ










និងការគាំទ្រពីរដ្ឋាភិបាលនៃសាធារណរដ្ឋកូរ៉េ។

លោកបានបន្តថា កិច្ចសន្ទនានេះពិសេសនោះគឺ ការផ្តោតទៅលើវិធីសាស្រ្តក្នុងការស្វែងរកអត្ថប្រយោជន៍ និងកាលានុវត្តភាព ដែលកើតចេញពីឧស្សាហកម្ម៤.០ ព្រមទាំងដោះស្រាយបញ្ហាប្រឈមដែលបានកើតឡើងពីជំងឺរាតត្បាតជាសកល ដែលរំលេចដោយយុវជន។

លោករដ្ឋមន្រ្តីបន្តទៀតថា បដិវត្តន៍ឧស្សាហកម្មទី៤ គឺផ្លាស់ប្តូរជាមូលដ្ឋាននូវរបៀបរស់នៅ របៀបធ្វើការ និងទំនាក់ទំនងគ្នាទៅវិញទៅមក វាត្រូវបានកំណត់លក្ខណៈដោយចំណុចប្រសព្វនៃរបកគំហើញ បច្ចេកវិទ្យាដែលកំពុងរីកចម្រើនគ្របដណ្តប់លើវិស័យធំទូលាយដូចជា បញ្ញាសិប្បនិមិត្ត (AI), មនុស្សយន្ត, អ៊ីនធឺណិតនៃវត្ថុ (IoT), រថយន្តស្វយ័ត, ការបោះពុម្ព 3D, ណាណូបច្ចេកវិទ្យា,ជីវបច្ចេកវិទ្យា,វិទ្យាសាស្រ្តសម្ភារ, ការផ្ទុកថាមពល និង quantum computing ដើម្បីដាក់ឈ្មោះមួយចំនួន។

លោករដ្ឋមន្រ្តីជឿជាក់ថា កិច្ចសន្ទនាយុវជនអាស៊ានលើកទី១នេះ នឹងផ្តល់ជាវេទិកាដ៏សំខាន់មួយសម្រាប់យុវជនអាស៊ាន ដើម្បីពិភាក្សាអំពីបញ្ហាសំខាន់ៗក្នុងតំបន់ និងពិភពលោក ដែលជះឥទ្ធិពលដល់អនាគតរបស់ពួកគេ រាប់ចាប់ពីវិទ្យាសាស្រ្ត បច្ចេកវិទ្យា នវានុវត្តន៍ និងអនាគតសម្រាប់ការងារដល់ការអភិវឌ្ឍន៍ប្រកបដោយចីរភាព ការប្រែប្រួលអាកាសធាតុ និងការផ្លាស់ប្តូរពីមនុស្សទៅមនុស្ស ដើម្បីត្រៀមខ្លួនសម្រាប់ការងារនាពេលអនាគត និងទទួលបានជំនាញរៀនបច្ចេកវិទ្យាស្របតាមភាពជឿនលឿននៃបរិបទបដិវត្តន៍ឧស្សាហកម្មទី៤.០ ។

លើសពីនេះទៀត ស្របពេលដែល រដ្ឋសមាជិកអាស៊ានកំពុងប្រឈមមុខនឹងភាពមិនច្បាស់លាស់អំពីរបៀបរៀបចំយុវជនសម្រាប់អនាគតថ្មីនៃការងារ និងសម្រាប់ការសម្របខ្លួន និងការទទួលយកឧស្សាហកម្ម ៤.០ ។

យុវជន សេត សម្បត្តិ ជាយុវនិស្សិតមួយរូប បានថ្លែងថា ម្នូនមិនបានដឹងអំពីវេទិការសន្ទនានេះទេ ប៉ុន្តែប្រសិនបើមាន ទោះបីជាម្នូនមិនបានចូលរួម ក៏ម្នូនរីករាយនឹងការដែលឮអំពីការរៀបចំព្រឹត្តិការណ៍បែបនេះនៅកម្ពុជា។

សម្បត្តិ បានថ្លែងថា ៖ «ទោះមិនបានចូលរួម តែខ្ញុំរីករាយដែលយុវជនយើងផ្សេងទៀតមានឱកាសចូលរួមព្រឹត្តិការណ៍បែបនេះ។ ខ្ញុំរីករាយ ដែលឮថា យើងមានរៀបចំកិច្ចប្រជុំបែបនេះ ពីព្រោះវាគឺជាវេទិកា ដែលយ៉ាងហោចណាស់ ក៏តំណាងយុវជនយើងខ្លះបានចូលរួមដែរ»។

យុវជន ទុំ បញ្ញារិទ្ធិ យុវនិស្សិតមួយរូបទៀត ក៏សំដែងការចាប់អារម្មណ៍នឹងកម្មវិធីនេះដែរ ពីព្រោះថា វាគឺជាប្រធានបទមួយ ដែលយុវជនចាប់អារម្មណ៍។

បញ្ញារិទ្ធិ បានបញ្ជាក់ថា ៖ «ខ្ញុំដូចអត់បានដឹងអំពីពីព្រឹត្តិការណ៍នេះទេ តែយុវជនយើងពិតជាចាប់អារម្មណ៍ ជាពិសេសគឺរឿងបច្ចេកវិទ្យា និងរឿងច្នៃប្រឌិតទាក់ទងនឹង បដិវត្តន៍ឧស្សាហកម្ម៤.០»។

នាវេទិកានោះប្រតិភូយុវជនដែលមានចំនួនប្រមាណ ២០០នាក់ រួមមានរដ្ឋមន្រ្តីយុវជនអាស៊ាន និងកូរ៉េខាងត្បូង តំណាងជាន់ខ្ពស់នៃទីភ្នាក់ងារអន្តរជាតិ អភិបាលយុវជនជាន់ខ្ពស់ ប្រតិភូយុវជន ទីភ្នាក់ងាររដ្ឋាភិបាល អង្គការក្រៅរដ្ឋាភិបាល-សង្គមស៊ីវិល វិទ្យាស្ថានស្រាវជ្រាវ សហគ្រិនវិស័យឯកជន អ្នកសង្កេតការណ៍ អង្គភាពអាស៊ាន ទីភ្នាក់ងារអង្គការសហប្រជាជាតិ និងដៃគូពាក់ព័ន្ធមានឱកាសរៀនសូត្រពីគ្នាទៅវិញទៅមក ដោយទាញយកអត្ថប្រយោជន៍នៃឱកាសបច្ចេកវិទ្យា សេដ្ឋកិច្ច និងសង្គម ដើម្បីពង្រឹងកិច្ចសហប្រតិបត្តិការរវាងអាស៊ាន និងកូរ៉េខាងត្បូង។

កម្មវិធីនេះបានបង្កើតនូវអនុសាសន៍គោលនយោបាយស្តីពីបញ្ហារួម ដែលនឹងដាក់ជូនកិច្ចប្រជុំមន្រ្តីជាន់ខ្ពស់អាស៊ានស្តីពីយុវជន (SOMY) កិច្ចប្រជុំមន្រ្តីជាន់ខ្ពស់អាស៊ានស្តីពីយុវជនបូកបី (SOMY+3) និងកិច្ចប្រជុំរដ្ឋមន្រ្តីអាស៊ានស្តីពីយុវជន (AMMY) ដើម្បីជំរុញការអនុវត្តផែនការការងារអាស៊ានស្តីពីយុវជនឆ្នាំ ២០២១-២០២៥ ផែនការការងារអាស៊ានបូកបីស្តីពីយុវជនឆ្នាំ ២០២១-២០២៥ និងផែនការសកម្មភាពអាស៊ាន-កូរ៉េខាងត្បូងឆ្នាំ ២០២១-២០២៥ ៕

# ទេសចរណ៍ក្នុងស្រុកជួយស្តារ វិស័យទេសចរណ៍ជាតិ



*អត្ថបទ៖ អរិយបុត្រ*

ថ្នាក់ដឹកនាំប្រទេសនិងអ្នកប្រតិបត្តិករនៅក្នុងវិស័យទេសចរណ៍នៅកម្ពុជាសុទ្ធតែអះអាងថា ទេសចរណ៍ផ្ទៃក្នុងនៅតែជាឆ្អឹងខ្នងនៃការស្តារ និងអភិវឌ្ឍន៍វិស័យទេសចរណ៍ជាតិ ក្រោយពេលដែលកូវីដ-១៩បានវាយប្រហារវិស័យនេះដល់កម្រិតបាត ធៀបនឹងវិស័យផ្សេងៗទៀត។

សម្តេច ហ៊ុន សែន នាយករដ្ឋមន្ត្រីកម្ពុជាបានលើកឡើងថា ចលនាទេសចរណ៍ផ្ទៃក្នុង គឺបានហើយនិងកំពុងរួមចំណែកយ៉ាងសំខាន់ក្នុងការស្តារវិស័យទេសចរណ៍ក្នុងដំណាក់កាលវិបត្តិកូវីដ-១៩ ។

សម្តេចបានមានប្រសាសន៍ក្នុងពិធីបិទសន្និបាតបូកសរុបការងារវិស័យទេសចរណ៍របស់ក្រសួងទេសចរណ៍ និងប្រតិបត្តិករទេសចរណ៍ នាថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២២ថា ក្រសួងទេសចរណ៍និងស្ថាប័នពាក់ព័ន្ធព្រមទាំងវិស័យឯកជន ត្រូវតែបន្តជំរុញទាក់ទាញចលនាទេសចរផ្ទៃក្នុង ពីព្រោះទេសចរផ្ទៃក្នុងបានរួម ចំណែកយ៉ាងធំក្នុងដំណាក់កាលកូវីដ ដែលបានជួយស្តារសេដ្ឋកិច្ច-សង្គមឡើងវិញ ក្នុងពេលដែលយើងអនុវត្តវិធានការរស់នៅតាមគន្លងប្រក្រតីភាពថ្មី។

សម្តេចហ៊ុន សែនក៏បានផ្តល់អនុសាសន៍ឱ្យបន្តជំរុញយុទ្ធនាការ «ទស្សនាស្រុកយើង៖ ទេសចរណ៍ផ្សារភ្ជាប់ទឹកដី ឬស្រឡាញ់ជាតិ ត្រូវស្គាល់ទឹកដី» ឱ្យមានប្រសិទ្ធភាពខ្ពស់។

ពាក់ព័ន្ធនឹងវិស័យទេសចរណ៍នេះដែរសម្តេចក៏បានបង្ហាញនូវការ ជឿជាក់ថាភ្ញៀវទេសចរចិននឹងមកកម្ពុជាច្រើន បើរដ្ឋាភិបាលចិនដកគោលនយោបាយសូន្យកូវីដ ហើយបានណែនាំឲ្យក្រសួងនិងវិស័យឯកជនត្រៀមខ្លួន។

សម្តេចបានមានប្រសាសន៍ថា ការដាក់ចេញនូវគោលនយោបាយសូន្យកូវីដ របស់រដ្ឋាភិបាលចិន បានធ្វើឲ្យប៉ះពាល់ការហូរចូលនៃភ្ញៀវទេសចរចិនមកកម្ពុជា ព្រោះតែការកំណត់ចំនួនថ្ងៃធ្វើចត្តាឡីស័ក មានរយៈពេលយូរ ពិបាកក្នុងការធ្វើដំណើរចេញចូល។

ភ្ញៀវទេសចរចិន ដែលនៅមុនកើតឡើងនូវវិបត្តិកូវីដ-១៩ ឈរលំដាប់លេខ១ មកទស្សនាកម្ពុជា ច្រើនជាងគេបំផុត។ ជាថ្មីម្តងទៀត ក្រៅពីបង្ហាញក្តីសង្ឃឹមសម្តេចក៏បានណែនាំថា វិស័យទេសចរណ៍កម្ពុជា អាចនឹងបន្តរងគ្រោះដោយសារបញ្ហាសង្គ្រាមនិងទណ្ឌកម្ម។

នៅក្នុងសន្និបាតលោក ទិត ចន្ថា រដ្ឋលេខាធិការប្រចាំការក្រសួងទេសចរណ៍ បានឱ្យដឹងថា «វិស័យទេសចរណ៍កម្ពុជាមានចក្ខុវិស័យប្រកបដោយសុទិដ្ឋិនិយមថា នឹងអាចវិលទៅរកសភាពប្រហាក់ប្រហែលនឹងស្ថានភាពទេសចរណ៍ឆ្នាំ២០១៩ វិញ នៅក្នុងឆ្នាំ២០២៦ ។

លោកបានអះអាងថា ស្ថិតក្នុងបរិការណ៍នៃភាពមិនច្បាស់លាស់នេះ ការចូលរួមមិនអាចខ្វះបានរបស់គ្រប់ភាគីពាក់ព័ន្ធ ដោយឈរលើគោលការណ៍ចតុភាគីរដ្ឋ-ឯកជន-ប្រជាពលរដ្ឋ និងភ្ញៀវទេសចរ-ដៃគូនៅក្នុងក្របខណ្ឌទ្វេភាគី និងពហុភាគី នឹងក្លាយជាចលករក្នុងការជំរុញវិស័យទេសចរណ៍កម្ពុជាឱ្យវិលមករកភាពដើមវិញ ស្របតាមចក្ខុវិស័យដែលបានចែងក្នុងផែនទីចង្អុលផ្លូវស្តីពីផែនការស្តារ និងលើកស្ទួយវិស័យទេសចរណ៍កម្ពុជាក្នុងនិងក្រោយវិបត្តិជំងឺកូវីដ-១៩ ។

លោក ថោង ខុន រដ្ឋមន្ត្រីក្រសួងទេសចរណ៍ បានឱ្យដឹងដែរថា ក្នុងរយៈពេលប្រាំមួយខែដំបូងនៃឆ្នាំ ២០២២ កម្ពុជាបានទាក់ទាញភ្ញៀវទេសចរអន្តរជាតិជាង ៥00 000 នាក់បានមកទស្សនាប្រទេសកម្ពុជា កើនឡើងរហូតដល់ ៣៩៤ ភាគរយបើធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០២១ ប៉ុន្តែតួលេខនេះបានថយចុះចំនួន ៨៤,៨ ភាគរយបើធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០១៩ ។

លោកបានបន្តថា ៖ «នៅក្នុងឆមាសទីមួយនៃឆ្នាំនេះ ចលនាទេសចរណ៍ក្នុងស្រុកត្រូវបានតាមដានថា មានចំនួន ៦,៣៣ លាននាក់ កើនឡើងប្រហែល ២១៩ ភាគរយ ខណៈដែលចំនួនភ្ញៀវទេសចរបរទេសក្នុងស្រុកត្រូវបានកត់ត្រាចំនួន ០,៦៨ លាននាក់ កើនឡើងប្រហែល ៣៨០ភាគរយបើធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០២១»។

វិស័យទេសចរណ៍គឺជាសសរស្តម្ភមួយក្នុងចំណោមសសរស្តម្ភទាំងបួនដែលជួយដល់សេដ្ឋកិច្ចកម្ពុជា។ ប្រទេសកម្ពុជាបានទាក់ទាញភ្ញៀវទេសចរអន្តរជាតិរហូតដល់ ៦,៦១ លាននាក់ក្នុងឆ្នាំ ២០១៩ ដែលបង្កើតប្រាក់ចំណូលសរុបចំនួន ជិត ៥ ពាន់លានដុល្លារអាមេរិក៕



# ធនាគារអភិវឌ្ឍន៍អាស៊ីគាំទ្រខ្សែសង្វាក់ផ្គត់ផ្គង់កសិកម្មនៅកម្ពុជា

*អត្ថបទ៖ អរិយបុត្រ*

ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) និងក្រុមហ៊ុន De Heus TMH Company Limited (DH-TMH) បានចុះហត្ថលេខាលើ ប្រាក់កម្ចី ចំនួន ១៥ លានដុល្លារ ដើម្បីជំរុញវិស័យចំណីសត្វរបស់កម្ពុជា តាមរយៈការពង្រីកសមត្ថភាពផ្ទុក និងកែច្នៃចំណីសត្វរបស់ក្រុមហ៊ុន DH-TMH នៅខេត្តកំពង់ស្ពឺ។

គម្រោងនេះនឹងពាក់ព័ន្ធជាមួយនឹងការពង្រីកទំហំឃ្លាំង និងលទ្ធកម្មនៃម៉ាស៊ីនកែច្នៃបន្ថែម នឹងជំរុញការផលិតចំណីប្រកបដោយប្រសិទ្ធផល។ គម្រោងនេះនឹងអនុញ្ញាតឱ្យក្រុមហ៊ុនអាចទិញវត្ថុធាតុដើមបានកាន់តែច្រើនពីម្ចាស់កសិដ្ឋាន ខ្នាតតូចក្នុងស្រុក នៃដំណាំ ពោត ស្រូវ ដំឡូងមី ក្នុងខ្សែសង្វាក់ផ្គត់ផ្គង់របស់ខ្លួន តាមរយៈការបង្កលក្ខណៈ ដល់ការផ្គត់ផ្គង់ផលិតចំណីប្រកបដោយគុណភាពសម្រាប់កសិករចិញ្ចឹមបសុសត្វ និងត្រី។

ជាមួយការ វិនិយោគនានាលើឃ្លាំងផ្ទុក ផលិតផលពោត គម្រោងនេះក៏គាំទ្រដល់ការដំឡើងម៉ាស៊ីនសម្ងួតអាចរក្សាទុកបានកាន់តែយូរ និងកាត់បន្ថយហានិភ័យដែលបណ្តាលមកពីអាកាសធាតុ។

លោកស្រី ជីយូសាណា វ៉ាម៉ា (Jyotsana Varma) នាយិកាធនាគារអភិវឌ្ឍន៍អាស៊ីនៅកម្ពុជា បានឲ្យដឹងថា ៖ «តាមរយៈការគាំទ្រនេះ យើងកំពុងជួយពង្រឹងខ្សែសង្វាក់តម្លៃចំណី ធ្វើអោយប្រសើរឡើងនូវ ជីវភាពរស់នៅរបស់កសិករដំណាំចំណី បសុសត្វ និង ត្រី ហើយគាំទ្រសកម្មភាពកសិកម្ម ដែលមាន និរន្តរភាព និង ភាពធន់»។

> យើងកំពុងជួយពង្រឹងខ្សែសង្វាក់តម្លៃចំណី ធ្វើអោយប្រសើរឡើងនូវ ជីវភាពរស់នៅរបស់កសិករដំណាំចំណី បសុសត្វ និង ត្រី ហើយគាំទ្រសកម្មភាពកសិកម្ម ដែលមាន និរន្តរភាព និង ភាពធន់

លោកស្រីបានបន្តថា ការអភិវឌ្ឍការផ្គត់ផ្គង់ចំណីសត្វដែលមានប្រភពក្នុងស្រុក គុណភាពខ្ពស់ និង តម្លៃ សមរម្យ គឺជាកត្តាសំខាន់ក្នុងការការពារសន្តិសុខស្បៀងរបស់កម្ពុជា និងកាត់បន្ថយការពឹង ផ្អែកលើ ការនាំចូលចំណីសត្វ។

រីឯ លោក ហ្គាប៉ ហ្វ្លូត ( Gabor Fluit) នាយកប្រតិបត្តិ De Heus នៅអាស៊ីបានអះអាងថា ក្រុមហ៊ុនប្តេជ្ញាផ្តល់អំណាចដល់កសិករឯករាជ្យនៅកម្ពុជា។ កិច្ចព្រមព្រៀងសហប្រតិបត្តិការជាយុទ្ធសាស្ត្រ រួមជាមួយនឹងការផ្តោតការយកចិត្តទុកដាក់លើការបណ្តុះបណ្តាល និងការចែករំលែកចំណេះដឹងជាមួយនឹងបាវចនា «ចំណេះដឹងសកល-ផលជះក្នុងតំបន់» នឹងគាំទ្រនិងពន្លឿនការអភិវឌ្ឍន៍ ប្រកបដោយចីរភាពនៃខ្សែសង្វាក់ផ្គត់ផ្គង់ប្រូតេអ៊ីនសម្រាប់សត្វនៅកម្ពុជា។

លោក វេង សាខុន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ បានថ្លែងថា ជាសមិទ្ធផលថ្មីមួយទៀតដែលបានប្រសូត្រចេញពីការខិតខំប្រឹងប្រែង ផ្តល់កិច្ចសហការគ្នាបានល្អរវាងភាគីពាក់ព័ន្ធ ឈានមកសម្រេចបាននូវកិច្ចព្រមព្រៀងកម្ចីឥណទានដើម្បីយកមកអភិវឌ្ឍខ្សែប្រវាក់ផលិតកម្មចំណីសត្វដើម្បីឆ្លើយតបបានទាន់ពេលទៅនឹងកំណើនផលិតកម្មសត្វ (ជ្រូក ត្រី និងបក្សី) នាពេលបច្ចុប្បន្ន។

ជំនួយបច្ចេកទេសមួយ នឹងគាំទ្រដល់ការបណ្តុះបណ្តាលសម្រាប់កសិករដាំពោតចំនួន ២ 000 នាក់ និងកសិករចិញ្ចឹមមាន់ចំនួន ២ 000 នាក់ ដែលភាគច្រើនជាស្ត្រី អំពីការអនុវត្តធ្វើឱ្យកសិដ្ឋានធន់នឹងអាកាសធាតុ ព្រមទាំងអំពីចំណេះដឹងផ្នែកហិរញ្ញវត្ថុ។ ការគាំទ្រកសិករជាស្ត្រីនឹងជួយពង្រឹងមុខការរបស់ពួកគាត់នៅក្នុងកសិដ្ឋាន និង ជំរុញលទ្ធភាពទទួលបានហិរញ្ញវត្ថុដើម្បីពង្រីកអាជីវកម្មរបស់ពួកគាត់ផងដែរ៕

# ដើមកោងកាងចំនួន៣០០០ដើម ត្រូវបានដាំនៅខេត្តកែប

*អត្ថបទ៖ អមរិន្ទ ដានុត*

ដើមកោងកាងចំនួន ៣០០០ ដើម ត្រូវបានដាំ នៅសហគមន៍នេសាទភូមិថ្មី សង្កាត់ព្រៃធំ ក្រុងកែប ខេត្តកែប ដើម្បីអបអរទិវាអន្តរជាតិសម្រាប់ការអភិរក្សប្រព័ន្ធអេកូឡូស៊ីព្រៃកោងកាង ២៦ កក្កដា ឆ្នាំ២០២២ ដោយក្រសួងបរិស្ថាន រដ្ឋបាលខេត្តកែប និងក្រុមហ៊ុន វីន ហ្វ្រេតជើនីធី (វីតាល់)។

ពិធីនេះធ្វើឡើងក្នុងគោលបំណងលើកកម្ពស់និរន្តរភាព និងការយល់ដឹងអំពីបរិស្ថាន និងចូលរួមស្តារព្រៃកោងកាងឡើងវិញនៅតាមតំបន់ឆ្នេរសមុទ្រកម្ពុជា។ ព្រឹត្តិការណ៍ នេះត្រូវបានរំពឹងថានឹងជាសារដ៏សំខាន់បណ្តុះស្មារតីពលរដ្ឋឱ្យស្រឡាញ់បរិស្ថាន និងចូលរួមអភិរក្សធនធានធម្មជាតិកាន់តែខ្លាំងថែមទៀត។

លោក នេត្រ ភក្ត្រា រដ្ឋលេខាធិការ និងជាអ្នកនាំពាក្យក្រសួងបរិស្ថាន បានលើកឡើងថា ការដាំកូនកោងកាងក្នុងទិវានេះ មិនត្រឹមតែចូលរួមបង្កើតភាពបៃតងនៅតាមតំបន់ខេត្តមាត់សមុទ្រ ប៉ុន្តែបានចូលរួមបង្កើតជម្រកសម្រាប់ជីវៈចម្រុះ និងពង្រឹងប្រព័ន្ធអេកូឡូស៊ីនៅតំបន់សមុទ្រ ហើយនឹងផ្តល់ការលើកទឹកចិត្តដល់សាធារណៈជនឱ្យស្រឡាញ់បរិស្ថានកាន់តែខ្លាំងនិងចូលរួមការពារបរិស្ថាននិងធនធានធម្មជាតិ។

លោកមានប្រសាសន៍ថា ៖ «ដើមកោងកាង គឺជាតំបន់ទ្រនាប់រវាងដីគោក និងសមុទ្រ ទប់នឹងបញ្ហាធ្ងន់ធ្ងរនៃការហូរច្រោះតាមឆ្នេរសមុទ្រ និងការគំរាមកំហែងនៃការកើនឡើងនៃកម្ពស់ទឹកសមុទ្រ។ ព្រៃកោងកាងជារបៀងយុទ្ធសាស្ត្រតភ្ជាប់ប្រព័ន្ធអេកូឡូស៊ីពីតំបន់ដីគោក ឆ្នេរ និងសមុទ្រ ហើយក៏ជារនាំងប្រឆាំងនឹងគ្រោះធម្មជាតិ និងការប្រែប្រួលអាកាសធាតុ»។

អ្នកនាំពាក្យរូបនេះ បានបន្ថែមថា ព្រៃកោងកាងផ្តល់នូវការបន្សាំធម្មជាតិទៅនឹងផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ និងប្រឆាំងនឹងការប្រែប្រួលអាកាសធាតុនិងចូលរួមចំណែកកាត់បន្ថយការបំភាយឧស្ម័នផ្ទះកញ្ចក់។

ចំណែកលោកសោមពិសិដ្ឋអភិបាលខេត្តកែប បានលើកឡើងដោយបានលើកទឹកចិត្តគ្រប់មន្ទីរទាំងអស់ ក៏ដូចជាសាធារណជនទូទៅក្នុងខេត្ត បន្តចូលរួមដាំកោងកាងឱ្យបានកាន់តែច្រើនថែមទៀត ដើម្បីធានាការពារគុណភាព បរិស្ថានឱ្យបានល្អ និងលើកកម្ពស់សោភ័ណភាពទីក្រុងបៃតង ។

លោកមានប្រសាសន៍ថា៖«អាជ្ញាធរខេត្ត បាននិងកំពុងយកចិត្តទុកដាក់យ៉ាងខ្លាំងក្នុងកិច្ចគាំពារបរិស្ថាន ការអភិរក្សធនធានធម្មជាតិ សំដៅទប់ស្កាត់ការប្រែប្រួលអាកាសធាតុ ការកើនឡើងកម្តៅ ការរាំងស្ងួត ទឹកជំនន់ និងគ្រោះធម្មជាតិផ្សេងៗទៀត ពិសេសធ្វើឱ្យការប្រើប្រាស់ធនធានធម្មជាតិបានយូរអង្វែង»។

លោកស្រី ជឹង សុគន្ធាវី អគ្គនាយិកាក្រុមហ៊ុនវីន ហ្វ្រេតជើនីធី (វីតាល់) បានឱ្យដឹងថា ប្រព័ន្ធអេកូឡូស៊ីព្រៃកោងកាងបានរងការគំរាមកំហែងដោយសារសកម្មភាពរបស់មនុស្ស ហើយបង្កការគំរាមកំហែងយ៉ាងធ្ងន់ធ្ងរដល់មនុស្សជាតិ និងជីវៈចម្រុះ។

លោកស្រីថា ការការពារ និងស្តារប្រព័ន្ធអេកូឡូស៊ីទាំងនេះឡើងវិញមានសារៈសំខាន់ណាស់ ហើយទាំងអស់អាចចាប់ផ្តើមពីថ្ងៃនេះ តាមរយៈសកម្មភាពនៃការដាំកោងកាងឡើងវិញដោយការចូលរួមការពារ និងផ្សព្វផ្សាយ ដើម្បីឱ្យអនាគតកម្ពុជាកាន់តែប្រសើរ និងជាប្រភពស្រស់ថ្លានៃធម្មជាតិ៕

# រដ្ឋមន្ត្រីប្រកាសសមាជិកគណៈកម្មាធិការប្រកួតប្រជែងកម្ពុជា

*អត្ថបទ៖ អរិយបុត្រ*

គណៈកម្មាធិការប្រកួតប្រជែងកម្ពុជាថ្មីៗនេះបានបើកកិច្ចប្រជុំលើកទី១របស់ខ្លួន ដើម្បីឱ្យសមាជិកទាំងអស់បានជួបជុំគ្នា ក្រោយពីរាជរដ្ឋាភិបាលចេញសេចក្តីសម្រេចតែងតាំងសមាសភាពកាលពីថ្ងៃទី១៤ ខែកក្កដា កន្លងទៅនេះ។

លោក ប៉ាន សូរស័ក្តិ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម បានបង្ហាញពីសុទិដ្ឋិនិយមចំពោះការបើកកិច្ចប្រជុំជាលើកដំបូងនេះ ដែលជាការបង្ហាញពីការចាប់ផ្តើមអនុវត្តច្បាប់ស្តីពីការប្រកួតប្រជែងនៅកម្ពុជា។

សមាជិកគណៈកម្មាធិការ នេះ មានសមាសភាពសរុបចំនួន ១៥រូប ដែល ១០រូបជាតំណាងមកពីក្រសួង ស្ថាប័នពាក់ព័ន្ធ និង ៥រូប ជាបុគ្គលឯករាជ្យ ដែលរួមមានអតីតចៅក្រម ១រូប អ្នកសេដ្ឋកិច្ច ២រូប និងអ្នកច្បាប់ ២រូប ដែលឆ្លងកាត់តាមការជ្រើសរើស។ គណៈកម្មាធិការនេះ មានអគ្គនាយកដ្ឋានការពារអ្នកប្រើប្រាស់ កិច្ចការប្រកួតប្រជែង និងបង្ក្រាបការក្លែងបន្លំ «ក.ប.ប.» ជាសេនាធិការ ដើម្បីអនុញ្ញាតឱ្យ គណកម្មាធិការនេះ ទទួលបាននូវសិទ្ធិពេញលេញក្នុងការអនុវត្តនូវតួនាទីនិងភារកិច្ចរបស់ខ្លួន។

លោក ប៉ាន សូរស័ក្តិ បានបញ្ជាក់ថា យោងតាមមាត្រា៤ នៃច្បាប់ស្តីពីការប្រកួតប្រជែង តម្រូវឱ្យបង្កើតគណៈកម្មាធិការប្រកួតប្រជែងកម្ពុជាដែលជាអ្នកទទួលបន្ទុកដឹកនាំ និងត្រួតពិនិត្យការអនុវត្តច្បាប់ស្តីពីការប្រកួតប្រជែង ។

លោកបន្ថែមថា យោងតាមច្បាប់ស្តីពីការប្រកួតប្រជែង អគ្គនាយកដ្ឋាន ក.ប.ប. ដែលជាសេនាធិការ និងដើរតួនាទីជាអ្នកស៊ើបអង្កេត ខណៈដែលគណៈកម្មាធិការប្រកួតប្រជែងកម្ពុជា ជាអ្នកធ្វើសេចក្តីសម្រេចក្នុងការកំណត់ថា បុគ្គលណាមួយបំពានច្បាប់ ដោយផ្អែកលើភស្តុតាងដែលផ្តល់ដោយមន្ត្រីនៃអគ្គនាយកដ្ឋាន ក.ប.ប.។

ទន្ទឹមនឹងការបង្កើតដោយជោគជ័យនូវគណៈកម្មាធិការប្រកួតប្រជែងកម្ពុជា «គ.ប.ក.» នេះ ថ្នាក់ដឹកនាំ និងមន្ត្រី នៃអគ្គនាយកដ្ឋាន ក.ប.ប. ចំនួន ២៨៥រូប បានបំពេញនីតិវិធីសម្បថ នៅតាមបណ្តាសាលាដំបូងរាជធានី-ខេត្ត ដើម្បីទទួលបាននីតិសម្បទាជានគរបាលយុត្តិធម៌ចប់សព្វគ្រប់ផងដែរ ដើម្បីត្រួតពិនិត្យនិងស៊ើបអង្កេតបទល្មើសក្រោមច្បាប់ស្តីពីការប្រកួតប្រជែង ហើយបច្ចុប្បន្ននេះ អគ្គនាយកដ្ឋាន ក.ប.ប. ក្នុងនាមជាសេនាធិការរបស់ គ.ប.ក. បាននិងកំពុងរៀបចំនូវបទប្បញ្ញត្តិមូលដ្ឋានមួយចំនួន សម្រាប់គាំទ្រដល់ដំណើរការអនុវត្តច្បាប់ស្តីពីការប្រកួតប្រជែង ប្រកបដោយប្រសិទ្ធភាព៕

# រដ្ឋគ្រោងដាក់ឲ្យប្រើប្រាស់ការធានារ៉ាប់រងយានយន្តឯកជនជាកាតព្វកិច្ច

*អត្ថបទ៖ អរិយបុត្រ*

ក្នុងគោលដៅលើកកម្ពស់វិស័យធានារ៉ាប់រងឲ្យមានការរីកចម្រើនថែមទៀតនៅពេលខាងមុខនេះ រាជរដ្ឋាភិបាលកម្ពុជាគ្រោងនឹងដាក់ឲ្យប្រើប្រាស់នូវសេវាធានារ៉ាបរងយានយន្តឯកជនជាកាតព្វកិច្ច ដែលជាការទទួលខុសត្រូវរបស់ប្រតិបត្តិករធានារ៉ាប់រង និងម្ចាស់យានយន្តចំពោះសង្គមជាតិ។

ក្នុងពិធីបើកកម្មវិធីទិវាធានារ៉ាប់រង ២០២២ កាលពីថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០២២កន្លងទៅនេះ លោក រស់ សីលវ៉ា រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាអនុប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ បានមានប្រសាសន៍ថា គម្រោងធានារ៉ាប់រងយានយន្តឯកជនជាកាតព្វកិច្ចនេះ តាមរយៈការធានារ៉ាប់រងដល់ជនរងគ្រោះ ដែលបង្កដោយគ្រោះថ្នាក់ចរាចរណ៍នៅតាមដងផ្លូវក្នុងប្រទេសកម្ពុជា ពោលគឺជួយឲ្យពួកគាត់ទទួលបានសំណងសមស្របណាមួយសម្រាប់ការព្យាបាល និងដោះស្រាយបញ្ហាផ្នែកហិរញ្ញវត្ថុរបស់ខ្លួន។

លោកបានឲ្យដឹងថា ផលប្រយោជន៍ក្នុងការដំណើរការប្រព័ន្ធធានារ៉ាប់រងខាងលើនេះ នឹងដើរតួនាទីយ៉ាងសំខាន់ក្នុងការពង្រឹង និងពង្រីកប្រព័ន្ធសំណាញ់សុវត្ថិភាពសង្គម ឲ្យដើរទន្ទឹមគ្នានឹងការដាក់ឲ្យអនុវត្តប្រព័ន្ធគាំពារសង្គមរបស់រដ្ឋាភិបាលផងដែរ។

ជាមួយគ្នានេះ ប្រធានសមាគមធានារ៉ាប់រងកម្ពុជា លោក ហ៊ុយ វ៉ាថារ៉ូ បានបង្ហាញការគាំទ្រចំពោះគម្រោងការដាក់ឱ្យដំណើរការប្រព័ន្ធធានារ៉ាប់រងយានយន្តឯកជនជាកាតព្វកិច្ច ខណៈបច្ចុប្បន្នបានអនុវត្តជាអន្លើរតែទៅលើយានយន្តនៃក្រុមហ៊ុនដឹកជញ្ជូនអ្នកដំណើរ និងក្រុមហ៊ុនដឹកទំនិញប៉ុណ្ណោះ។

លោកបន្តថា ទីផ្សារធានារ៉ាប់រងនៅកម្ពុជាក្នុងពេលបច្ចុប្បន្ន មានក្រុមហ៊ុនធានារ៉ាប់រងសរុប៣៩ ក្នុងនោះក្រុមហ៊ុនធានារ៉ាប់រងទូទៅមានចំនួន១៨ ក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិតចំនួន១៤ និងក្រុមហ៊ុនធានារ៉ាប់រងខ្នាតតូចចំនួន៧ ព្រមទាំងមានក្រុមហ៊ុនធានារ៉ាប់រងបន្តចំនួន១ ៕

# មន្ត្រី៖ ហាត់ប្រាណទៀងទាត់ និងបរិភោគ អាហារចម្រុះមុខជាប្រចាំ នាំមកនូវសុខភាពល្អ



*អត្ថបទ៖ អមរិន្ទ ដានុត*

កញ្ញា ឈុន បូរមី បានចាប់ផ្តើមឡើងគីឡូជាគំហុកនៅឆ្នាំ២០១៦ ដោយសារតែការមិនសូវបានយកចិត្តទុកដាក់ទៅលើកត្តាសំខាន់ចំនួនពីរ គឺ ការបរិភោគអាហារ និងការហាត់ប្រាណ និងដោយសារនាងខ្ញុំមានការមមាញឹកជាខ្លាំងក្នុងការសិក្សានៅសកលវិទ្យាល័យ។

ជាអ្នកសម្របសម្រួលក្រុមយុវជនជើងឯកអាហារូបត្ថម្ភនៃអង្គការហេឡែន ខេលល័រអន្តរជាតិ កញ្ញា ឈុន បូរមី បានប្រាប់ឱ្យដឹងថា ៖ «ខ្ញុំមិនសូវបានយកចិត្តទុកដាក់ទៅលើកត្តាសំខាន់ទាំងពីរនេះ និងដោយសារខ្ញុំមានការមមាញឹកជាខ្លាំងក្នុងការសិក្សានៅសកលវិទ្យាល័យ។ ជាមួយគ្នានេះ ខ្ញុំក៏រវល់ខ្លាំងក្នុងការបំរើការងារនៅការិយាល័យស្ថាប័នមួយ ដែលជាហេតុមិនសូវមានពេលវេលាគ្រប់គ្រាន់ទៅលើការហាត់ប្រាណនិងគិតគូម៉ត់ចត់លើបរិភោគអាហារសុខភាពទេ»។

ពីមួយថ្ងៃទៅមួយថ្ងៃ គីឡូរបស់ឈុន បូរមី កាន់តែឡើងទៅៗ ដែលធ្វើឲ្យនាងកាន់តែមួរម៉ង និងរកាំក្នុងចិត្តយ៉ាងខ្លាំង ដោយសារតែរូបរាងនាងមិនមានលក្ខណៈដូចពីពេលមុន។ ជាមួយគ្នានេះ នាងមានអារម្មណ៍ថាចង់គេងយូរ, ខ្ជិលធ្វើការ, និងមានសុខភាពមិនសូវល្អដូចពីមុនឡើយ។

កញ្ញា ឈុន បូរមី បានបន្ថែមថា ៖ «ពេលនោះធ្វើឲ្យខ្ញុំចាប់ផ្តើមគិតគូរឡើងវិញអំពីកត្តា និងមូលហេតុដែលធ្វើឲ្យខ្ញុំឡើងគីឡូយ៉ាងគំហុកនេះ។ បន្ទាប់ពីការសិក្សាស្វែងយល់លើសារៈសំខាន់ និងគុណតម្លៃនៃការហាត់ប្រាណ និងរបបអាហារសុខភាពមក ខ្ញុំបានប្តេជ្ញាចិត្តអនុវត្តន៍ឲ្យខាងតែបាន ដើម្បីឲ្យរូបរាងរបស់ខ្ញុំមានទម្រង់ដូចដើមវិញ»។

បន្ទាប់ពីមានការសិក្សា ស្វែងយល់ច្បាស់ហើយ យុវតីរូបនេះ ក៏បានដាក់វិន័យចំពោះខ្លួនឯងយ៉ាងតឹងរឹង ដោយចាប់ផ្តើមហាត់ប្រាណយ៉ាងទៀងទាត់ ជាពិសេសឆ្លៀតហាត់ប្រាណពេលព្រឹកមុនចេញមកធ្វើការ និងពេលល្ងាចបន្ទាប់ពីចេញកន្លែងធ្វើការវិញ ព្រមទាំងឆ្លៀតពេលហាត់ប្រាណនៅចុងសប្តាហ៍ផងដែរ។

តាមការសិក្សានាពេលថ្មីៗនេះបានរកឃើញថា ក្រៅពីធ្វើឲ្យរាងកាយមាំមួនមានសុខភាពល្អ ការហាត់ប្រាណ និងការរស់នៅ បែបសកម្មអាចកាត់បន្ថយការប្រឈមនឹងជំងឺបាក់ទឹកចិត្តបានរហូតដល់ពីរភាគបី។ នេះជាលើកឡើងរបស់រដ្ឋលេខាធិការក្រសួងសុខាភិបាល លោកស្រី ប្រាក់ សោភ័ណនារី។








លោកស្រីមានប្រសាសន៍ថា ៖ «អ្នកស្រាវជ្រាវដែលបានធ្វើការវាយតម្លៃទៅលើការសិក្សាចំនួន ៤៩ មកពីទូទាំងពិភពលោកបានរកឃើញថាអ្នកដែលធ្វើសកម្មភាពរាងកាយ ច្រើនបំផុតទំនងជាមិនសូវមានបញ្ហាបាក់ទឹកចិត្តច្រើនដូចអ្នកដែលធ្វើសកម្មភាពតិចតួចបំផុតឡើយ»។

ចំណែក អគ្គលេខាធិការក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ សុខ ស៊ីឡូ បានឱ្យដឹងថា ការសម្រេចបាននូវការកាត់បន្ថយបរិមាណកាឡូរីតាមរយៈការផ្លាស់ប្តូររិជ្ជមាននូវរបបអាហារគឺជាគន្លឹះសម្រាប់ការទប់មិនឲ្យរាងកាយឡើងទម្ងន់ខ្លាំង ដែលនាំឱ្យមានហានិភ័យខ្ពស់ដល់សុខភាព។

លោកមានប្រសាសន៍ថា ៖ «ការសិក្សាជាច្រើនបានបង្ហាញថា នៅពេលដែលរាងកាយយើងមានភាពសកម្មជាប្រចាំ រួមជាមួយនឹងការអនុវត្តន៍របបអាហារសុខភាពបានទៀងទាត់ អាចជួយកាត់បន្ថយហានិភ័យនៃជំងឺបេះដូង, ជំងឺលើសឈាម, លើសជាតិស្ករនិងខ្លាញ់, ជួយបង្កើនសាច់ដុំរាងកាយ, និងធ្វើឱ្យសុខភាពផ្លូវកាយនិងសុខភាពផ្លូវចិត្តរបស់យើងម្នាក់ៗមានលក្ខណៈប្រសើរឡើង»។

អង្គការសុខភាពពិភពលោកក៏បានបញ្ជាក់ថា ការហាត់ប្រាណបានទៀងទាត់អាចជួយការពារ និងគ្រប់គ្រងជំងឺទឹកនោមផ្អែម, ជំងឺបេះដូង, ជំងឺមហារីក និងជំងឺផ្សេងៗទៀតបានយ៉ាងល្អ។ ការធ្វើឲ្យរាងកាយមានភាពសកម្មភាពក៏អាចកាត់បន្ថយជំងឺបាក់ទឹកចិត្ត និងការថប់បារម្ភ ព្រមទាំងពង្រឹងស្មារតី, បង្កើនលទ្ធភាពរៀនសូត្រ ប្រសិទ្ធភាពការងារនិងលើកកម្ពស់សុខុមាលភាពទូទៅរបស់មនុស្ស។

ជាមួយគ្នានេះដែរ លោកស្រី Sanne Sigh តំណាងគម្រោង MUSEFO នៃអង្គការ GIZ បានប្រាប់ដែរថារបបអាហារដែលមានសុខភាពល្អរួមមាន ការលាយបញ្ចូលគ្នានៃបន្លែ និងផ្លែឈើ ត្រី ស៊ុត សាច់ គ្រាប់ធញ្ញជាតិ និងគ្រាប់ធញ្ញជាតិ។

លោកស្រីមានប្រសាសន៍ថា ៖ «មិនត្រឹមតែរបបអាហារមានសារៈសំខាន់ប៉ុណ្ណោះទេ ប៉ុន្តែសកម្មភាពរាងកាយក៏មានសារសំខាន់ខ្លាំងដែរ។ នៅពេលយើងគិតអំពីសកម្មភាពរាងកាយ យើងតែងតែគិតថាយើងត្រូវរត់ម៉ារ៉ាតុង ឬជិះកង់ចម្ងាយ៥០ គីឡូម៉ែត្រ។ ប៉ុន្តែសកម្មភាពរាងកាយត្រូវបានកំណត់ដោយ WHO ដូចជាចលនារាងកាយណាមួយដោយសាច់ដុំរបស់យើងដែលត្រូវការថាមពល»។

កញ្ញា ឈុន បូរមី ក៏បានបញ្ជាក់ទៀតថា នាងក៏បានអនុវត្តកាត់បន្ថយក្នុងការញ៉ាំអាហារដែលមិនមាសុខភាពល្អផងដែរ ដូចជា ភេសជ្ជៈដែលផ្អែមខ្លាំង, អាហារកញ្ចប់ និងអាហារ fast foods ជាដើម ដែលពីមុននាងតែងតែញ៉ាំតាមការឃ្លាន ញ៉ាំគ្រប់ពេលវេលា និងគ្រប់ទីកន្លែងទាំងអស់។

កញ្ញាថា ៖ «បន្ទាប់ពីការអនុវត្តន៍យ៉ាងម៉ឺងម៉ាត់ និងជាប្រចាំ គីឡូរបស់ខ្ញុំបានស្រកចុះជាបណ្តើរៗ ពី៦៨ មកត្រឹម៦១ គីឡូដែលផ្តល់ក្តីសង្ឃឹមជាថ្មីឡើងវិញ។ ការធ្វើលំហាត់ប្រាណ និងរបបអាហារសុខភាព មិនត្រឹមតែធ្វើឲ្យយើងមានសុខភាពល្អខាងផ្នែករាងកាយប៉ុណ្ណោះទេ តែក៏ធ្វើឲ្យយើងមានសុខភាពល្អខាងផ្លូវចិត្តផងដែរ»៕

# ប្រេងសម្រាប់អ្នកជំងឺ ផ្តល់កម្លាំងមកពីព្រះវិញ្ញាណ

*អត្ថបទ៖ រឿន ស្រីម៉ាច*











ព្រះសហគមន៍ក្រុងកំពង់ចាមនាព្រឹកថ្ងៃអាទិត្យទី២៤ ខែកក្កដា ឆ្នាំ២០២២កន្លងទៅនេះបានប្រារព្ធពិធីលាបប្រេងជូនអ្នកជំងឺ និងចាស់ជរា ដើម្បីផ្តល់កម្លាំង សេចក្តីសង្ឃឹមពីព្រះវិញ្ញាណដ៏វិសុទ្ធ និងកម្លាំងយ៉ាងពិសេសពីព្រះជាម្ចាស់ដើម្បីឈ្នះសេចក្តីអាក្រក់ ទុក្ខកង្វល់ អំពើបាប និងភាពទន់ខ្សោយទាំងឡាយនៅក្នុងជីវិតប្រចាំថ្ងៃ។

លោកបូជាចារ្យស្ទេផាន សែ សាត បូជាចារ្យជនជាតិខ្មែរសព្វថ្ងៃទទួលខុសត្រូវព្រះសហគមន៍ក្រុងកំពង់ចាម និងព្រះសហគមន៍មួយចំនួនក្នុងតំបន់កំពង់ចាមបានឲ្យដឹងអំពីអត្ថន័យយ៉ាងសំខាន់ក្នុងពិធីលាបប្រេងសម្រាប់អ្នកជំងឺ និងមនុស្សចាស់ថា៖ «ក្នុងព្រះសហគមន៍ពីដើមប្រេងសម្រាប់អ្នកជំងឺនេះគឺគេតែងហៅថាប្រេងបង្ហើយ គឺលាបនៅពេលដែលអ្នកជំងឺ ឬចាស់ជរាមានសភាពធ្ងន់ធ្ងរ អាចនិយាយបានថាជិតផុតដង្ហើម តាមរបៀបគ្រីស្តសាសនាការលាបប្រេងនេះគឺដើម្បីឲ្យគាត់មានចិត្តស្ងប់ និងមានកម្លាំង សេចក្តីសង្ឃឹមចំពោះព្រះជាម្ចាស់ និងព្រះវិញ្ញាណដ៏វិសុទ្ធជានិច្ច។

លោកបូជាចារ្យរូបនេះបន្ថែមទៀតថា៖«សព្វថ្ងៃព្រះសហគមន៍បានដូរអត្ថន័យ ឬរបៀបហៅបន្តិចដោយប្រែពីពាក្យថា «ប្រេងបង្ហើយ» មកជា «ប្រេងផ្តល់កម្លាំង» វិញដើម្បីងាយស្រួលយល់ និងមានន័យពិរោះជាង ព្រោះប្រេងនេះគឺជាម្លាំងដែលមកពីព្រះវិញ្ញាណ ជាកម្លាំងដែលមកពីព្រះជាម្ចាស់ដើម្បីឲ្យអ្នកដែលបានទទួលឈ្នះអស់សេចក្តីអាក្រក់។ប្រេងនេះគឺបង្ហាញអំពីអគ្គសញ្ញាលើកលែងទោស រំដោះបាប រំដោះទុក្ខលំបាកដែលគាត់កំពុងមាន»។

រាល់ឆ្នាំព្រះសហគមន៍កាតូលិកកម្ពុជាតែងតែប្រារព្ធពិធីបុណ្យប្រសិទ្ធពរលើប្រេងដែលមាន៣ប្រភេទផ្សេងគ្នាគឺ៖១ប្រេងសម្រាប់អ្នកស្វែងយល់ ២ប្រេងសម្រាប់អគ្គសញ្ញាតែងតាំង(ប្រេងគ្រីស្មារ) និងទី៣គឺជាប្រេងសម្រាប់អ្នកជំងឺ ហើយប្រេងទាំង៣ប្រភេទនេះលោកអភិបាលព្រះសហគមន៍កម្ពុជានឹងធ្វើការចែកចាយទៅលោកអភិបាលតាមភូមិភាគនីមួយៗដើម្បីបញ្ជូនបន្តទៅឲ្យលោកបូជាចារ្យតាមព្រះសហគមន៍ផ្សេងៗប្រើប្រាស់តាមសេចក្តីត្រូវការរបស់ព្រះសហគមន៍។

លោកបូជាចារ្យសែ សាត បានសង្កត់ធ្ងន់បន្ថែមថា៖«សម្រាប់អគ្គសញ្ញាទាំងអស់គឺសុទ្ធតែបង្ហាញអំពីសេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់! ចំណែកអគ្គសញ្ញាលាបប្រេងគឺជាសញ្ញាមួយដែលបង្ហាញអំពីសេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់ដែលនាំការសង្គ្រោះដល់មនុស្សលោកជាពិសេសដល់អ្នកដែលកំពុងមានជំងឺ។ ព្រះសគមន៍បានរៀបចំពិធីលាបប្រេងនេះឡើងគឺដើម្បីផ្តល់កម្លាំងចិត្ត ផ្តល់សេចក្តីសង្ឃឹម និងឲ្យគេដឹងថាព្រះយេស៊ូកំពុងផ្តល់កម្លាំង រួមដំណើរក្នុងទុក្ខលំបាក និងរួមជាមួយព្រះអង្គធ្វើដំណើរទៅមុខទៀតក្នុងជំនឿផងដែរ។

អ្នកស្រី លុយ ផល្លី វ័យ៧៣ឆ្នាំ រស់នៅក្នុងភូមិកោះចាស់ ឃុំកោះមិត្ត ស្រុកកំពង់សៀម ខេត្តកំពង់ចាមជាគ្រីស្តបរិស័ទនៅព្រះសហគមន៍ក្រុងកំពង់ចាមបានឲ្យដឹងថា៖«ខ្ញុំមានអារម្មណ៍រំភើប និងសប្បាយរីករាយយ៉ាងខ្លាំងដោយសារខានមកព្រះវិហារជាមួយខែថ្ងៃមកហើយដោយសារមានជំងឺធ្ងន់ធ្ងរត្រូវព្យាបាលជាបន្ទាន់!ហើយក្នុងពេលនេះគឺបានមកព្រះវិហារវិញ និងបានទទួលប្រេងពីលោកឪពុកសាតគឺណែនាំ ឲ្យខ្ញុំកាន់តែមានកម្លាំងកាយ កម្លាំងចិត្តបន្ថែមទៀត ហើយជាពិសេសបង្ហាញឲ្យខ្ញុំឃើញថា ព្រះសហគមន៍រួមជាមួយគ្រីស្តបរិស័ទមិនបាន បោះបង់ចោលខ្ញុំនោះទេ ជាពិសេសគឺព្រះយេស៊ូដែលតែងតែស្រឡាញ់ និងផ្តល់កម្លាំងឲ្យខ្ញុំជានិច្ច។

អ្នកស្រី ផល្លីបានបន្ថែមថា៖«ក្នុងគ្រាដែលខ្ញុំកំពុងមានជំងឺ ខ្ញុំពុំមានសង្ឃឹមថានឹងមានជីវិតរស់នៅបន្តរនោះទេ គឺដោយសារជំនឿលើព្រះយេស៊ូធ្វើឲ្យខ្ញុំដឹងថា ព្រះអង្គទ្រង់បានសង្គ្រោះខ្ញុំ និងដឹកដៃខ្ញុំ រហូតមកទល់ពេលនេះខ្ញុំបានធូរស្បើយច្រើនគឺតាំងពីដេកនៅនឹងកន្ទេល រហូតអាចក្រោកអង្គុយ និងគេអបដើរបានខ្លះៗ ខ្ញុំតែងអធិដ្ឋានជាប់ជានិច្ច ហើយនេះគឺជាការសង្គ្រោះរបស់ព្រះអង្គឲ្យខ្ញុំមានកម្លាំងចិត្តខំប្រឹងជំនះដោយសេចក្តីសង្ឃឹមលើខ្ញុំពិតៗ ខ្ញុំសូមអរព្រះគុណព្រះអង្គ។

ចំណែកអ្នកស្រី គឹម សុង វ័យ បានប្រាប់ពីអារម្មណ៍របស់ខ្លួនថា៖ «ពេលលោកឪពុកប្រាប់ថាការលាបប្រេងនោះគឺជាប្រេងបង្ហើយ» ធ្វើឲ្យខ្ញុំមានអារម្មណ៍ថាភ័យខ្លួនដោយសារថាសភាពយើងចាស់ហើយសុខភាពក៏មិនសូវល្អ ខ្លាចថាលាបប្រេងនោះហើយគឺទៅតែម្តង តែក្រោយបានស្តាប់ការពន្យល់ និងធម្មទេសនារបស់លោកពេលថ្វាយអភិបូជារួចធ្វើឲ្យខ្ញុំកាន់តែយល់ច្បាស់ថាតាមពិតប្រេងនោះគឺជាប្រេងសម្រាប់អ្នកជំងឺមែនតែសម្រាប់ផ្តល់កម្លាំងយ៉ាងពិសេសពីព្រះជាម្ចាស់សម្រាប់យើងដែលជាអ្នកទន់ខ្សោយ ឲ្យមានសេចក្តីសង្ឃឹម និងជំនឿកាន់តែរឹងមាំឡើង។

ស្រ្តីវ័យចំណាស់ដែលមានជំនឿយ៉ាងមុតមាំនៅព្រះសហគមន៍ភូមិថ្មី និងពីមុនរស់នៅដែលមានទីលំនៅក្នុងភូមិថ្មី ឃុំរំចេក ស្រុកកំពង់សៀម ខេត្តកំពង់ចាម សព្វថ្ងៃមករស់នៅជាមួយកូនប្រុសដែលមានទីលំនៅក្នុក្រុងកំពង់ចាម លោកអ៊ុំប្រាបថា៖«ខ្ញុំមានអំណរសប្បាយដោយសាររាល់ថ្ងៃអាទិត្យយើងជាគ្រីស្តបរិស័ទបានជួបជុំគ្នា បានឃើញបងប្អូនខ្លះបានធូស្បើយពីជំងឺ និងអ្នកខ្លះមានទឹកមុខញញឹម សួរសុខទុក្ខគ្នាទៅវិញទៅមកនេះបង្ហាញថាយើងជាបងប្អូនក្នុងមហាគ្រួសារតែមួយក្នុងព្រះសហគមន៍ពិតមែន ខ្ញុំឲ្យបងប្អូនបន្តមកព្រះវិហារ និងរក្សាជំនឿ ជាពិសេសការបញ្ជូនបន្តរជំនឿសម្រាប់អ្នកជំនាន់ក្រោយ»។

ក្នុងពិធីថ្វាយអភិបូជានោះមានគ្រីស្តបរិស័ទអ្នកជំងឺ និងមនុស្សចាស់ប្រមាណ៥០នាក់មកពីព្រះសហគមន៍ក្រុងកំពង់ចាម ព្រះសហគមន៍បុសខ្នុរ និងរលៀក បន្ទាប់ពីពីបញ្ចប់អភិបូជាក៏មានកម្មវិធីរាំលេងកម្សាន្ត និងទទួលទាន់អាហាររួមគ្នាយ៉ងសប្បាយរីករាយ។

ព្រះសហគមន៍កាតូលិកក្រុងកំពង់ចាមមានទីតាំងស្ថិតនៅផ្លូវ១៨៤ ភូមិទី១ សង្កាត់វាលវង់ក្រុងកំពង់ចាម ខេត្តកំពង់ចាម ទទួលខុសត្រូវដោយលោកបូជាចារ្យស្ទេផាន សែ សាត ៕

# បុរសជនជាតិខ្មែរពូណងក្លាយជាបូជាចារ្យកាតូលិក





*អត្ថបទ៖ កែវ កញ្ញា*

ក្បួនដង្ហែលាយឡំជាមួយតន្ត្រីនិងសំឡេងគងរបស់ខ្មែរភាគតិចពូណងបានលាន់ឮរំពងឡើងប្រមាណជា១គីឡូដី ដែលអមដោយរបាំក្មេងនាំមុខឈើឆ្កាងបូជាចារ្យនិងលោកអភិបាលដើម្បីនាំយុវជនជាតិពូណងម្នាក់មកថ្វាយព្រះជាម្ចាស់។

«ជាបូជាចារ្យគឺត្រូវបម្រើ បូជាជីវិត និងធ្វើអត្តសញ្ញាដល់បងប្អូន។» នេះជាការបញ្ជាក់របស់លោកប្រាក់ប៊ុនហុង ជាឧបដ្ឋាក ដែលបានតែងតាំងក្លាយជាបូជាចារ្យកាតូលិកក្នុងថ្ងៃទី២៩ខែមិថុនានេះ។

នៅក្នុងខែមិថុនាជាពេលវេលាដែលព្រះសហគមន៍តែងតាំងបូជាចារ្យ។ លោកអភិបាលអូលីវីយេ៉ឝ្មីតហាស្លេអភិបាលព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញបញ្ជាក់អំពីរឿងនេះ។ លោកបន្ថែមថានៅពេលនេះការប្រកាសដំណឹងល្អនៅទីដាច់ស្រយាលគឺមានរូបរាងហើយ។

ពិធីតែងតាំងនេះត្រូវបានប្រារព្ធឡើងនៅព្រះវិហារសន្តយ៉ូហានបាទីស្តនៅព្រះសហគមន៍ប៊ូស្រាក្នុងស្រុកពេជ្រាដា ខេត្តមណ្ឌលគិរី ដែលស្ថិតក្នុងភាគឦសាន្តនៃប្រទេសកម្ពុជាប្រមាណជាង៥០០គីឡូម៉ែត្រពីទីក្រុងភ្នំពេញ។

តំបន់នេះភាគច្រើនមានខ្មែរជនជាតិភាគតិចពូណងរស់នៅ។ លោកបូជាចារ្យប៊ុនហុងដែលមានកំណើតមកពីព្រះសហគមន៍នេះ បានឲ្យដឹងទៀតថា «ព្រះជាម្ចាស់បានត្រាស់ហៅខ្ញុំនិងញែកខ្ញុំចេញពីគេចូលទៅក្នុងក្រុមរបស់ព្រះអង្គ គឺក្រុមបូជាចារ្យដើម្បីបម្រើព្រះអង្គនិងព្រះសហគមន៍។»

លោកបូជាចារ្យថ្មី បន្ថែមថា «ព្រះអង្គបានប្រទានពរដល់ខ្ញុំតាមរយៈលោកអភិបាលអូលីវីយេ៉ឲ្យខ្ញុំមានកំលាំងខ្លាំងដើម្បីបម្រើព្រះសហគមន៍ទៅថ្ងៃមុខ។»

ព្រះវិហារសន្តយ៉ូហានបាទីស្តនៃព្រះសហគមន៍ប៊ូស្រា ដោយមានជនជាតិដើមភាគតិចពូណងចំនួន១៥គ្រួសារ បានផ្លាស់ប្ដូរជំនឿរបស់ខ្លួននៅប្រទេសវៀតណាម ក្នុងពេលភៀសខ្លួនដោយសារសង្គ្រាម។ ក្រោយមកក៏បានវិលត្រឡប់មកកាន់ប្រទេសកម្ពុជាវិញ ដោយមាន១០គ្រួសារតាំងលំនៅនៅប៊ូស្រា និង៥គ្រួសារទៀតតាំងលំនៅនៅដាក់ដាំ។

ក្នុងឆ្នាំ១៩៩៦ មានយុវជនស្ម័គ្រចិត្តជាតិបារាំងបានទៅដល់ប៊ូស្រា និងបានរកឃើញគ្រីស្តបរិស័ទនៅទីនោះ ហើយបន្តបន្ទាប់មកទៀតក៏មានបូជាចារ្យទៅសួរសុខទុក្ខនិងថ្វាយអភិបូជាយូរៗម្តង។ បច្ចុប្បន្នព្រះសហគមន៍ប៊ូស្រាមានគ្រីស្តបរិស័ទប្រមាណជាង១០០នាក់ ដែលភាគច្រើនជាអ្នកធ្វើស្រែនិងចម្ការជាជនជាតិខ្មែរភាគតិចពូណង។ ក្នុងព្រះសហគមន៍នេះ ក៏មានយុវនារីម្នាក់បានក្លាយខ្លួនជាដូនជី ក្នុងក្រុមស្រឡាញ់ឈើឆ្កាងព្រះយេស៊ូផងដែរ។

ក្នុងវ័យជា៧៥ឆ្នាំ ជាជនជាតិដើមភាគតិចដែលបានចាប់ផ្តើមព្រះសហគមន៍នៅទីនេះ ជាមួយគ្រួសារចំនួន៥ទៀត លោកព្រី ត្រេ បានឲ្យដឹងអំពីមូលហេតុនៃការផ្លាស់ប្តូរជំនឿថា៖ «យើងជាបងប្អូនជនជាតិកាលនោះ យើងអត់មានអ្វីសែនព្រេន ហើយឃើញការរស់នៅរបស់បងប្អូនគ្រីស្តបរិស័ទល្អ មានការរាប់អាន ហើយ(ជំនឿនេះ)យើងអាចតាមគេបាន»។

ក្នុងធម្មទេសនា លោកអភិបាលអូលីវីយេ៉មានប្រសាសន៍ថា ព្រះវិញ្ញាណនាំយើងទៅប្រកាសដំណឹងល្អ អោយយើងប្រកាសជំនឿ ហើយណែនាំអោយថ្ងៃនេះ «ហុងអាចឆ្លើយតបនឹងព្រះជាម្ចាស់និងរួមជាមួយព្រះសហគមន៍ដើម្បីប្រកាសដំណឹងល្អដោយមានគោលដៅតែមួយ គឺដើម្បីអោយបងប្អូនស្គាល់ការសង្គ្រោះ អោយជីវិតយើងចូលក្នុងជីវិតអស់កល្បជានិច្ច។»

លោកអភិបាលព្រះសហគមន៍មានប្រសាសន៍ទៀតថា ការងារនិងតួនាទីរបស់បូជាចារ្យទាំងអស់គឺ«គ្មានអាណត្តិដូចគេទេ។ គឺបូជាចារ្យ(រស់នៅនិងបម្រើ)ជាប់នឹងព្រះជាម្ចាស់អស់មួយជីវិត។»

ក្នុងពិធីនេះ មានបូជាចារ្យមកពី៣ភូមិភាគសរុប ៥២នាក់ ហើយក្នុងឱកាសនោះដែរ លោកអភិបាលស្នើសុំឲ្យលោកបូជាចារ្យគ្រប់រូបជួយលើកទឹកចិត្ត ស្វាគមន៍ ធ្វើជាគំរូ ជាបងរបស់លោកបូជាចារ្យថ្មីនិងរស់នៅក្នុងភាតរភាពទៅជាគ្រួសារមួយពិសេសក្នុងអង្គព្រះយេស៊ូគ្រីស្ត ជាធ្លុងតែមួយដូចព្រះបិតា ព្រះបុត្រានិងព្រះវិញ្ញាណដ៏វិសុទ្ធដែលជាអង្គតែមួយ។

លោកអភិបាលបញ្ជាក់ថាលោកបូជាចារ្យមានកិច្ចការ៣ដែលសំខាន់គឺ រស់ជាមួយគ្នាដោយធ្វើដំណើរជាមួយគ្នាក្នុងអង្គព្រះយេស៊ូគ្រីស្ត បម្រើព្រះបន្ទូលដោយប្រកាសដំណឹងល្អគឺឲ្យគេស្គាល់ព្រះបន្ទូលហើយអោយបន្ទូលទៅដល់មនុស្សឯទៀតៗដើម្បីឲ្យគេស្គាល់ព្រះយេស៊ូ និងត្រូវធ្វើអត្តសញ្ញាផ្សេងរបស់ព្រះជាម្ចាស់ដើម្បីនាំឲ្យគ្រីស្តបរិស័ទក្លាយជាប្រជារាស្ត្រដ៏វិសុទ្ធរបស់ព្រះជាម្ចាស់និងឲ្យជីវិតរបស់ព្រះជាម្ចាស់មាននៅក្នុងជីវិតរបស់បងប្អូន។

លោកអភិបាលបន្តថា លោកសូមអរគុណបងប្រុសហុង ដែលពេលនេះ បានសុខចិត្តលះបង់ខ្លួនថ្វាយនិងបម្រើព្រះជាម្ចាស់ ហើយក៏សូមអរគុណមហាគ្រួសារកាតូលិកនៅកម្ពុជា ដែលជាព្រះសហគមន៍តូចមែនតែមានជីវិតរស់រវើក។

លោកបូជាចារ្យប្រាក់ ប៊ុនហុង ជាបូជាចារ្យទី១០ ក្នុងចំណោមបូជាចារ្យជនជាតិខ្មែរផ្សេងៗទៀតដែលកំពុងបម្រើកិច្ចការប្រកាសដំណឹងល្អក្នុងភូមិភាគទាំងបីក្នុងប្រទេសកម្ពុជា។

និយាយអំពីគោលដៅសំខាន់នៅថ្ងៃអនាគតជាបូជាចារ្យ លោកបូជាចារ្យថ្មី ប្រាក់ប៊ុនហុង ចង់ប្រកាសដំណឹងល្អដល់មនុស្សដែលនៅជុំវិញទាំងគ្រីស្តបរិស័ទនិងមិនមែនជាគ្រីស្តបរិស័ទ ឲ្យស្គាល់ព្រះយេស៊ូកាន់តែច្បាស់និងអំពីសេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់ចំពោះពួកគេ។ លោកបន្ថែមថា «ខ្ញុំចង់ណែនាំពួកគេនិងលើកទឹកចិត្តពួកគេ អ្នកធ្លាក់ទឹកចិត្តមិនថាសាសនាណាពូជសាសន៍ណាទេ។»

ព្រះសគមន៍កាតូលិកកម្ពុជា បានកកើតក្នុងឆ្នាំ១៥៥៥ ដោយបព្វជិតជាតិប៉័ទុយហ្គាល់។ ហើយព្រះសហគមន៍នេះ បានរីកចម្រើនឡើងបន្តិចម្តងៗ តែជាអកុសលដោយសារសង្គ្រាមស៊ីវិល ជាពិសេសក្នុងរបបប្រល័យពូជសាសន៍ប៉ុលពតក្នុងឆ្នាំ១៩៧៥-១៩៧៩ ព្រះសហគមន៍ត្រូវបានបំផ្លាញគ្មានសល់ ទាំងហេដ្ឋារចនាសម្ពន្ធនិងធនធានមនុស្ស។ អស់លោកអភិបាល បូជាចារ្យ បព្វជិត-ជិតា គ្រហស្ថនិងគ្រីស្តបរិស័ទមួយភាគធំត្រូវបានស្លាប់និងសម្លាប់ ហើយសាសនទូតបរទេសត្រូវបណ្តេញចេញគ្មានសល់។

ក្រោយសង្គ្រាមចប់ គ្រីស្តបរិស័ទបានបង្រួបបង្រួមគ្នាឡើងវិញ។ ក្នុងឆ្នាំ២០០១ មានយុវជនខ្មែរ៤រូបបានតែងតាំងជាបូជាចារ្យលើកដំបូងលើទឹកដីកម្ពុជា។ ហើយព្រះសគមន៍បានខិតខំបង្កើតក្រុមនានាសម្រាប់យុវជនដើម្បីឈ្វេងយល់អំពីការត្រាស់ហៅរបស់ព្រះជាម្ចាស់ជាអ្នកបួស ដោយមានកិច្ចប្រជុំរិះគិតប្រចាំខែ ត្រីមាស និងឆ្នាំសម្រាប់ក្រុមនិងយុវន្តនិងយុវតី។

ក្នុងពេលបច្ចុប្បន្ននេះ ព្រះសហគមន៍កម្ពុជាដែលមានគ្រីស្តបរិស័ទប្រមាណ២០០០០នាក់ មានបូជាចារ្យជាតិខ្មែរចំនួន១០អង្គ និងដូនជីជិត១០នាក់៕

# ដើមឈើមួយដើម អធិដ្ឋានម្ដង

*អត្ថបទ៖ ហៀម សុកខុន*

កាលពីថ្ងៃទី២៤ កក្កដា កន្លងទៅនេះ លោកបូជាចារ្យ ផាន បូរី បានដឹកនាំ គ្រីស្តបរិស័ទព្រះសហគមន៍ កែវសីមា បានដាំដើមឈើប្រណិតៗប្រមាណ១៥០ដើម ដូចជា ក្រញូង បេង នាងនួន ជាដើម ក្នុងដីចម្ការរបស់ព្រះសហគមន៍នេះ ដែលស្ថិតនៅភូមិអូររណា ឃុំស្រែខ្ទុម ស្រុកកែវសីមា ខេត្តមណ្ឌលគិរី។

លោក បូចារ្យ ផាន បូរី បានមានប្រសាសន៍ថា ប្រភេទឈើទាំងនេះ នៅក្នុងប្រទេសកម្ពុជាកំពុងរងនូវការកាប់បំផ្លាញ និងព្រៃឈើក៏កំពុងថយចុះ ជាពិសេសឈើប្រណិតៗ ហើយការដាំដើមឈើនៅថ្ងៃនោះ គឺដើម្បីបន្សល់ទុកឲ្យកូនចៅជំនាន់ក្រោយបានស្គាល់ បានដឹង និងបានឃើញ។

លោកបន្តថា កម្មវិធីនេះ គឺគ្រីស្តបរិស័ទនៅព្រះសហគមន៍កែវសីមាបានមូលមតិគ្នារកទិញកូនឈើទាំងនេះ។

លោកបូជាចារ្យទទួលខុសត្រូវព្រះសហគមន៍នេះ ឲ្យដឹងទៀតថា ការដាំដើមឈើនេះផងដែរ គឺដើម្បីឲ្យគណៈកម្មការព្រះសហគមន៍មានសកម្មភាពរួបរួមគ្នាធ្វើអ្វីមួយ និងមានអំណរសប្បាយរួមជាមួយគ្នា។ លោកបញ្ជាក់ថា ការសាមគ្គីភាពនាំឲ្យយើងជោគជ័យនៅក្នុងព្រះសហគមន៍របស់យើង។

លោក បូជាចារ្យរូបនេះបានឲ្យដឹងថា ការដាំដើមឈើពិតជាមានសារៈសំខាន់ណាស់សម្រាប់បងប្អូនគ្រីស្តបរិស័ទ ដោយសារពេលដាំឈើមួយដើម ពួកគាត់អធិដ្ឋានទៅព្រះជាម្ចាស់។

លោកបូរីបញ្ជាក់ថា ទោះបីដើមឈើទាំងនោះមានឈ្មោះរបស់វាក៏ដោយ តែគ្រីស្តបរិស័ទបានដាក់ឈ្មោះថ្មីឲ្យពួកវា មានដូចជា«ដើមឈើនៃសន្តិភាព ដើមឈើនៃសេចក្តីសុខសាន្ត ដើមឈើនៃសុភមង្គល ដើមឈើនៃសេចក្តីស្រឡាញ់»

លោកបូជាចារ្យបូរី បានជម្រុញឲ្យគ្រីស្តបរិស័ទចេះការពារបរិស្ថាន ការពារធនធានធម្មជាតិ ដែលជាស្នាព្រះហស្តដ៏ឧត្តុងឧត្តមមកពីព្រះជាម្ចាស់។

កម្មវិធីដាំដើមឈើនៅព្រះសហគមន៍កែវ សីមា ត្រូវបានធ្វើជាលើកទី១ លើដីចម្ការរបស់ព្រះសហគមន៍ដែលមានទំហំប្រមាណ៣,៥ហិចតា សម្រាប់សាងសង់អគារសិក្សាអប់រំនិងព្រះវិហារ ធ្វើចម្ការ និងមួយផ្នែកទុកសម្រាប់ធ្វើជាព្រៃឈើប្រណិត។

លោកបូជាចារ្យបូរីបានបញ្ជាក់ថា ការចំណាយលើថ្លៃកូនឈើ និងដាំ បានមកពីការឧបត្ថម្ភពីសប្បុរសជន និងគ្រីស្តបរិស័ទនៅព្រះសហគមន៍កែវសីមាផ្ទាល់៕

# លោក សិលា សួន ហង្សលី ត្រូវបានតែងតាំងជាអភិបាលទទួលបន្ទុកភូមិភាគកំពង់ចាម

*អត្ថបទ៖ ព្រះសហគមន៍កាតូលិកភូមិភាគកំពង់ចាម*

យោងតាមលិខិតលោកអភិបាលព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញនាថ្ងៃទី១៥ ខែកក្កដា ដែលផ្សើរីតាស់អាស៊ីទទួលបាននាពេលល្ងាច បានឲ្យដឹងថា សន្តអាសនៈនៃបុរីវ៉ាទីកង់ បានជ្រើសតាំងលោកសិលា សួន ហង្សលី ជាអភិបាលទទួលបន្ទុកមើលការខុសត្រូវព្រះសហគមន៍កាតូលិកភូមិភាគកំពង់ចាម។

តាមរយៈលិខិតដដែល លោកអភិបាលអូលីវីយេ ឆ្មីតហាស្លេបានបញ្ជាក់ថា នៅថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០២២នេះ លោកត្រូវបានជ្រើសតាំងដោយសម្ដេចប៉ាបហ្វ្រង់ស៊ីស្ហ ឲ្យក្លាយជាលោកអភិបាលមើលការខុសត្រូវនៅក្នុងភូមិភាគកំពង់ចាមទាំងមូល។

ព្រះសហគមន៍ភូមិភាគកំពង់ចាម គ្របដណ្ដប់ខេត្តចំនួន៨ មានដូចជា កំពង់ចាម ព្រៃវែង ក្រចេះ ស្ទឹងត្រែង មណ្ឌលគិរី រតនគិរី ត្បូងឃ្មុំ និងស្វាយរៀង។

លោកអភិបាលអូលីវីយេឲ្យដឹងថា លោកនិងលោកអភិបាលថ្មីធ្លាប់បានរួមការងារជាមួយគ្នាក្នុងឆ្នាំ២០០២-២០០៧ នៅមណ្ឌលសកម្មភាពកំពត-តាកែវ។ ក្នុងឆ្នាំ២០០៧-២០១៥ លោកហង្សលី បានទៅបន្តការសិក្សាអនុបណ្ឌិតនៅប្រទេសបារាំង ផ្នែកទេវវិទ្យានៅវិទ្យាស្ថានកាតូលិកនៃទីក្រុងប៉ារីស។

លោកបូជាចារ្យហង្សលីពេលបច្ចុប្បន្នកំពុងបម្រើការងារនៅក្នុងព្រះសហគមន៍ភូមិភាគភ្នំពេញ ជាបូជាចារ្យទទួលខុសត្រូវមណ្ឌលសកម្មភាពភ្នំពេញថ្មី និងជាតំណាងពេញសិទ្ធិរបស់លោកអភិបាលភូមិភាគភ្នំពេញក្នុងឆ្នាំ២០១៦ និងជានាយកនៃទេវវិទ្យាល័យ សន្តយ៉ូហាន ម៉ារី វីយ៉ាណែរ ក្នុងឆ្នាំ២០១៨។

លោកអភិបាលសិលា សួន ហង្សលី ជាជនជាតិខ្មែរ ប្រសូតនៅក្នុងគ្រួសារគ្រីស្តបរិស័ទ នៅថ្ងៃទី១៥ ខែមេសា ឆ្នាំ១៩៧១ នៅស្រុកល្វាឯម ខេត្តកណ្ដាល។ លោកត្រូវបានតែងតាំងជាបូជាចារ្យកាតូលិកក្នុងថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០០១ ជាមួយនិស្សិតទេវវិទ្យាល័យចំនួន៣រូបផ្សេងទៀត ហើយបានបម្រើការងារក្នុងភូមិភាគភ្នំពេញរហូតមកដល់សព្វថ្ងៃនេះ។

ក្នុងសេចក្តីប្រកាសរបស់លោកអភិបាលអូលីវីយេ លោកសូមសម្ដែងការអបអរសាទរចំពោះការជ្រើសតាំងនេះ និងសូមថ្លែងអំណរគុណចំពោះវត្តមាន និងកិច្ចសហការដ៏ស្អិតរមួតរបស់លោកអភិបាលថ្មី ដែលបានខិតខំអស់ពីកំលាំងកាយចិត្ត ដើម្បីបម្រើព្រះសហគមន៍នៅក្នុងភូមិភាគភ្នំពេញកន្លងមក។

«យើងពិតជានឹកលោកណាស់ លោកអភិបាល ប៉ុន្តែយើងនឹងអធិដ្ឋានសម្រាប់បេសកកម្មថ្មីរបស់លោកក្នុងភូមិភាគកំពង់ចាម។» លោកអភិបាលអូលីវីយេបន្ថែម៕




# ម៉ារីម៉ាដាឡា ជាគំរូសម្រាប់អ្នកមានបាប

*អត្ថបទ៖ ង៉ែត សុធីរិទ្ធ*



ក្នុងពិធីរំលឹកដល់សន្តីម៉ារីម៉ាដាឡា សម្រាប់ព្រះសហគមន៍គីឡូម៉ែត្រលេខ១១ លោកបូជាចារ្យជ្រមផុង ស៊ីហារ៉ាត់ (ប៊ឺត) ជាប្រធានអភិបូជានៅថ្ងៃនោះ បានមានប្រសាសន៍ថា យើងទាំងអស់គ្នាជាមនុស្សមានបាប ដូច្នេះឱ្យយើងកែប្រែចិត្តគំនិតរបស់យើង ឱ្យយើងស្វែងរកព្រះយេស៊ូគ្រីស្ត។

លោកបូជាចារ្យអធិបតី មានបន្ថែមថា «អ្នកមានបាបបានទទួលអ្វីល្អមែនទែនពីព្រះជាម្ចាស់។ ជាក់ស្តែងនៅក្នុងព្រះគម្ពីរ អ្នកដែលបានឡើងស្ថានបរមសុខមុនគេគឺអ្នកទោស(ចោរព្រៃ) ដែលជាប់ឆ្កាងជាមួយព្រះយេស៊ូ។»

លោកបូជាចារ្យប៊ឺត បន្តថា នាងម៉ារីម៉ាដាឡា ជាស្ត្រីរកស៊ីផ្លូវភេទ ពិតមែនគាត់ជាមនុស្សមិនល្អ ប៉ុន្តែនៅពេលគាត់បានជួបព្រះយេស៊ូគ្រីស្ត គាត់បានកែប្រែចិត្តគំនិត ក្លាយជាមនុស្សថ្មី។

ជាទូទៅមនុស្សទាំងអស់មើលគ្នាតែសំបកក្រៅ ដែលខុសពីព្រះជាម្ចាស់ ព្រះអង្គគង់នៅជាមួយមនុស្សមានបាបដែរ។ លោកបានសង្កត់ធ្ងន់ថា «អស់អ្នកដែលគិតថាខ្លួនឯងល្អមែនទែន អ្នកនោះនៅឆ្ងាយពីព្រះជាម្ចាស់ ប៉ុន្តែអស់អ្នកដែលទទួលស្គាល់ថាខ្លួនជាមនុស្សមានបាប អ្នកនោះព្រះជាម្ចាស់គង់នៅជាមួយគេ។»

លោកបន្តថា ព្រះយេស៊ូយាងមកដើម្បីស្វែងរកមនុស្សមានបាប ដើម្បីឱ្យគេកែប្រែចិត្តគំនិត មិនមែនមករកមនុស្សសុចរិតទេ។

លោកសុំឲ្យគ្រីស្តបរិស័ទទាំងអស់ យកគំរូតាមនាងម៉ារីម៉ាដាឡា ដែលបានកែប្រែចិត្តគំនិតបន្ទាបខ្លួនគាត់ និងស្វែងរកព្រះជាម្ចាស់នៅក្នុងជីវិតរបស់គាត់។ ហើយទីបញ្ចប់ គាត់បានឃើញសិរីរុងរឿងរបស់ព្រះជាម្ចាស់មុនគេ។

ព្រះសហគមន៍គីឡូម៉ែត្រលេខ១១ បានជ្រើសរើសសន្តីម៉ារីម៉ាដាឡាជាសន្តឧបការីរបស់ខ្លួន ហើយជារៀងរាល់ឆ្នាំ ព្រះសហគមន៍នេះតែងប្រារព្ធពិធីនេះ នៅថ្ងៃទី២៣ ខែកក្កដា។

មុននឹងបញ្ចប់ធម្មទេសនាលោកបូជាចារ្យប៊ឺត បានដាស់តឿនគ្រីស្តបរិស័ទឲ្យចេះស្រឡាញ់គ្នា ចេះលើកលែងទោសឱ្យគ្នា។ លោកថា នេះជាអ្វីដែលសំខាន់ជាងគេសម្រាប់គ្រីស្តបរិស័ទ។

ក្នុងកម្មវិធីរំលឹកសន្តីរូបនេះ ក្នុងឆ្នាំ២០២២នេះ បានធ្វើឡើង នៅភូមិលូ សង្កាត់ស្វាយប៉ាក ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ និងមានការអញ្ជើញចូលរួមពីលោកបូជាចារ្យ រឿង ឆ័ត្រសិរី លោកឪពុក ចន ប៉េង លោកឪពុក អូហ្គូស្ទីន វន និងលោកឪពុក ជ្រមផុង ស៊ីហារ៉ាត់ (ប៊ឺត) ព្រមទាំងដែលមានគ្រីស្តបរិស័ទប្រមាណជិត១០០នាក់ ដែលមកពីតំបន់ផ្សេងៗក្នុងមណ្ឌលសកម្មភាពភ្នំពេញខាងជើង៕

# លោកស្ទេ ផានុស ត្រូវចាត់ទៅព្រះសហគមន៍ប៉ោយប៉ែត

*អត្ថបទ៖ សេង មួយ*

លោកអភិបាលទេព ច័ន្ទពិសិដ្ឋ (គីគេ) អភិបាលព្រះសហគមន៍ភូមិភាគបាត់ដំបង បានប្រកាសផ្ទេរមុខងារដល់លោកបូជាចារ្យស្ទេ ផានុស វីនណាតូ ឲ្យទទួលខុសត្រូវព្រះវិហារសន្តីម៉ារីម៉ាដាឡា នៃព្រះសហគមន៍កាតូលិកប៉ោយប៉ែត ជំនួសលោកហ្វ្រេឌ្រិចហ្វ្លរីយ៉ូស ព្រីយ៉ាឌី។

ក្នុងឱកាសបុណ្យរំលឹកសន្តីម៉ារីម៉ាដាឡា ជាឧបការិនីព្រះសហគមន៍ប៉ោយប៉ែត កាលពីថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០២២ លោកអភិបាលទេព ច័ន្ទពិសិដ្ឋបានមានប្រសាសន៍ថា ៖ «នៅថ្ងៃនេះជាថ្ងៃពិសេស យើងត្រូវអធិដ្ឋានសម្រាប់លោកស្ទេផានុស ដើម្បីឲ្យលោកជួយណែនាំព្រះសហគមន៍ក្នុងរបៀបល្អដូចលោកពីដើម និង សូមទទួលលោកផានុសដែលជាលោកឪពុកថ្មីសម្រាប់ព្រះសហគមន៍នៅទីនេះ»។

គិតចាប់តាំងពីឆ្នាំ១៩៩៩ ព្រះសហគមន៍នេះ មានលោកបូជាចារ្យ៣អង្គ ដែលបានជួយណែនាំ គឺមានលោកសិលាទម្លាប់ សុផល លោករ៉ាជេត ហាសាពូទី និងលោកហ្វ្រេឌ្រិចហ្វ្លរីយ៉ូស ព្រីយ៉ាឌី។

យុវតី ធិត គីមស៊ីង ជាប្រធានយុវជនព្រះសហគមន៍ប៉ោយប៉ែតបានលើកឡើងអំពីលោកបូជាចារ្យហ្វ្រេឌ្រិច ដែលធ្លាប់បានបម្រើព្រះសហគមន៍នេះថា លោកបានផ្តល់កម្លាំងចិត្តឲ្យគ្រីស្តបរិស័ទព្រះសហគមន៍ប៉ោយប៉ែតច្រើនណាស់ ដូចជាការពង្រឹងជំនឿដល់គ្រីស្តបរិស័ទ និងលើកទឹកចិត្តឲ្យគ្រីស្តបរិស័ទចូលរួមជាមួយព្រះសហគមន៍ និងចូលរួមអភិបូជារាល់សប្តាហ៍ផងដែរ។

យុវតី គីមស៊ីង បានបន្តថា លោកជាមនុស្សម្នាក់ដែលស្រឡាញ់ធម្មជាតិ ស្រឡាញ់បរិស្ថាន ហើយបាននាំយុវជនឲ្យដាំដើមឈើជាច្រើននៅក្នុងបរិវេណព្រះសហគមន៍ និងដឹកនាំយុវជនឲ្យមានគំនិតក្នុងការបង្កើតអ្វីៗពីធម្មជាតិ ដោយមិនប្រើប្លាស្ទិក និងជួយសម្អាតបរិស្ថានជានិច្ច។

ម្យ៉ាងវិញទៀតលោកបានជួយដោះស្រាយបញ្ហាជាច្រើនរបស់ព្រះសហគមន៍ ដូចជាជួយកសាងអគារថ្មីផងដែរ។ នេះបើតាមការបញ្ជាក់របស់គីមស៊ីង។

ចំណែក លោក សុខ ហេង ជាគណៈកម្មការព្រះសហគមន៍ប៉ោយប៉ែតលើកឡើងថាថ្ងៃនេះជាឱកាសដ៏ល្អប្រសើរសម្រាប់ពួកយើងជាគ្រីស្តបរិស័ទ នៅក្នុងទីក្រុងប៉ោយប៉ែត យើងមានអំណរសប្បាយដែលទទួលស្វាគមន៍លោកឪពុកស្ទេផានុស ដែលមកទទួលខុសត្រូវនៅទីនេះសម្រាប់ជួយដល់ព្រះសហគមន៍យើង។

លោកបន្ថែមថា ៖ «ពួកយើងសង្ឃឹមថាសម្រាប់ដំណើរទៅមុខទៀត យើងជាមួយគណៈកម្មការ គ្រីស្តបរិស័ទ បងស្រី ក៏ដូចជាលោកឪពុក យើងរួមគ្នាជាធ្លុងតែមួយ ដើម្បីបម្រើ និងបំពេញបេសកកម្មរបស់ព្រះជាម្ចាស់ ជាពិសេសយើងធ្វើតាមព្រះហឫទ័យរបស់ព្រះជាម្ចាស់ ដើម្បីឲ្យព្រះសហគមន៍កាន់តែរីកចម្រើនឡើងនៅក្នុងធម៌មេត្តារបស់ព្រះអង្គ»។

# គ្រីស្តបរិស័ទអបអរសាទរខួប២២ឆ្នាំនិង២៧ឆ្នាំ ជូនដល់លោកអភិបាលនិងបូជាចារ្យ

*អត្ថបទ៖ សេង មួយ*

គ្រីស្តបរិស័ទប្រមាណជាង៣០០នាក់បានមកជួបជុំគ្នា ដើម្បីចូលរួមអបអរសាទខួបជ្រើសតាំងជាអភិបាល២២ឆ្នាំ និង៣០ឆ្នាំជាបូជាចារ្យរបស់លោកអភិបាលទេព ច័ន្ទពិសិដ្ឋ (គីគេ) និងខួបតែងតាំងជាបូជាចារ្យ២៧ឆ្នាំ របស់លោកឪពុកទម្លាប់ សុផល ដែលធ្វើឡើងកាលពីថ្ងៃទី៤ ខែកក្កដា កន្លងទៅ នៅព្រះវិហារព្រះជាម្ចាស់លើកព្រះនាងម៉ារីឡើងស្ថានបរមសុខ នៃព្រះសហគមន៍បាត់ដំបងក្រុង ក្នុងខេត្តបាត់ដំបង។

អ្នកស្រីដាំ ប្រាជ្ញា ជាគណៈកម្មការនៃព្រះវិហារនេះ មានប្រសាសន៍ថា « ព្រះសហគមន៍យើងខ្ញុំមានសំណាងបានទទួលលោកអភិបាលមួយអង្គ ដែលជាលោកអភិបាលប្រកបដោយធម៌មេត្តាករុណា»

អង្គុយលើរទេះរុញ អ្នកស្រីប្រាជ្ញាដែលមានវ័យជាង៧០ឆ្នាំបន្ថែមថា លោកអភិបាលតែងតែគិតគូរដល់បងប្អូនទាំងអស់។ លោកស្រឡាញ់ប្រទេសខ្មែរ ស្រឡាញ់គ្រីស្តបរិស័ទខ្មែរ ជាពិសេសលោកតែងតែលើកទឹកចិត្ត និងមានទឹកមុខល្អ ញញឹមដោយក្តីស្រឡាញ់។

ជាមួយគ្នានោះដែរកញ្ញាញ៉ាក់ ស្រីល័ក្ខ សព្វថ្ងៃស្នាក់នៅផ្ទះបងស្រីលីឌី ដែលជាផ្ទះសម្រាប់ទទួលកុមារឲ្យបានរៀនសូត្រនៅសាលា បានលើកឡើងថា « សម្រាប់នាងខ្ញុំ បានឃើញលោកអភិបាលជាគំរូដ៏ល្អសម្រាប់នាងខ្ញុំ ក៏ដូចជាគ្រីស្តបរិស័ទព្រោះគាត់បានចែករំលែកនូវចំណេះដឹង សេចក្តីស្រឡាញ់ ព្រមទាំងជួយឧបត្ថម្ភដល់សិស្សក្រីក្រដែលគ្មានលទ្ធភាពក្នុងការរៀនសូត្រ និងជួយដល់ជនពិការ»

លោកអភិបាលទេពច័ន្ទពិសិដ្ឋ កើតនៅថ្ងៃទី២១ ខែកញ្ញា ឆ្នាំ១៩៥៩ លោកបានចូលរួមក្នុងក្រុមសហជីវិនព្រះយេស៊ូ (Jesuit) នៅថ្ងៃទី១៤ ខែតុលា ឆ្នាំ១៩៧៩ ហើយលោកបានទទួលអគ្គសញ្ញាតែងតាំងជាបូជាចារ្យនៅថ្ងៃទី០៤ ខែកក្កដា ឆ្នាំ១៩៩២ នៅប្រទេសអេស្ប៉ាញ។ នៅថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០០០ លោកត្រូវបានជ្រើសតាំងជាអភិបាលប្រចាំព្រះសហគមន៍កាតូលិកភូមិភាគបាត់ដំបង រហូតដល់បច្ចុប្បន្ននេះ។

ភូមិភាគបាត់ដំបងគ្របដណ្តប់ខេត្តចំនួន៩ រួមមាន ខេត្តបាត់ដំបង ខេត្តបន្ទាយមានជ័យ ខេត្តកំពង់ឆ្នាំង ខេត្តកំពង់ធំ ខេត្តប៉ៃលិន ខេត្តសៀមរាប ខេត្តឧត្តរមានជ័យ ខេត្តពោធិសាត់ និងខេត្តព្រះវិហារ។

តាមរយៈលោកប៉ូវ៉ារ៉ុផ ជាប្រធានគណៈកម្មការព្រះសហគមន៍ បានឡើងថ្លែងរំលឹកអំពីស្ថានភាពព្រះសហគមន៍ក្នុងភូមិភាគនេះ ទាំងនៅលើតំបន់ដីគោក តំបន់ទន្លេ និងតំបន់អង្គរ ដែលមានសមិទ្ធផលជាច្រើន។

សមិទ្ធផលទាំងនោះមាន សាលាមត្តេយ្យសម្រាប់ក្មេងៗ ទីកន្លែងស្នាក់នៅសម្រាប់សិស្ស និងនិស្សិត មណ្ឌលសុខភាព កន្លែងសម្រាកព្យាបាលក្មេងៗអូទីសឹម កន្លែងសម្រាប់ទទួលជនមានពិការភាពឲ្យមានជំនាញនិងរៀនចំណេះដឹងទូទៅ មណ្ឌលតម្បាញនិងកាត់ដេរសម្រាប់រកចំណូលដល់ជនក្រីក្រ មានការប្រកួតកីឡាប្រចាំឆ្នាំ (ពានរង្វាន់លោកអភិបាល Bishop cup)ដើម្បីបង្កើតភាពរីករាយ និងទំនាក់ទំនងយុវជនផ្សេង។





លោកថា ពិសេសជាងនេះទៅទៀតមានបូជាចារ្យទទួលខុសត្រូវតាមព្រះសហគមន៍ ដើម្បីបន្តជំនឿដល់អ្នកដែលកំពុងស្វែងរកព្រះយេស៊ូគ្រីស្ត និងថែរក្សាព្រះសហគមន៍ឲ្យមានជីវិតស្រស់បំព្រង។

លោកអភិបាលបានមានប្រសាសន៍ទៀតថា នៅពេលណាយើងថែនិងមានទំនាក់ទំនងជាមួយអ្នកដទៃដែលអស់សង្ឃឹម គ្មានសុខភាព គ្មានទីពឹង គឺយើងជួយអោយគេស្គាល់ព្រះភ័ក្ត្ររបស់ព្រះជាម្ចាស់ ដើម្បីឲ្យវត្តមានរបស់ព្រះអង្គទៅដល់គ្រប់កន្លែងទាំងអស់។

លោកអភិបាលបានរំលឹកដល់គ្រីស្តបរិស័ទទាំងអស់ ឲ្យកាន់ជំនឿរឹងមាំដោយមានទំនាក់ទំនងជិតស្និទ្ធជាមួយព្រះជាម្ចាស់ និងមានសង្ឃឹមជានិច្ចទៅលើព្រះយេស៊ូ។ លោកបញ្ជាក់ថា «កុំមើលជីវិតដូចលោកីយ៍នេះម្ចាស់ជីវិតរបស់យើងគឺព្រះយេស៊ូ»

ដោយមានការចូលរួមពីគ្រីស្តបរិស័ទលោកបូជាចារ្យ និងគណៈកម្មការព្រះសហគមន៍ ព្រះសហគមន៍កាតូលិកក្នុងភូមិភាគនេះ បានរីកចម្រើន។ នេះបើតាមការបញ្ជាក់របស់លោកអភិបាលទេពច័ន្ទពិសិដ្ឋ។

ក្នុងបទសំភាសន៍ជាមួយវិទ្យុវេរីតាស់អាស៊ីកាលពីថ្ងៃទី៤ ខែកក្កដា លោកអភិបាលបានមានប្រសាសន៍បន្ថែមទៀតថា៖ «ក្នុងរយៈពេល២២ឆ្នាំ ហើយ ខ្ញុំបានឃើញលទ្ធផលដ៏ល្អ។ នៅគ្រប់ព្រះសហគមន៍ យើងមានសាលាមត្តេយ្យ និងមានការឧបត្ថម្ភអាហាររូបករណ៍។ ខ្ញុំឃើញកូនៗយកឱកាសដែលឲ្យយើងទទួលបានជោគជ័យច្រើន ដែលធ្វើឲ្យព្រះសហគមន៍មានកម្លាំងច្រើន»

ចំណែកខាងផ្នែកអប់រំជំនឿ លោកបានឲ្យដឹងថា យើងមានសិក្ខាសាលាច្រើន ដើម្បីឲ្យជំនឿឲ្យមាំ ឲ្យយើងយល់អំពីព្រះគម្ពីរច្រើន។ កន្លងមកមានមនុស្សជាច្រើនបានចូលឈ្វេងយល់ក្នុងព្រះសហគមន៍។

ក្នុងមួយឆ្នាំៗ ព្រះសហគមន៍កាតូលិកភូមិភាគបាត់ដំបង មានអ្នកទទួលអគ្គសញ្ញាជ្រមុជទឹកជិត១០០នាក់។

លោកអភិបាលបានបន្ថែមថា «ខ្ញុំឃើញថាមានបងប្អូនជាច្រើនបានចូលរួមជាមួយព្រះសហគមន៍នេះជាដំណាក់កាលទៅខាងមុខដ៏ល្អ និងខ្ញុំសង្ឃឹមទៅថ្ងៃអនាគតនឹងមានការចូលរួមច្រើនជាង កុំឲ្យយើងទីពឹងពីស្រុកក្រៅច្រើនពេក»

ក្នុងនោះដែរ លោកអភិបាលព្រះសហគមន៍រំពឹងថា នឹងមានការត្រាស់ហៅច្រើនក្នុងភូមិភាគរបស់លោក។ «ខ្ញុំសង្ឃឹមថានឹងមានការត្រាស់ហៅច្រើននៅក្នុងព្រះសហគមន៍ ដើម្បីឲ្យយើងមានបងស្រីពីស្រុកខ្មែរ លោកឪពុកពីស្រុកខ្មែរ មានយុវជនចូលរួមក្នុងព្រះសហគមន៍ដោយសកម្ម»

ក្នុងថ្ងៃនោះដែរក៏មានកម្មវិធីសម្រាប់លោកឪពុកទម្លាប់ សុផល ដែលបានទទួលអគ្គសញ្ញាតែងតាំងជាបូជាចារ្យចំនួន២៧ឆ្នាំ។ លោកសុផល កើតនៅថ្ងៃទី១៨ ខែសីហា ឆ្នាំ១៩៥៣ នៅប្រទេសកម្ពុជា លោកឪពុកបានទទួលអង្គសញ្ញាតែងតាំងជាបូជាចារ្យនៅថ្ងៃទី០២ ខែកក្កដា ឆ្នាំ១៩៩៥ ។ លោកឪពុកបានមកបម្រើនៅព្រះសហគមន៍កាតូលិកភូមិភាគបាត់ដំបងរហូតមកដល់សព្វថ្ងៃនេះ។

ក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងទៅនេះ លោកបានលះបង់កម្លាំងកាយចិត្ត យ៉ាងសកម្ម និងយ៉ាងជិតស្និតក្នុងការណែនាំបង្រៀនប្រៀនប្រដៅទំនាក់ទំនងជាមួយបងប្អូន ជាពិសេសលោកបានបម្រើបងប្អូននៅក្នុងព្រះសហគមន៍ ទោះបីពេលនេះលោកមានសុខភាពមិនសូវល្អ ប៉ុន្តែលោកមានចិត្តក្លាហានក្នុងការណែនាំ ប្រឹងប្រែងអស់ពីសមត្ថភាពក្នុងការបង្រៀនព្រះគម្ពីរ បង្កើតទំនាក់ទំនងល្អលើទឹកចិត្តអ្នកទន់ខ្សោយ អ្នករួមការងារ ទោះបីមានការលំបាកក្នុងការធ្វើដំណើរយ៉ាងណាក៏ដោយ៕

# ព្រះសហគមន៍កាតូលិក ភ្ញាក់ផ្អើលអំពីរបាយការណ៍ ជួញដូរមនុស្ស និងចំណាត់ថ្នាក់អាមេរិក

*អត្ថបទ៖ កែវ កញ្ញា*

មន្ត្រីជាន់ខ្ពស់របស់ព្រះសហគមន៍កាតូលិកនៅកម្ពុជា បានសម្តែងការស្រងាកចិត្តនិងភ្ញាក់ផ្អើលអំពីការដាក់ចំណាត់ថ្នាក់របស់ប្រទេសកម្ពុជានៅលំដាប់ថ្នាក់លេខ៣នៃអំពើជួញដូរមនុស្សរបស់សហរដ្ឋអាមេរិកដែលបានចេញផ្សាយកាលពីពេលថ្មីនេះ ហើយបាននិយាយថា ជារឿងនយោបាយរបស់អាមេរិក។

លោក ដួង សារវង់ ជាសមាជិកម្នាក់ក្នុងគណៈកម្មការអន្តរសាសនា តំណាងព្រះសហគមន៍កាតូលិកនៅកម្ពុជា បានលើកឡើងថា ចំណាត់ថ្នាក់នេះ ប្រហែលមាននិន្នាការនយោបាយច្រើនជាង ហើយការផ្ទៀងផ្ទាត់ចំពោះដំណើរការនៃរបាយការណ៍នេះ ក៏មិនដឹងថាមានលក្ខណៈបែបណាដែរ។

លោកឲ្យដឹងទៀតថា «សហរដ្ឋអាមេរិកកំពុងមាននយោបាយ ចង់គាបព្រះរាជាណាចក្រកម្ពុជាយើង។ ដោយអាមេរិកកំពុងគិតថា កម្ពុជាយើងជាប់ទាក់ទងជាមួយចិន» ហើយគោលនយោបាយរបស់គេ គឺកំពុងមាននយោបាយប្រឆាំងជាមួយចិន។

របាយការណ៍ជួញដូរមនុស្សកម្ពុជាឆ្នាំ២០២២ ចេញដោយក្រសួងការបរទេសអាមេរិក នៅថ្ងៃទី២០ កក្កដា បានវាយតម្លៃថា រដ្ឋាភិបាលកម្ពុជាមិនបានបំពេញតាមស្តង់ដារអប្បបរមា ក្នុងការប្រឹងប្រែងលុបបំបាត់ការជួញដូរមនុស្សនោះទេ។ របាយការណ៍បង្ហាញថា កម្ពុជាដើរថយក្រោយក្នុងការលុបបំបាត់ការជួញដូរមនុស្សដោយសារបញ្ហាអំពើពុករលួយជាប្រព័ន្ធ ដែលបានរារាំងដល់ការអនុវត្តច្បាប់ បណ្តោយឱ្យជនល្មើសនៅតែអាចប្រព្រឹត្តបទល្មើស ឬគេចខ្លួនពីការកាត់ទោស ហើយជនរងគ្រោះនៅតែមិនអាចទទួលបានការជួយសង្គ្រោះ។

របាយការណ៍ក៏បានបង្ហាញថា រដ្ឋាភិបាលកម្ពុជាមិនបានផ្តល់ការគាំទ្រគ្រប់គ្រាន់ដល់ជនរងគ្រោះទាំងក្នុងស្រុក និងបរទេសពីការជួញដូរនោះទេ ដោយបានពឹងផ្អែកស្ទើរទាំងស្រុងពីម្ចាស់ជំនួយបរទេស និងអង្គការក្រៅរដ្ឋាភិបាលទៅវិញ។

លោកសារវង់បន្ថែមថា រាល់ឆ្នាំ មានទិវាជាច្រើនដើម្បីដាស់ស្មារតីប្រជាជនឲ្យចូលរួមប្រយុទ្ធប្រឆាំង។ ហើយរដ្ឋាភិបាលកម្ពុជាក៏មានការខិតខំកែទម្រង់ ដើម្បីលុបបំបាត់ការជួញដូរមនុស្ស។ ជាមួយគ្នានេះដែរ រដ្ឋាភិបាលក៏បានជម្រុញឲ្យសាសនានៅក្នុងប្រទេស រួមគ្នាប្រឆាំងការជួញដូរដែរ។

លោកបានលើកឡើងទៀតថា លោកបានចូលរួមក្នុងកិច្ចប្រជុំជាច្រើនដែលរៀបចំឡើងដោយអន្តរសាសនាជាមួយរដ្ឋាភិបាល ដែលបាននិយាយអំពីការជួញដូរមនុស្សមានទាំងកំលាំងពលកម្មសរីរាង្គរបស់មនុស្សជាដើម។ លោកបញ្ជាក់ថា «ខ្ញុំដឹងថា ក្រសួងមហាផ្ទៃបានធ្វើការយ៉ាងច្រើនជាមួយប្រទេសនានាដែលពាក់ព័ន្ធក៏ច្រើនដែរ»

លោកបន្ថែមថា «ដូច្នេះ តាមខ្ញុំគិត ជាបញ្ហានយោបាយជាងលទ្ធផលដែលរដ្ឋាភិបាលនិងព្រះរាជាណាចក្រកម្ពុជាយើងបានធ្វើ»

ជាមួយគ្នានេះដែរ ក្រសួងការបរទេសអាម៉េរិកទទួលបន្ទុកប្រយុទ្ធប្រឆាំងនឹងការជួញដូរមនុស្ស បានដាក់ប្រទេសវៀតណាម កម្ពុជា ប្រ៊ុយណេ និងម៉ាកាវ ក្នុងបញ្ជីខ្មៅជួញដូរមនុស្សដោយរាប់ប្រទេសម៉ាឡេស៊ីផងដែរ ដោយចោទប្រកាន់ថា ប្រទេសទាំងនេះ មិនប្រឹងប្រែងក្នុងការបញ្ឈប់ការងារផ្លូវភេទដោយបង្ខំ ឬជួយពលករចំណាកស្រុក។

លោកស្រី ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍នៃគណៈកម្មាធិការជាតិប្រយុទ្ធនឹងការជួញដូរមនុស្ស បានថ្លែងប្រាប់អ្នកសារព័ត៌មាន នារសៀលថ្ងៃទី ២១ ខែកក្កដានេះ ថា «យើងតែងតែសង្ឃឹមថាឆ្នាំនេះ យើងនឹងទទួលបានចំណាត់ថ្នាក់ល្អ យើងមានកិច្ចសហការពីស្ថានទូតសហរដ្ឋអាមេរិកប្រចាំកម្ពុជា ដែលកន្លងមកយើងនឹង ធ្វើការជិតស្និទ្ធជាមួយគ្នា រហូតដល់មានដាក់ការិយាល័យ FBI ជាមួយនិងអគ្គស្នងការដ្ឋាននគរបាលជាតិ មានអ្នកធ្វើសេចក្តីរាយការណ៍មកធ្វើការជាមួយយើង»។

លោកស្រីបន្តថា ខាងអាមេរិកបានចុះទៅយកព័ត៌មានខ្លួនឯងដោយផ្ទាល់នៅថ្នាក់ក្រោមជាតិ។ លោកស្រីសង្កត់ធ្ងន់ថា «ម្នាក់ៗតែងតែនិយាយថាវិជ្ជមានខ្លាំងណាស់ ប៉ុន្តែផ្ទុយទៅវិញបែរជាមានចំណាត់ថ្នាក់លេខបី ដែលជាចំណាត់ថ្នាក់ទាបបំផុត វាស្មើរនឹងយើងមិនបានធ្វើអ្វីសោះ»។

លោក ម៉ុន្ទ ម៉ុនសារិទ្ធ នាយករងនៃអង្គការការីតាសកម្ពុជាឲ្យដឹងថា កន្លងមកអង្គការការីតាសកម្ពុជា បានខិតខំប្រឹងប្រែងយ៉ាងខ្លាំងដោយបញ្ជ្រាបការយល់ដឹងអំពីរឿងនេះ ទាំងក្នុងសហគមន៍និងក្នុងតំបន់ ជាពិសេសទៅលើគម្រោងការនានារបស់ខ្លួនតាមខេត្តនីមួយ។

លោកបញ្ជាក់យ៉ាងនេះថា «គឺយើងចាប់ផ្តើមប្រយុទ្ធប្រឆាំង ជាពិសេសយើងបណ្តុះបណ្តាលពលរដ្ឋឲ្យគាត់យល់ច្បាស់អំពីការជួញដូរមនុស្ស»

លោកបន្ថែមថា យើងបានពន្យល់ដល់ក្រុមកសិករគោលដៅរបស់យើងឲ្យយល់ដឹងច្បាស់អំពីការចំណាកស្រុកដូចម្តេចដើម្បីមានសុវត្ថិភាព ហើយធ្វើម៉េចដើម្បីទប់ស្កាត់ការចំណាកស្រុកគ្មានសុវត្ថិភាព ដែលបង្កឲ្យមានការជួញដូរ។

លោកអនុប្រធានរូបនេះ បានឲ្យដឹងទៀតថា លោកទទួលស្គាល់ថាក្នុងចំណោមក្នុងក្រុមគោលដៅរបស់អង្គការការីតាសក៏មានចំណាកស្រុកដែរ ប៉ុន្តែពួកគាត់ចំណាកស្រុកដោយសុវត្ថិភាព។ ហើយការចំណាកស្រុកនេះ គឺមានចំនួនតិចតួចប៉ុណ្ណោះ។ លោកលើកឡើងថា «មានទៅប្រទេសចិន ថៃ និងម៉ាឡេស៊ី៕»

# អគ្គសញ្ញាជ្រមុជទឹកនិងលាបថ្វាសក្នុងថ្ងៃតែមួយ

*អត្ថបទ៖ ចាន់ ម៉ានុត*

បេក្ខជនចំនួន៤រូប បានសុំព្រះសហគមន៍ទទួលអគ្គសញ្ញាជ្រមុជទឹក និងលាបថ្វាសក្នុងថ្ងៃតែមួយ ដើម្បីក្លាយជាគ្រីស្តបរិស័ទកាតូលិក កាលពីពេលថ្មីៗនេះ នៅព្រះវិហារសន្តសិលា និងសន្តប៉ូល នារាជធានីភ្នំពេញ។



«នាងខ្ញុំបានទទួលពិធីជ្រមុជទឹក ក្នុងថ្ងៃនេះ គឺដោយសារតែនាងខ្ញុំទទួលការជឿលើព្រះយេស៊ូ» នេះជាការលើកឡើងរបស់វេរ៉ូនីកា ស៊ូ ស្រីនីត មកពីព្រះសហគមន៍ សន្តសិលា និងសន្តប៉ូល។

ស្រីនីតបន្តថា នាងបានរួមដំណើរជាមួយព្រះសហគមន៍ក្នុងរយៈពេល៧ឆ្នាំមកហើយ ទើបសម្រេចចិត្តទទួលអគ្គសញ្ញាជ្រមុជទឹក។ យុវតីរូបនេះឲ្យដឹងថា ពេលជ្រមុជទឹកហើយ នាងគឺជាបុត្រធីតារបស់ព្រះជាម្ចាស់ និងមានតួនាទីសំខាន់ គឺត្រូវប្រកាសដំណឹងល្អនិងដើរតាមព្រះជាម្ចាស់។

«ព្រះអង្គគឺជាព្រះតែមួយគត់ដែលរំដោះយើងចេញអំពីបាប» ស្រីនីតបញ្ជាក់។

យុវតីរូបនេះបន្ថែមថា «នៅថ្ងៃអនាគតនាងខ្ញុំនឹងធ្វើជាគ្រីស្តបរិស័ទគម្រូ ដោយប្រកាសដំណឹងល្អ នឹងសម្តែងធម៌មេត្តាករុណាដោយជួយបងប្អូនដែលជាជនក្រីក្រ»

ហ្វ្រង់ស៊ីស្កូ សាវីយ៉េ នឿង វ៉ី ជាបេក្ខជនម្នាក់ទៀត និយាយថា ទម្រាំតែបានទទួលអគ្គសញ្ញាជ្រមុជទឹក «ខ្ញុំបាទបានតាំងចិត្តថា នឹងបន្តអប់រំជំនឿ បន្តអធិដ្ឋាន ស្តាប់ព្រះបន្ទូល ដើម្បីក្លាយជាគ្រីស្តបរិស័ទម្នាក់ដ៏ល្អ ជាគម្រូដល់ប្អូនដែលកំពុងតែឈ្វេងយល់នៅជំនាន់ក្រោយផងដែរ »

នឿង វ៉ី បានតាំងចិត្តនាំព្រះបន្ទូលរបស់ព្រះជាម្ចាស់ទៅដល់អ្នកឯទៀតៗតាមរយៈកម្មវិធីអប់រំជំនឿរបស់ព្រះសហគមន៍។ «ខ្ញុំនឹងធ្វើជាគ្រូអប់រំជំនឿ... ចែករំលែកសេចក្តីស្រលាញ់ មានចិត្តសប្បុរស បម្រើអ្នកដទៃ ដើម្បីបញ្ជាក់ពីវត្តមានរបស់ព្រះជាម្ចាស់ ថាទ្រង់ពិតជាគង់នៅជាមួយយើងជានិច្ច»

ពិធីជ្រមុជទឹកនិងលាបថ្វាស ប្រព្រឹត្តទៅក្រោមអធីបតីភាពរបស់លោកបូជាចារ្យ សិលា សួន ហង្សលី កាលពីថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០២២ នៅព្រះវិហារសន្តសិលា និងសន្តប៉ូល។

ក្នុងធម្មទេសនាលោកបូជាចារ្យហង្សលី មានប្រសាសន៍ថា ក្នុងជីវិតជាគ្រីស្តបរិស័ទ មានកិច្ចការ២ដែលយើងត្រូវធ្វើ គឺធ្វើកិច្ចការច្រើនដូចនាងម៉ាថា និងស្តាប់ព្រះបន្ទូលដូចនាងម៉ារីដែលមាននៅក្នុងគម្ពីរសម្រាប់ថ្ងៃនេះ (លក១០,៤១-៤២)។

លោកបូជាចារ្យ សិលា សួន ហង្សលី មានប្រសាសន៍ទៅកាន់បេក្ខជនទាំង៤រូប ឲ្យខិតខំព្យាយាមស្តាប់ព្រះបន្ទូលរបស់ព្រះយេស៊ូគ្រីស្ត ដើម្បីអោយព្រះបន្ទូលជ្រួតជ្រាបនៅក្នុងចិត្តដែលនាំឲ្យអាចបង្កើតជាផលផ្លែចេញមកតាមរយៈការស្តាប់នេះ។

លោកបន្ថែមថា ត្រូវរៀនទទួលព្រះយេស៊ូក្នុងជីវិតរស់នៅប្រចាំថ្ងៃ ដោយទទួលបងប្អូនឯទៀតៗ ជាពិសេសរងទុក្ខលំបាក ក្រីក្រ និងអ្នកត្រូវការជំនួយ ដោយត្រូវនឹកចាំអំពី ព្រះបន្ទូលរបស់ព្រះអង្គដែលថា «គ្រប់ពេលដែលបងប្អូនបានប្រព្រឹត្តអំពើតូចតាចណាមួយចំពោះ នរណាម្នាក់ ដូចបានប្រព្រឹត្តចំពោះខ្ញុំដែរ»

លោកបានបញ្ជាក់ថា នៅពេលដែលយើងទទួល ពិធីជ្រមុជទឹក គឺបានរួមស្លាប់រួមរស់ជាមួយព្រះយេស៊ូ ហើយយើងបានឈ្វេងយល់ជាមួយគ្នា នូវសេចក្តីពិតនឹងណែនាំឲ្យយើងរួចពីអំពើបាប។ យើងទទួលជីវិតថ្មី ទទួលព្រះជន្មផ្ទាល់របស់ព្រះអង្គ។

តាមកម្មវិធីអប់រំជំនឿរបស់ព្រះសហគមន៍កាតូលិក អស់អ្នកដែលទទួលអគ្គសញ្ញាជ្រមុជទឹក និងលាបថ្វាស ចាំបាច់ត្រូវមានបងធម៌នៃជំនឿមកជាមួយ ដែលជាអ្នកណែនាំប្អូនធម៌ឲ្យយល់ដឹងកាន់តែច្រើនអំពីព្រះជាម្ចាស់។

តេរេសា ជិន សុភាព ជាបងធម៌របស់បេក្ខជនក្នុងថ្ងៃនេះឲ្យដឹងថា ក្នុងនាមជាបងធម៌ គាត់ត្រូវតែបន្តអធិដ្ឋានសម្រាប់ប្អូនៗដែលទទួលអគ្គសញ្ញាជ្រមុជទឹក និងអគ្គសញ្ញាលាបថ្វាសនៅថ្ងៃនេះ ដើម្បីក្លាយជាគ្រីស្តបរិស័ទថ្មីដែលមានកម្លាំងមាំមួន ក្នុងដំណើរបេសកម្មថ្មីដែលបានទទួលពីព្រះយេស៊ូតាមរយៈព្រះសហគមន៍៕

# ជំនួបដំបូងរវាងលោកសិលា សួន ហង្សលី និង អ្នកដឹកនាំព្រះសហគមន៍ក្នុងភូមិភាគកំពង់ចាម





*អត្ថបទ៖ សុវណ្ណា និងកញ្ញា*

លោកអភិបាលថ្មីដែលទើបនឹងត្រូវជ្រើសរើសដើម្បីដឹកនាំព្រះសហគមន៍ភូមិភាគកំពង់ចាម លោកសិលា សួន ហង្សលី បានជួបប្រជុំជាមួយលោកបូជាចារ្យក្នុងតំបន់ បព្វជិត-ជិតា នៅក្នុងភូមិភាគកំពង់ចាមលើកដំបូង កាលពីថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០២២នេះ នៅក្រុងកំពង់ចាម។

សម្ដេចប៉ាបហ្វ្រង់ស៊ីស្លូ បានជ្រើសតាំងលោកបូជាចារ្យសិលា សួន ហង្សលី ដែលបច្ចុប្បន្នកំពុងបម្រើការងារនៅមណ្ឌលសកម្មភាពភ្នំពេញថ្មី ជាតំណាងពេញសិទ្ធិលោកអភិបាលព្រះសហគមន៍ភូមិភាគភ្នំពេញ និងជានាយកទេវវិទ្យាល័យសន្តយ៉ូហានម៉ារីយ៉ាណែរ ដើម្បីទទួលមុខងារជាអភិបាលទទួលខុសត្រូវព្រះសហគមន៍កាតូលិកភូមិភាគកំពង់ចាម កាលពីថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០២២នេះ។

លោកត្រូវបានបន្តមុខងារពីលោកអភិបាលអន់តូនីសាមី ស៊ូសៃរាជ្យ និងលោកអភិបាលប៊្រុយណូ កូសម៍( Apostolic Administor) នៃព្រះសហគមន៍ភូមិភាគកំពង់ចាម។ បន្ទាប់ពីសារត្រូវបានផ្សព្វផ្សាយកាលពីថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០២២ លោកបូជាចារ្យហង្សលី ទទួលសារលើកទឹកចិត្តជាច្រើនសម្រាប់បេសកកម្មថ្មីរបស់លោក។

«ខ្ញុំមានចិត្តរំភើប ដោយមិននឹកស្មានថា ជាបូជាចារ្យម្នាក់អាចជួយណែនាំភូមិភាគមួយនោះទេ» នេះជាប្រសាសន៍របស់លោកអភិបាលថ្មីនៃភូមិភាគកំពង់ចាម ដែលបានផ្ដល់បទសំភាសន៍កាលពីថ្ងៃទី១៨ ខែកក្កដាកន្លងទៅនេះ។

លោកបន្ថែមថា គាត់បានទទួលសារពីលោកបូជាចារ្យ គ្រីស្ដបរិស័ទ និងលោកអភិបាលផ្សេងៗទៀតបានផ្ញើសារជួយគាំទ្រ ហើយពួកគាត់បង្ហាញអំណរសប្បាយ និងលើកទឹកចិត្តឲ្យលោកបម្រើក្នុងឋានៈជាអ្នកជួយណែនាំភូមិភាគកំពង់ចាម។

«ខ្ញុំនឹងយកចិត្តទុកដាក់ ប្រើអស់ពីសមត្ថភាពដើម្បីបំពេញមុខងារថ្មី ដែលព្រះសហគមន៍បានជ្រើសរើស» លោកហង្សលីបន្ថែម។

និយាយអំពីបេសកកម្មនៃការបម្រើក្នុងភូមិភាគនេះ លោកអភិបាលបានឲ្យដឹងទៀតថា គាត់ត្រូវរៀបចំកន្លែងដែលគាត់កំពុងទទួលខុសត្រូវឲ្យមានអ្នកទទួលការងារជំនួសសិន បន្ទាប់មកពេលទៅកំពង់ចាម គឺត្រូវមានជំនួបជាមួយលោកបូជាចារ្យ ក្រុមអ្នកបួស និងលោកអភិបាលក្នុងភូមិភាគពីមុន ដើម្បីសិក្សាឈ្វេងយល់អំពីព្រះសហគមន៍ក្នុងតំបន់ទាំងនោះ មុននឹងរៀបចំផែនការការងារ។

លោកអភិបាលសង្កត់ធ្ងន់ថា «កម្លាំងដែលខ្ញុំមាន គឺបានមកពីលោកបូជាចារ្យ បងប្រុសបងស្រី និងគណៈកម្មការនៅទីនោះដែលគេផ្ដល់ជាគំនិត និងជួយខ្ញុំតាមរបៀបផ្សេងៗ ដើម្បីឲ្យខ្ញុំអាចបំពេញមុខងារណែនាំភូមិភាគនេះបាន»

លោកមានប្រសាសន៍ទៀតថា មុខងារនេះណែនាំឲ្យគ្រីស្ដបរិស័ទរិះគិតអំពីរបៀបនៃការកសាងព្រះសហគមន៍កម្ពុជា ហើយក៏ជាឱកាសដើម្បីឲ្យមនុស្សទូទៅឈ្វេងយល់ថា ព្រះសហគមន៍កាតូលិកមិនមែនជាសាសនាបរទេស ប៉ុន្តែជាសាសនាសកលមួយ។

ព្រះសហគមន៍កាតូលិកបានមកដល់ទឹកដីកម្ពុជាក្នុងឆ្នាំ១៥៥៥ ប៉ុន្តែដោយសារតែសង្គ្រាម ព្រះសហគមន៍រងគ្រោះនិងមិនសូវរីកចម្រើន។ លោកអភិបាលបានសុំឲ្យគ្រីស្ដបរិស័ទទាំងអស់អធិដ្ឋានឲ្យបានច្រើន សម្រាប់គាត់ផង និងខ្លួនពួកគេផង និងសម្រាប់ព្រះសហគមន៍ក្នុងការប្រកាសដំណឹងល្អដល់បងប្អូនឯទៀត។

លោកបូជាចារ្យ សិលា សួន ហង្សលី ជាបូជាចារ្យខ្មែរទី៣ ដែលត្រូវបានជ្រើសតាំងឲ្យណែនាំព្រះសហគមន៍។ លោកបូជាចារ្យ យ៉ូសែប ឆ្មារ សាឡាស់ បានក្លាយជាអភិបាលព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញក្នុងឆ្នាំ១៩៧៥-១៩៧៧ និងលោកអភិបាលប៉ូល ទេព អ៊ឹម សុត្ថា អភិបាលព្រះសហគមន៍ភូមិភាគបាត់ដំបង ដែលអស់លោកត្រូវបានស្លាប់និងត្រូវបានសម្លាប់ដោយរបបប្រល័យពូជសាសន៍ប៉ុលពត។

ពិធីប្រគល់មុខងារជាអភិបាលព្រះសហគមន៍ភូមិភាគកំពង់ចាមសម្រាប់លោកអភិបាលថ្មី នឹងប្រព្រឹត្តទៅក្នុងពេលខាងមុខ៕

# ការប្រកួតកីឡា ដើម្បីមិត្តភាពនិងសាមគ្គីភាពក្នុងព្រះសហគមន៍

*អត្ថបទ៖ កែវ កញ្ញា*

អួន សារាយ មកពីព្រះសហគមន៍តាហែននៃក្រុមជ័យលាភីលេខ១ខាងនារី បាននិយាយថា គាត់រីករាយដែលបានចូលរួមក្នុងកម្មវិធីប្រកួតបាល់ទាត់នេះ ហើយអ្វីដែលពិសេសនោះ គឺគាត់បានស្គាល់មនុស្សជាច្រើនមកពីកន្លែងផ្សេង រួមនឹងរបៀបលេងបាល់ផងដែរ។

«មកជួបជុំមិត្តភក្តិទាំងអស់គ្នា បានស្គាល់ក្រុមច្រើន។ ខ្ញុំចូលរួមក្នុងកម្មវិធីនេះ ស្គាល់ទិកនិកលេង និងក្រុមកីឡាផ្សេងៗ»។ សារាយបញ្ជាក់។

ឡី ឆវ៉ន ពីព្រះសហគមន៍បាត់ដំបងជ័យលាភីលេខ១ខាងបុរស បានឲ្យដឹងថា គាត់និងក្រុមបាល់ទាត់របស់គាត់ចូលរួមក្នុងកម្មវិធីនេះ ដើម្បីបង្កើតមិត្តភាព ស្គាល់មនុស្សកាន់តែច្រើន និងជាសារមួយដើម្បីបញ្ចៀសគ្រឿងញៀនក្នុងសហគមន៍ ដោយសារការលេងកីឡា។

កម្មវិធីបឺសបខាប់នេះត្រូវបានធ្វើឡើងកាលពីឆ្នាំ២០១០ ក្រោមការផ្ដួចផ្ដើមរបស់លោកអភិបាលទេពច័ន្ទពិសិដ្ឋ (គីគេ) នៃព្រះសហគមន៍កាតូលិកភូមិភាគបាត់ដំបង។

លោកអភិបាលមានប្រសាសន៍អំពីគោលដៅនៃកម្មវិធីយ៉ាងនេះថា ៖ «ឲ្យកូនក្មេង យុវជន ចូលរួមបង្កើតមិត្តភាព ចេះតស៊ូបង្កើតក្រុមដែលចេះសាមគ្គីគ្នា និងឲ្យព្រះសហគមន៍មានការរីកចម្រើន»។

ការរៀបចំកម្មវិធីនេះ ក៏បានធ្វើឲ្យមនុស្សជាច្រើនបានស្គាល់ព្រះសហគមន៍ផងដែរ។ នេះបើតាមការបញ្ជាក់របស់លោកអភិបាលច័ន្ទពិសិដ្ឋ។ លោកបានឲ្យដឹងថា ៖ «គេចាប់ផ្ដើមស្គាល់ព្រះសហគមន៍ដោយសារបឺសបខាប់។ យើងមានពីសកលវិទ្យាល័យ នគរបាលគេចូលរួម។ គេចាប់ផ្ដើមស្គាល់ពេទ្យយាយជី ព្រះសហគមន៍»។

លោកអភិបាលមានប្រសាសន៍ទៀតថា កម្មវិធីនេះដែរ ក៏ផ្ដល់ឱកាសឲ្យកុមារនិងយុវជននៅតាមភូមិអាចបញ្ចេញសមត្ថភាពនិងសកម្មភាពរបស់ពួកគេ ចូលរួមជាមួយគ្នាជាក្រុម ដើម្បីបង្កើតមិត្តភាព ដែលមានគុណតម្លៃច្រើនដែលត្រូវនឹងព្រះគម្ពីរនិងទិសដៅរបស់ព្រះសហគមន៍។

តាមការបញ្ជាក់របស់លោកអភិបាល ក្នុងឆ្នាំនេះ គឺមានតែសមាជិកក្រុមក្នុងព្រះសហគមន៍នានា និងមណ្ឌល សាលារបស់ព្រះសហគមន៍ក្នុងភូមិភាគបាត់ដំបងចូលរួមប៉ុណ្ណោះ ដើម្បីឲ្យយើងស្គាល់គ្នាកាន់តែច្រើនឡើង ដែលធ្វើឲ្យ



ទិសដៅដែលយើងគ្រោងទុកកើតជារូបរាង។

លោកអភិបាលរំលឹកថា ការចូលរួមរបស់កុមារនិងយុវជន គឺជារបៀបមួយដែលឲ្យព្រះសហគមន៍ដឹងថា ព្រះសហគមន៍កំពុងមានដំណាក់កាលទៅមុខ។ «យើងកំពុងបំពេញតួនាទីដែលយើងមាន គឺលើកទឹកចិត្តកូនក្មេងឲ្យចូលរួម ឲ្យដឹងថា គេមានតម្លៃចំពោះអ្វីៗដែលគេបានបង្កើត។»

កម្មវិធីប្រកួតបាល់ទាត់ពានរង្វាន់លោកអភិបាលព្រះសហគមន៍ភូមិភាគបាត់ដំបង ប្រព្រឹត្តទៅកាលពីថ្ងៃទី២ ខែកក្កដា ឆ្នាំ២០២២ នៅព្រះសហគមន៍កាតូលិកពេទ្យយាយជី នាក្រុងបាត់ដំបង ខេត្តបាត់ដំបង។ ក្នុងឆ្នាំនេះមានក្រុមប្រកួតចំនួន ១៩ក្រុម ក្នុងនោះមានក្រុមនារីចំនួន៧ក្រុម និងអ្នកជ័យលាភីលេខមួយគឺមានផ្នែកបុរស គ្រីស្ដបរិស័ទបាត់ដំបង.និងផ្នែកនារីក្រុមសសរសន្តិភាពតាហែន៕

# អគារសិក្សាថ្មី ជាក្តីសង្ឃឹមសម្រាប់ធនធានមនុស្សនៅកម្ពុជា





*អត្ថបទ៖ សួន ស្រីហួចដាលីស*

អគារសាលាបឋមសិក្សា នៃមជ្ឈមណ្ឌលវប្បធម៌និងភាសាបរទេស (FFCC) មួយខ្នងដែលមានថ្នាក់រៀន១២បន្ទប់ បានដាក់សម្ពោធជាផ្លូវការក្រោមអធិបតីភាព លោក ម៉ៅ ធនិន្ទ អភិបាលខេត្តកំពត លោកអភិបាលព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ អូលីវីយេ ជ្មីតហស្លេ។

កម្មវិធីសម្ពោធដាក់ឱ្យប្រើប្រាស់នេះ ប្រព្រឹត្តទៅនៅភូមិសុវណ្ណសាគរ ស្រុកកំពង់បាយ ខេត្តកំពត នាព្រឹកថ្ងៃទី១៧ ខែមិថុនាឆ្នាំ ២០២២ ដោយមានអ្នកចូលរួមប្រមាណជាង ៣០០នាក់។

លោកបូជាចារ្យ តាវ៉ូឡា ឃុំាងលូកា ជាប្រធានមណ្ឌលសកម្មភាពកំពត បានលើកឡើងថា សាលានេះមានទិសដៅស្វែងរកសេចក្តីសុខជូនប្រទេសកម្ពុជា ប្រកបដោយវឌ្ឍនភាព ដោយធ្វើឱ្យកុមារគ្រប់ស្រទាប់វណ្ណៈ ទទួលបានការអប់រំប្រកបដោយគុណភាព ភាតរភាព និងលើកកម្ពស់តម្លៃ វប្បធម៌ សីលធម៌ គុណធម៌ ដើម្បីឲ្យកុមារក្លាយជាពលរដ្ឋល្អនៅក្នុងសង្គមនាពេលអនាគត។

លោកអភិបាល អូលីវីយេ ជ្មីតហស្លេមានប្រសាសន៍ថា កម្មវិធីសិក្សារបស់យើងគឺធ្វើយ៉ាងម៉េចដើម្បីណែនាំឱ្យកូនក្មេងយុវជនយុវនារីឲ្យទៅជាមនុស្សដ៏ពេញលក្ខណៈ គឺឱ្យកូនក្មេងរីកចម្រើនបន្តិចម្តងៗ មិនមែនត្រឹមតែចំណេះដឹងប៉ុន្តែជាមនុស្សដែលពេញលក្ខណៈ។

លោកអភិបាលមានប្រសាសន៍ថា៖«សាលាបានខិតខំបណ្តុះបណ្តាលកុមារឱ្យមានសេចក្តីក្លាហានឯករាជម្ចាស់ការដែលចេះទទួលខុសត្រូវនិងបង្កើតទំនាក់ទំនងរវាងលោកគ្រូអ្នកគ្រូជាមួយបងប្អូនព្រមទាំងអ្នកដទៃនៅក្នុងសង្គម»។

លោកអភិបាលបញ្ជាក់ទៀតថា ៖ «យើងជាមនុស្ស ពេញលក្ខណៈនៅពេលដែលយើងចូលទៅក្នុងវប្បធម៌របស់យើងដែលចូលទៅក្នុងគ្រប់វិស័យដែលនាំអោយយើងចូលនៅក្នុងប្រទេសកម្ពុជា ស្គាល់ឫស ណែនាំឱ្យស្គាល់តួនាទីរបស់យើង ជាតួនាទីដ៏សំខាន់ ដោយបន្តរស់នៅក្នុងសុខសន្តិភាពពេញលក្ខណៈ»។

តាមរយៈការកើនឡើងចំនួនថ្នាក់រៀនទាំងមត្តេយ្យ និងបឋមសិក្សា និងមានការឧបត្ថម្ភគាំទ្រពីព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ និងពីសប្បុរសជនមួយចំនួន លោកតាវ៉ូឡា ឃុំាងលូកា ដែលជាគណៈគ្រប់គ្រងរបស់សាលា បានចាប់ផ្តើមកសាងអគារបឋមសិក្សាថ្មីនេះឡើង នៅថ្ងៃទី ២៤ ខែវិច្ឆិកា ឆ្នាំ២០២០ និងបានបញ្ចប់ជាស្ថាពរនៅថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០២១ អគារសិក្សាថ្មីនេះបានបើកទ្វារទទួលសិស្សអោយចូលរៀន ចាប់ពីថ្ងៃទី ១០ ខែមករា ឆ្នាំ២០២២ ។

លោក ម៉ៅ ធនិន្ទ បានថ្លែងអំណរគុណដល់សប្បុរសជន និងព្រះសហគមន៍កាតូលិកដែលបានយកចិត្តទុកដាក់ខ្ពស់ចំពោះកុមារក្នុងវិស័យអប់រំ។ លោកបន្ថែមថា ៖ «យើងត្រូវរួបរួមគ្នាកសាងធនធានមនុស្សតាមរយៈការអប់រំ។ ចំណេះដឹងនាំឱ្យមនុស្សមានសីលធម៌ល្អ ទៅជាធនធានមនុស្សដ៏ពិតប្រាកដ»។

លោកសំណូមពរដល់លោកគ្រូអ្នកគ្រូទាំងអស់ឲ្យចូលរួមយ៉ាងសកម្មដើម្បីផលិតធនធានមនុស្សសម្រាប់ប្រទេសជាតិ ទាំងសីលធម៌ ក្រមសីលធម៌ សុជីវធម៌ សម្លីសម្លៅ អាកប្បកិរិយា ភាសា អក្សរសាស្ត្រ មនសិកា ឆន្ទៈ និងគ្រប់បែបយ៉ាងនៅក្នុងនោះដើម្បីបោះចេញមកនូវធនធានមនុស្សដែលពិតប្រាកដនិងពេញលក្ខណៈសម្បត្តិ។



លោកមានប្រសាសន៍ថា ៖ «ខ្ញុំចង់ឱ្យអ្នកគ្រូអ្នកគ្រូទាំងអស់ បណ្តុះបណ្តាលធនធានមនុស្សពាក់ព័ន្ធទៅនឹងវប្បធម៌កត្តញ្ញូ។ ភាពកត្តញ្ញូ គឺជាអ្វីដែលសំខាន់សម្រាប់ទឹកដីរបស់យើង»។

លោកបញ្ជាក់ថា សាលាដែលមិនបានបំពេញកាតព្វកិច្ចបង្រៀនអំពីរឿងនេះ គឺមិនបានបំពេញតួនាទីជាម្តាយទី២ ពេញលក្ខណៈនោះទេ។

កុមារី លី ម៉េងហួយ ក្នុងវ័យ១២ឆ្នាំ កំពុងសិក្សានៅថ្នាក់ទី៥នៃមជ្ឈមណ្ឌលវប្បធម៌និងភាសាបរទេស និយាយថា ៖ «នៅក្នុងចំណោមកម្មវិធីសិក្សាទាំងអស់ ខ្ញុំចូលចិត្តសិល្បៈនិងភាសាខ្មែរ ព្រោះម៉ាក់ថាភាសាខ្មែរខ្ញុំខ្លាំងនិងរបាំខ្ញុំរាំជាប្រចាំឆ្នាំបានស្អាត»។

ដោយមានការលើកទឹកចិត្តពីម្តាយផង កុមារីពោលទាំងរីករាយថា ធំឡើងនាងចង់ក្លាយជាគ្រូបង្រៀនភាសាខ្មែរ។

ម៉េងហួយបន្តថា៖«ខ្ញុំក៏សូមអរគុណដល់លោកគ្រូអ្នកគ្រូនៅសាលា FFCC ដែលបានបង្ហាត់បង្រៀនខ្ញុំតាំងពីតូចៗរហូតមកដល់ថ្នាក់ទី៥នេះ»។

មជ្ឈមណ្ឌលវប្បធម៌និងភាសាបរទេស សាងសង់លើផ្ទៃដីសរុបចំនួន ៣,១០៨ម៉ែត្រការេ និងផ្ទៃក្រឡាបន្ទប់រៀនទាំងអស់ ចំនួន១,០២៨ម៉ែត្រការេ។ មានអគារចំនួន ៣ខ្នង ១ខ្នងសម្រាប់មត្តេយ្យ មុនតេស្វរី និង២ខ្នងសម្រាប់បឋមសិក្សា ចែកចេញជា បន្ទប់រៀនចំនួន ១២បន្ទប់ បន្ទប់ទឹកចំនួន២៥បន្ទប់ បន្ទប់តន្ត្រី១បន្ទប់ បន្ទប់កុំព្យូទ័រ១បន្ទប់ បន្ទប់ពិសោធន៍១បន្ទប់ បន្ទប់គេហកិច្ច១បន្ទប់ បន្ទប់សុខភាព១បន្ទប់ បណ្ណាល័យ១ បន្ទប់ និងការិយាល័យ១បន្ទប់ ។

បច្ចុប្បន្នមានសិស្សសរុបចំនួន១៨៨នាក់ និងគ្រូបង្រៀននិងបុគ្គលិកចំនួន២១នាក់។ អាគារសិក្សានេះ ត្រូវបានឧបត្ថម្ភសាងសង់ដោយសប្បុរសធម៌មកព្រះសហគមន៍ក្នុងនិងក្រៅប្រទេស៕

# លោកបូជាចារ្យហុងណែនាំឲ្យគ្រីស្តបរិស័ទស៊ូទ្រាំអធិដ្ឋាន

*អត្ថបទ៖ សួន ស្រីហួចដាលីស*

«នៅពេលយើងអត់ធ្មត់ក្នុងការអធិដ្ឋានគឺជាការបង្ហាញជំនឿ។ ការអធិដ្ឋានធ្វើឱ្យមានក្តីសង្ឃឹម» នេះជាការលើកឡើងរបស់លោកបូជាចារ្យ យ៉ូហាន បាទីស្ត ប្រាក់ ប៊ុនហុង ក្នុងពិធីថ្វាយអភិបូជាលើកដំបូងរបស់លោកនៅព្រះវិហារព្រះកុមារយេស៊ូបឹងទំពុន នារាជធានីភ្នំពេញកាលពីពេលថ្មីៗនេះ។

តបតាមការអញ្ជើញរបស់ព្រះសហគមន៍ព្រះវិហារព្រះកុមារយេស៊ូបឹងទំពុន លោកបូជាចារ្យទើបនឹងតែងតាំងកាលពីថ្ងៃទី២៩ ខែមិថុនារូបនេះបានមានប្រសាសន៍ទៀតថា ការអធិដ្ឋាន ដូចជាការប្រើពាក្យ៣ គឺទូលសុំ គោះទ្វារ និងស្វែងរក។

ក្នុងធម្មទេសនាដែលធ្វើឡើងកាលពីថ្ងៃទី២៤ កក្កដា លោកបូជាចារ្យរូបនេះ បន្ថែមថា ការអធិដ្ឋាន គឺសន្ទនាទៅព្រះជាម្ចាស់ ដោយកសាងទំនាក់ទំនងដូចមិត្តសម្លាញ់។ ម្យ៉ាងទៀត ការអធិដ្ឋាន គឺជាការតស៊ូទទួលផលផ្លែ ដូចយើងបានស្តាប់ព្រះយេស៊ូមានបន្ទូលអំពីអ្នកគោះទ្វារ។

លោកបន្តថា ការអធិដ្ឋានសំខាន់ណាស់ ទោះបីព្រះយេស៊ូនៅលើឈើឆ្កាងហើយ ព្រះអង្គក៏នៅតែអធិដ្ឋាន។ លោកបូជាចារ្យហុងរំលឹកថា នៅពេលយើងមានទុក្ខព្រួយ យើងត្រូវអអិដ្ឋាន។ អធិដ្ឋានគឺជាការទូលសុំ ការស្វែងរក ការគោះទ្វារ និងជាការឆ្លើយតបរបស់ព្រះជាម្ចាស់ ទោះបីជាយឺតយ៉ាវ ប៉ុន្តែនឹងបានផលក្នុងថ្ងៃណាមួយ។

ការអធិដ្ឋានមានច្រើនប្រភេទ ដែលមានដូចជា លក្ខណៈផ្ទាល់ខ្លួន ដូចព្រះយេស៊ូ និងលោកអប្រាហាំ។ ការអធិដ្ឋាន ជារបៀបសូត្រផ្គាំ ឬប្រើជាទំនុកបទកំណាព្យ។ ការអធិដ្ឋានជាក្រុម ជាមួយសហគមន៍ ឬអ្នកជឿ។

លោកបញ្ជាក់ទៀថា ការអធិដ្ឋានក៏អាចធ្វើតាមរបៀបស្ងៀមស្ងាត់ ដូចលោកអូហ្គូស្ទីន ដែលជាបិតានៃទេវវិទ្យារបស់ព្រះសហគមន៍ផងដែរ។ លោកបន្ថែមថា «មាត់យើងបិទ តែបេះដូងស្រែករកព្រះជាម្ចាស់»

លោកបូជាចារ្យយ៉ូហាន បាទីស្តប្រាក់ ប៊ុនហុង ជាបូជាចារ្យខ្មែរទី១០ និងជាបូជាចារ្យខ្មែរជាតិពូណងដំបូងគេដែលមានកំណើតនៅខេត្តមណ្ឌលគិរី។ សព្វថ្ងៃលោកកំពុងបម្រើការងារនៅព្រះសហគមន៍រតនគិរី ក្នុងភូមិភាគកំពង់ចាម។

បច្ចុប្បន្នព្រះសហគមន៍កាតូលិកនៅប្រទេសកម្ពុជាមានគ្រីស្តបរិស័ទប្រមាណ២មុឺននាក់ក្នុងចំណោមប្រជាជនខ្មែរ១៦លាននាក់៕

# កិច្ចប្រជុំជេស្វីតអាស៊ីប៉ាស៊ីហ្វិកនៅកម្ពុជា

*អត្ថបទ៖ កែវ កញ្ញា*

សមាជិកក្រុមសហជីវិនព្រះយេស៊ូជាង ២០នាក់ នៅក្នុងអាស៊ីប៉ាស៊ីហ្វិក បានរួមគ្នាធ្វើសន្និសីទនៅក្នុងប្រទេសកម្ពុជា ដើម្បីឈ្វេងយល់បន្ថែមអំពីតម្រូវការនានារបស់សមាជិកក្រុមតាមតំបន់នីមួយៗ។

លោកបូជាចារ្យ អន់តូនីញូ ម៉ូរ៉េណូ (Antonio Moreno, SJ) ប្រធាននៃសន្និសីទសហជីវិនព្រះយេស៊ូប្រចាំតំបន់អាស៊ីប៉ាស៊ីហ្វិក ហៅកាត់ថា JCAP បានមានប្រសាសន៍ថា កិច្ចប្រជុំនៅក្នុងប្រទេសកម្ពុជាសម្រាប់រយៈពេលមួយសប្ដាហ៍នេះ គឺដើម្បីពិនិត្យឡើងវិញនូវផែនការសកម្មភាពក្រុមតាមប្រទេសនីមួយៗ។

លោកប្រធានរូបនេះ បន្ថែមថា ក្នុងកិច្ចប្រជុំសម្រាប់ពាក់កណ្ដាលឆ្នាំ២០២២នេះ គឺចង់លើកកម្ពស់កិច្ចសហប្រតិបត្តិការនិងការយល់ដឹងអំពីបេសកកម្មបន្ថែមទៀត និងមើលអំពីសេចក្ដីត្រូវការរបស់ប្រទេសជាសមាជិក។

«យើងចង់ធ្វើឱ្យប្រាកដថា ផែនការនេះ អាចអនុវត្តបាន ហើយប្រសិនបើយើងត្រូវផ្លាស់ប្ដូរ យើងនឹងផ្លាស់ប្ដូរវា។» លោកអន់តូនីញូពន្យល់។

ជារៀងរាល់ឆ្នាំ JCAP មានកិច្ចប្រជុំ២ដង ដែលធ្វើឡើងក្នុងខែមករានិងខែកក្កដា។ ហើយកិច្ចប្រជុំកាលពីថ្ងៃទី១៨-២២ ខែកក្កដាកន្លងទៅនេះ គឺជាកិច្ចប្រជុំផ្ទាល់ដំបូងបន្ទាប់ពីជំងឺរាតត្បាតបានធូរស្រាល ដែលធ្វើឡើងនៅក្នុងប្រទេសកម្ពុជា នៅមជ្ឈមណ្ឌលភ្នំពេញថ្មី នារាជធានីភ្នំពេញ។

ក្នុងកិច្ចប្រជុំនេះ មានប្រទេសចំនួន ១៥ នៅអាស៊ីប៉ាស៊ីហ្វិក ចូលរួម ដែលក្នុងនោះ មាន៧តំបន់ (Provincial) ដូចជា ហ្វីលីពីន ឥណ្ឌាជប៉ុន អូស្ត្រាលី កូរ៉េ វៀតណាម ចិន (ហុងកុង និងម៉ាកាវ) ឥណ្ឌូនេស៊ី និងអនុតំបន់ចំនួន៤ រួមមាន ថៃ ម៉ាឡេស៊ីនិងសិង្ហបុរី ទីម័រខាងកើត និងមីយ៉ាន់ម៉ា។

លោកបូជាចារ្យ វុន អូ ឆាង ជាតំណាងជេស្វីតកូរ៉េប្រចាំកម្ពុជា ឲ្យដឹងថា សមាជិកក្រុមJCAP មកកម្ពុជា ដើម្បីយល់ដឹងច្បាស់អំពីស្ថានភាពអំពីរបៀបដែលអាចចែករំលែក និងចូលរួមគាំទ្របេសកកម្មជេស្វីតនៅប្រទេសកម្ពុជា។

«នេះជាឱកាសល្អដែលយើងអាចចែករំលែកព័ត៌មានផង និងឲ្យគេយល់ច្បាស់អំពីស្ថានភាពនៅប្រទេសកម្ពុជាផង ហើយដឹងចំណុចណាយើងត្រូវការបន្តនិងចំណុចខ្សោយ ហើយគេអាចគាំទ្រលុយដែរ។» លោកអូ ឆាងបន្ថែម។

ជារៀងរាល់ឆ្នាំ ជេស្វីតអូស្ត្រាលី បានឧបត្ថម្ភសម្រាប់ការសាងសង់និងអាហារូបករណ៍សម្រាប់កូនសិស្សក្រីក្រនៅកម្ពុជាជាមួយសាលាសន្តសាវីយ៉េ ដែលគ្រប់គ្រងដោយជេស្វីតនៅកម្ពុជា។ នេះបើយោងតាមលោកពុក វៀន វូ គីម ជាប្រធានតំបន់ជេស្វីតអូស្ត្រាលី។

«យើងបានជួយគ្រួសារជាច្រើន នៅពេលដែលខ្ញុំបានរស់នៅប្រទេសកម្ពុជា។ ពីមុនយើងមាន១០០នាក់ តែពេលនេះ មាន៨៥០នាក់មកពីគ្រប់ទីកន្លែងក្នុងប្រទេស។» លោកវៀន វូ គីម បញ្ជាក់ ទៀតថា មូលហេតុចម្បងនៃការគាំទ្រនេះ គឺដើម្បីអនាគតរបស់យុវជនកម្ពុជា។

> «នេះជាឱកាសល្អដែលយើងអាចចែករំលែកព័ត៌មានផង និងឲ្យគេយល់ច្បាស់អំពីស្ថានភាពនៅប្រទេសកម្ពុជាផង ហើយដឹងចំណុចណាយើងត្រូវការបន្តនិងចំណុចខ្សោយ ហើយគេអាចគាំទ្រលុយដែរ»

លោកបន្ថែមថា យើងក៏បានជួយសម្រាប់ការអប់រំ កិច្ចការងារសង្គម និងការងារប្រកាសដំណឹងនៅក្នុងព្រះសហគមន៍ភូមិភាគបាត់ដំបងផងដែរ។

ក្រុមសហជីវិនព្រះយេស៊ូបានចូលមកដល់ប្រទេសកម្ពុជាមុនសម័យខ្មែរក្រហម ដោយបម្រើព្រះសហគមន៍ជនជាតិចិននៅទីក្រុងភ្នំពេញ។ ក្រោយកិច្ចព្រមព្រៀងទីក្រុងប៉ារីសនៅក្នុងឆ្នាំ១៩៩១ ក្រុមជេស្វីតបានចាប់ផ្ដើមបេសកកម្មផ្លូវការនៅប្រទេសកម្ពុជា ដោយបម្រើប្រជាជនខ្មែរ និងបានជួយដល់ជនអន្តោប្រវេសន៍វៀតណាម នៅជំរំខ្មែរថៃ ដោយផ្ដល់កិច្ចការសង្គមនិងអប់រំ។

បច្ចុប្បន្ននេះ ជេស្វីតនៅកម្ពុជា មានសាលាសន្តសាវីយ៉េ ដែលមានកូនសិស្សជាង៨៥០នាក់ ចាប់ពីកម្រិតមត្តេយ្យសិក្សារហូតដល់វិទ្យាល័យ។ ជាមួយគ្នានេះក៏មាន កម្មវិធីជាច្រើនដូចជា កម្មវិធីបរិស្ថាន កម្មវិធីអភិវឌ្ឍ អង្គការជេស្វីសីវីស កម្មវិធីសម្រាប់ជនអន្តោប្រវេសន៍ មណ្ឌលបោះពុម្ពសៀវភៅមេហ្គា មណ្ឌលរួមសម្រាប់កម្មករកម្មការិនី។

បច្ចុប្បន្ននេះ ជេស្វីតកម្ពុជា ក៏មានយុវជនខ្មែរចំនួន៣រូបកំពុងរៀនដើម្បីក្លាយជាបព្វជិត រួមមានលោកជួ ដាម៉ូ ដែលនឹងតែងតាំងជាឧបដ្ឋាកក្នុងឆ្នាំ២០២២នេះ លោកគី រីគៃ កំពុងសិក្សាទេវវិទ្យា និងលោកទៀង ចាន់រ៉ា ចូលជាណូវីស៕










# សុបិន្តរបស់ព្រះសហគមន៍កំពតលេចចេញជារូបរាង

*អត្ថបទ៖ សួន ស្រីហួចដាលីស*

ទោះបីជា មាន ភ្លៀង ធ្លាក់ក៏ក្បួន ដង្ហែ ដោយមាន ព្រះឈើឆ្កាង ព្រះគម្ពីរ ទៀន ផ្កាភ្ញី អមដោយស្នូរចម្រៀងលើកតម្កើងព្រះជាម្ចាស់ឥតដាច់ ដោយមានតំណាងគ្រីស្តបរិស័ទ អស់លោកបូជាចារ្យ និង លោក អភិបាលព្រះសហគមន៍កាតូលិក ភូមិភាគភ្នំពេញ អូលីវីយេ ឡឺត ហស្លេ ហែជុំវិញ ព្រះវិហារថ្មី ចំនួន៣ជុំ នាព្រឹក ថ្ងៃ ទី ៤ មិថុនា ២០២២ ដើម្បី ប្រសិទ្ធព្រះវិហារថ្មីនេះទៅជាព្រះដំណាក់របស់ព្រះជាម្ចាស់។



ពិធីនេះប្រព្រឹត្តទៅ នៅភូមិសុវណ្ណសាគរ ស្រុកកំពង់បាយ ក្រុងកំពត និង មានតំណាងគ្រីស្តបរិស័ទមកពី ព្រះសហគមន៍នានាក្នុងភូមិភាគភ្នំពេញ ចូលរួមអបអរសាទរ យ៉ាងច្រើនកុះករ។

នាក់ កញ្ញា ជាគ្រីស្តបរិស័ទនៅមណ្ឌលសកម្មភាពកំពត រៀបរាប់ថា «នៅពេល ដែល បាន ឃើញព្រះវិហារថ្មី ខ្ញុំមាន អារម្មណ៍ សប្បាយរីករាយរំភើប ដោយសារ យើងមានកន្លែងអភិបូជាស្អាត និងមានន្លែងសម្រាប់អធិដ្ឋាន ហើយព្រះវិហារនេះ សាងសង់ដោយមានរចនាគួរឱ្យទាក់ទាញ»

កញ្ញាបានឲ្យដឹងទៀតថា ការរៀបចំតាក់តែងរបស់ព្រះវិហារនេះ បានធ្វើឲ្យនាងមានអារម្មណ៍ជិតស្និទ្ធនឹងព្រះជាម្ចាស់។ «កាលពីមុន ព្រះវិហារចាស់ តូចចង្អៀត ទ្រុឌទ្រោម ពិបាក។ ប៉ុន្តែ ព្រះវិហារ ថ្មី នេះ ធ្វើឱ្យ យើង អាច ចួបជុំគ្នាបានច្រើន និង មានភាពកក់ក្តៅ នៅពេលយើងអធិដ្ឋានមានអារម្មណ៍ថារឹងមាំជាថ្មី» នាក់កញ្ញាបន្ថែម។





ព្រះវិហារថ្មីនេះ មានឈ្មោះថា សន្តអូគូស្តាំង ដែលមានទំហំបណ្តោយ១៧ម៉ែត្រ និងទទឹង១៧ម៉ែត្រ។

លោកបូជាចារ្យ ទទួលខុសត្រូវ ព្រះវិហារ សន្តអូគូស្តាំង លោកតាវ៉ូឡា យ៉ុំងលូកា មានប្រសាសន៍ថាព្រះវិហារថ្មីនេះជាសុបិន្តរបស់ព្រះសហគមន៍កំពត។

លោក បានរំឭកថា កាលពី ឆ្នាំ ២០០៩ ខណៈពេលលោកមកដល់កំពត គឺមានតែបន្ទប់អធិដ្ឋានមួយស្អាត ប៉ុន្តែ ជាសំយ៉ាបផ្ទះ ដែលលោកអភិបាលអូលីវីយេ និង លោក ឪពុក លី បាន រៀបចំ។ ហើយពេលនេះ ព្រះសហគមន៍ របស់យើង ក៏បានលូតលាស់ ដោយពេលយើងថ្វាយអភិបូជានៅថ្ងៃអាទិត្យ មានបងប្អូនមួយចំនួនអង្គុយ នៅខាង ក្រៅ នៅតាមសួន ដែលនាំឱ្យយើងចិញ្ចឹមគំនិតថា «ត្រូវតែរៀបចំឱ្យមានព្រះវិហារមួយ»

លោកបន្តថា «ខ្ញុំជឿ និងសង្ឃឹមថា កន្លែងនេះនិងសកម្មភាព ដែលយើងមានជាប្រចាំនឹងជួយឱ្យព្រះសហគមន៍ របស់យើងរីកចម្រើនជាពិសេសមានភាពជិតស្និទ្ធជាមួយព្រះយេស៊ូ ដោយមានកន្លែងសមរម្យដើម្បីអធិដ្ឋាន ស្តាប់ព្រះបន្ទូល ព្រះជាម្ចាស់»

លោក បូជាចារ្យ ក៏សង្ឃឹមថាព្រះវិហារថ្មីនេះនឹងផ្តល់កម្លាំងចិត្តឱ្យ ព្រះសហគមន៍ កំពត ទោះបីព្រះវិហារតូច ព្រះសហគមន៍តូច ប៉ុន្តែ យើងនៅតែរឹងមាំ ដោយមានឆន្ទៈបន្តទៅមុខដើម្បីប្រកាសដំណឹងល្អ។

ពិធីឆ្លងព្រះវិហារថ្មីនេះ ចាប់ផ្តើមដោយមេជាងប្រគល់កូនសោរទៅលោកអភិបាល ហើយលោកអភិបាលជូនទៅលោកបូជាចារ្យយ៉ុំងលូកា បើកទ្វារដើម្បីនាំគ្រីស្តបរិស័ទ ចូលក្នុងព្រះដំណាក់ព្រះជាម្ចាស់។

លោកអភិបាលអូលីវីយេ បានប្រោះទឹកព្រះពរ លាបប្រេងលើអាសនៈ បញ្ចុះធាតុរបស់សន្តអូគូស្តាំងកាលពី៧០០ឆ្នាំមុន និងលាបប្រេងលើជញ្ជាំងព្រះវិហារ។

ថ្លែងនៅក្នុងធម្មទេសនា លោកអភិបាលបានរំលឹកថា ក្នុងឆ្នាំ២០០១ លោកនៅជាបូជាចារ្យ ហើយបានបំពេញបេសកកម្មនៅក្នុងតំបន់កំពតជាមួយលោកបូជាចារ្យសួនហង្សលី ដោយធ្វើកិច្ចការមេត្តាករុណា ដើម្បីប្រកាសដំណឹងល្អ។

លោកអភិបាលបានជំរុញឲ្យគ្រីស្តបរិស័ទយកគំរូរបស់សន្តប៉ូលដែលខិតខំ ប្រកាសដំណឹងល្អរហូតដល់ចុងក្រោយនៃជីវិតរបស់លោក។

លោកលើកឡើងថា ត្រូវស្វាគមន៍មនុស្សដែលមករកយើង ហើយយើងផ្ទាល់ខ្លួនដែលជាគ្រីស្តបរិស័ទ ត្រូវតែមាន សេចក្តីសុខសាន្ត សេចក្តីសង្ឃឹម សេចក្តីស្រឡាញ់ ការចេះយល់ចិត្តគ្នា ការចេះបង្កើតទឹកសន្តិភាព ការចេះបង្កើតសុខដុមរមនា។ ជាមួយគ្នានេះ ការប្រកាសព្រះរាជ្យព្រះជាម្ចាស់មិនមែនបង្ខំ ប៉ុន្តែផ្តល់សាក្ខីភាពអំពីជីវិតដែលព្រះជាម្ចាស់ទាននិងដោយយកចិត្តទុកដាក់អប់រំខ្លួន ដូចសន្តប៉ូលដែលមានចិត្តអង់អាច។

> «ខ្ញុំជឿ និងសង្ឃឹមថា កន្លែងនេះនិងសកម្មភាព ដែលយើងមានជាប្រចាំនឹងជួយឱ្យព្រះសហគមន៍ របស់យើងរីកចម្រើនជាពិសេសមានភាពជិតស្និទ្ធជាមួយព្រះយេស៊ូ ដោយមានកន្លែងសមរម្យដើម្បីអធិដ្ឋាន ស្តាប់ព្រះបន្ទូល ព្រះជាម្ចាស់»

លោកក៏បានក្រើនរំឭកគ្រីស្តបរិស័ទទៀតថា យើងត្រូវចេញពីកន្លែងផ្ទាល់ខ្លួនដើម្បីទៅដល់កន្លែងដែលបងប្អូនមានសេចក្តីត្រូវការ និងមានទុក្ខលំបាក ហើយបន្តសក្ខីភាពរបស់យើងជាមួយបងប្អូន ដើម្បីនាំគេឱ្យមានជីវិតពេញបរិបូរណ៍។

នៅក្នុងពិធីឆ្លងនេះ លោកមានប្រសាសន៍ទៀតថា «ពិតមែនព្រះដំណាក់របស់ព្រះជាម្ចាស់ផ្ទះដោយសក្ការៈរបស់ព្រះជាម្ចាស់មិនមែនត្រឹមតែព្រះវិហារទេ ប៉ុន្តែនៅក្នុងដួងចិត្តរបស់យើង ជាយើងដែលជាវត្តមានរបស់ព្រះជាម្ចាស់»

ព្រះសហគន៍កាតូលិកកំពត កកើតឡើងក្នុងខែកុម្ភៈ ឆ្នាំ២០០២ ដោយ មានបេសកកម្មស្វែងរកគ្រីស្តបរិស័ទពីដើម មុនសម័យប៉ុលពត។ ឆ្នាំ២០០៣ ព្រះសហគមន៍បានទិញផ្ទះមួយ រួចបង្កើតឱ្យមានមណ្ឌលសិស្សអូគូស្តាំង បង្កើតឱ្យមានក្រុមមេត្តាករុណា និងអប់រំជំនឿ មជ្ឈមណ្ឌលវប្បធម៌និងភាសាបរទេស និងសាលាមត្តេយ្យ ដោយមានគ្រឹះនៃសាសនទូតព្រះសហគមន៍កាតូលិកបានណែនាំជាច្រើនជំនាន់។ រីឯព្រះវិហារសន្តអូគូស្តាំង ដែលបានជួសជុលកែលម្អពង្រីកបន្ថែមនេះ បានកែប្រែពីផ្ទះរបស់ពុទ្ធសានិកមកជាផ្ទះដែលមានបន្ទប់អធិដ្ឋានរបស់ព្រះសហគមន៍កាតូលិក និងបន្តកែលម្អពង្រីកជាព្រះវិហារក្នុងបរិបទកូវីដ១៩កន្លងទៅ ដោយបញ្ចប់កិច្ចការសំណង់កាលពីដើមឆ្នាំ២០២២នេះ៕

# ព្រះសហគមន៍នឹងបង្កើតគណៈកម្មារសម្រាប់ទឹកដីអន្តរភូមិភាគ



*អត្ថបទ៖ សួន ស្រីហួចដាលីស*

ព្រះសហគមន៍កាតូលិកកម្ពុជា គ្រោងនឹងបង្កើតគណៈកម្មារ សម្រាប់ទឹកដីមរណសាក្សីនៅព្រះសហគមន៍តាំងគោក ក្នុងខេត្តកំពង់ធំ ដែលជាចំណុចកណ្តាលនៃប្រទេសកម្ពុជា។

ក្នុងពិធីគោរពអ្នកបម្រើព្រះជាម្ចាស់ កាលពីពេលកន្លងទៅនេះ លោកអភិបាលអូលីវីយេ ជ្មីតហាស្លេ អភិបាលនៃព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ បានស្នើសុំឲ្យលោកអភិបាលនៃភូមិភាគបាត់ដំបង និងកំពង់ចាម រួមគ្នាជាមួយលោក បង្កើតឲ្យមានកន្លែងពិសេសមួយលើទឹកដីតាំងគោក ជាបូជនីយដ្ឋានសម្រាប់ជំនឿ។

លោកបន្ថែមថា គឺដើម្បីឲ្យគ្រីស្តបរិស័ទនានាបានស្គាល់ប្រវត្តិសាស្ត្រ និងជំនឿនៃព្រះសហគមន៍កាតូលិកកម្ពុជា។

ព្រះសហគមន៍តាំងគោក ជាទីកន្លែងសម្រាប់ព្រះសហគមន៍កាតូលិកអន្តរភូមិភាគនៅកម្ពុជា ដែលតំបន់នេះ ជាកន្លែងប្រវត្តិសាស្ត្រមួយក្នុងសម័យប៉ុលពត ដោយមានលោកអភិបាលឆ្មារ សាទ្បាសនិងសហការីបានធ្លាប់រស់នៅ និងស្លាប់នៅទីនោះ។

លោកអភិបាលឆ្មារ សាឡាស ជាអភិបាលខ្មែរដំបូងគេ ដែលត្រូវបានតែងតាំងក្នុងឆ្នាំ១៩៧៥ ហើយបានទទួលមរណភាពដោយធ្វើការហួសកំលាំង ក្នុងឆ្នាំ១៩៧៧ នៅតំបន់តាំងគោក។

សព្វថ្ងៃនេះ ព្រះសហគមន៍កាតូលិកនៅកម្ពុជា បានបង្កើតគណៈកម្មារសម្រាប់មរណសាក្សី ដើម្បីសិក្សាចងក្រងឯកសាររបស់អស់លោកដែល





> ទោះបីយើងជ្រើសរើសយកមួយណាក៏ដោយ បើយើងមានសេចក្តីស្រឡាញ់ពិត ជម្រើសរបស់យើងមិនខុសទេ។ កុំឲ្យខ្លួនឯងបិទបេះដូងមិនហ៊ានទទួល ខ្លាចបរិយាកាសជុំវិញខ្លួន។ កុំខ្លាច! បើព្រះជាម្ចាស់ត្រាស់ហៅហើយ សូមទៅ។ ពេលទៅ ព្រះជាម្ចាស់នឹងត្រួសត្រាយផ្លូវឲ្យ ហើយ អំណរសប្បាយនោះនឹងមាន











បានស្លាប់និងត្រូវបានគេសម្លាប់ដោយសារជំនឿក្នុងរបបប៉ុលពត។

«៧ឆ្នាំហើយដែលខ្ញុំបានបើកតុលាការជាផ្លូវការ ដោយមានលោកបូជាចារ្យ ប៉ូល រឿងឆ័ត្រសិរីដឹកនាំ ដោយចួបជុំគ្នាជាផ្លូវការជាង៣០ដងដើម្បីកាត់ក្ដីមរណសាក្សីដែលដាក់ឈ្មោះនាសម័យនោះសរុប៣៤នាក់។ ក្នុងនោះមានលោកឆ្មារសាឡាស និងសហការី៤៣នាក់» នេះបើតាមប្រសាសន៍របស់លោកអភិបាលអូលីវីយ៉េ។

មានប្រសាសន៍ទៅកាន់អង្គពិធី ដែលមានគ្រីស្ដបរិស័ទមកពីព្រះសហគមន៍នានាក្នុងប្រទេសកម្ពុជា ប្រមាណជាង១៥០០នាក់ លោកអភិបាលបន្ថែមថា ព្រះសហគមន៍កម្ពុជាត្រូវត្រៀមខ្លួនជាមុនដើម្បីទទួលមរណសាក្សីនៅកម្ពុជា ប្រសិនបើសន្តអសនៈយល់ព្រមតែងតាំងមរណសាក្សីឱ្យយើង។

នៅក្នុងដីរបស់ព្រះសហគមន៍តាំងគោក មានបន្សល់ទុកគ្រែមួយដែលគ្រីស្ដបរិស័ទអះអាងថា ជាគ្រែដែលលោកអភិបាលឆ្មារ សាឡាស និងសហការីរបស់លោកថ្វាយអភិបូជាចុងក្រោយ មុននឹងបែកគ្នាដើម្បីស្វែងរកនិងលើកទឹកចិត្តគ្រីស្ដបរិស័ទតាមតំបន់ចល័តដែលអស់លោកនឹងទៅដល់។

នៅក្នុងធម្មទេសនានាថ្ងៃទី ២២ ខែឧសភានោះ លោកអភិបាលអូលីវីយ៉េ អញ្ជើញគ្រីស្ដបរិស័ទនិងសហការីទាំងអស់ឱ្យនៅស្ងៀមស្ងាត់ដើម្បីនឹករឭកដល់អស់អ្នកស្លាប់ និងត្រូវបានគេសម្លាប់ដោយសារជំនឿ ក្នុងសម័យប៉ុលពត។

ក្រៅពីគ្រែ លោកអភិបាលឆ្មារសាឡាស ក៏មានបន្សល់ទុកខ្សែផ្គាំនិងបន្ទោងឈើឆ្កាងអភិបាលដែលបានបំពាក់ឲ្យគ្នាជាច្រើនដំណាររបស់ព្រះសហគមន៍កាតូលិកនៅកម្ពុជា ហើយត្រូវបានរក្សាដោយម្ដាយបង្កើតរបស់លោកផ្ទាល់។

តាមរយៈការតស៊ូ និងឆន្ទៈរបស់អស់លោកដែលបានបូជាជីវិតដើម្បីប្រកាសដំណឹងល្អទាំងអស់នោះ លោកអភិបាលអូលីវីយ៉េ រំលឹកឲ្យគ្រីស្ដបរិស័ទថា ជីវិតរបស់យើងត្រូវការតស៊ូ និងមានសមត្ថភាពដើម្បីឆ្លងទុក្ខលំបាកទាំងអស់ ហើយកំលាំងដែលយើងអាចយកឈ្នះបាន គឺដោយឈើឆ្កាងរបស់ព្រះគ្រីស្ដ។

«យើងជាសសរដែលពោរពេញដោយជីវិត និងត្រូវចែករំលែកសេចក្ដីស្រឡាញ់ដល់បងប្អូនឯទៀតៗនៅក្នុងជីវិតសាមញ្ញបំផុតរបស់យើង តស៊ូរស់នៅក្នុងក្ដីសង្ឃឹមជានិច្ចដោយមានព្រះវិញ្ញាណដ៏វិសុទ្ធជំរុញយើង» លោកអភិបាលបន្ថែម។

លោកអភិបាលព្រះសហគមន៍ភូមិភាគបាត់ដំបង ទេព ច័ន្ទពិសិដ្ឋ (អេនរីគេ ហ្វីការេដូ) មានប្រសាសន៍ថា យើងមានមរតកមួយពិសេសដែលមានគ្រីស្ដបរិស័ទបូជាជីវិតដោយសារជំនឿ និងបានគិតបានអនុវត្តតាមព្រះជាម្ចាស់។

លោកអភិបាលច័ន្ទពិសិដ្ឋ បានបន្តថា នេះជាគំរូជាសេចក្ដីសង្ឃឹម និងជាមាគ៌ាដែលយើងមាននៅកម្ពុជា។ មរណសាក្សីជាទ្រព្យសម្បត្តិពិសេសដែលយើងត្រូវបន្តថែរក្សា ជាមរតកដែលយើងទទួល។

លោកអភិបាលបន្ថែមថា នៅតាំងគោកបន្តិចទៀតយើងត្រូវបង្កើតគណៈកម្មការ ដោយត្រូវការយុទ្ធសាស្ត្រអភិវឌ្ឍកន្លែង បង្កើតអារាមដើម្បីឱ្យបងប្អូនដែលចង់ស្គាល់ប្រវត្តិសាស្ត្រព្រះសហគមន៍ និងមរណសាក្សីរបស់យើង អាចមកអធិដ្ឋាន មកជួបព្រះជាម្ចាស់ ស្គាល់ព្រះជាម្ចាស់តាមរយៈមរណសាក្សី។

តំណាងគណៈកម្មការមរណសាក្សីកម្ពុជា ដូនជី ម៉ារីណាថាលី ធារី បានឱ្យដឹងថា ដំណើរការមរណសាក្សីកម្ពុជាសព្វថ្ងៃនេះមានឈ្មោះបេក្ខភាពចំនួន១៤នាក់ ក្នុងនោះមានលោកអភិបាល លោកបូជាចារ្យ បព្វជិតបព្វជិតា និងគ្រីស្ដបរិស័ទជាតំណាង។

បច្ចុប្បន្ននេះ គណៈកម្មការកំពុងចងក្រងប្រវត្តិ និងការងារផ្សេងៗដែលលោកអភិបាលឆ្មារសាឡាស ដើម្បីផ្ញើទៅរ៉ូម។ ដូនជីរូបនេះបន្ថែមថា នេះជាក្ដីសង្ឃឹមរបស់យើងទាំងអស់គ្នា ទោះបីជាប្រទេសរបស់យើងតូចមែន ប៉ុន្តែយើងមានអ្នកដែលបានរស់នៅក្នុងជំនឿមុនយើងដោយរក្សាជំនឿ ជាពិសេសក្នុងសម័យខ្មែរក្រហម។

ដើម្បីរៀបចំឯកសារទាំងនេះ គណៈកម្មការបានចួបជាមួយបងប្អូនដែលជាសាក្សីទាំងផ្ទាល់ និងប្រយោលផងដែរ ដើម្បីរៀបចំតាមពេលវេលា។ នេះបើតាមការបញ្ជាក់របស់ដូនជីធារី។

គ្រីស្ដបរិស័ទ រស់ វត្ថា មកពីព្រះសហគមន៍ភ្នំពេញថ្មី បាននិយាយថា «ខ្ញុំនិយាយទៅគឺព្រឺសម្បុរ ដោយពួកគាត់ជាគំរូសម្រាប់យើងដែលនៅរស់ ទាំងជំនឿនិងទាំងការរស់នៅប្រចាំថ្ងៃ។ ជាសញ្ញាសម្គាល់ថាពួកគាត់បានលះបង់ជីវិតតាមព្រះហឫទ័យរបស់ព្រះជាម្ចាស់»

វត្ថា បន្ថែមថា ដូច្នេះយើងអ្នកនៅរស់ ត្រូវរៀនរស់នៅឱ្យស្របទៅនឹងជីវិតរបស់គ្រីស្ដបរិស័ទ៕

# សកម្មភាពនានារបស់ព្រះសហគមន៍កាតូលិកកម្ពុជា

## ព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ




## ព្រះសហគមន៍កាតូលិកភូមិភាគកំពង់ចាម



## ព្រះសហគមន៍កាតូលិកភូមិភាគបាត់ដំបង

